វិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី

# បណ្ដុំសំណេរតែងសេចក្ដី

## ថ្នាក់ទី ១០.១១.១២

## ភាគ ២

**រួមមាន ៖**

- ប្រធានពន្យល់
- ប្រធានពិភាក្សា
- ប្រធានប្រៀបធៀប



និពន្ធនិងរៀបរៀងដោយ អ្នកគ្រូ វណ្ណា ឆាក៉

# អារម្ភកថា

ការសិក្សាស្រាវជ្រាវ គឺមានសារៈសំខាន់ណាស់នៅក្នុងពេលបច្ចុប្បន្ននេះ មិនថាបុគ្គលិកក្នុងស្ថាប័ននានា មនុស្សក្នុងសង្គមទូទៅ ពិសេសអ្នកកំពុងសិក្សា ស្វែងរកចំណេះដឹង ត្រូវការជាចំបាច់នូវការអាន ការស្តាប់ ការកត់ត្រា និងការសាកសួរ ឬស្រាវជ្រាវបន្ថែមនូវរាល់ចម្ងល់ដែលខ្លួនមាន។ ដើម្បីឱ្យការសិក្សារបស់ខ្លួនពេញលក្ខណៈ ឬសិក្សាដោយមិនខាតបង់នូវពេលវេលា សិក្សាដើម្បីទទួលបាននូវផ្លែផ្កានាពេលខាងមុខ។

តាមរយៈស្នាដៃនិពន្ធ និងស្រាវជ្រាវនេះ គឺបានធ្វើឱ្យអ្នកអាន អ្នកសិក្សា និងបានយល់កាន់តែច្បាស់អំពីវិធីសាស្ត្រនៃការសរសេរសំណេរ ហើយធ្វើឱ្យអ្នកអាន អ្នកសិក្សា អាចសរសេរយ៉ាងណាឱ្យបានល្អ សរសេរយ៉ាងណាឱ្យត្រូវប្រធាន កុំបកស្រាយចាកប្រធាន សរសេរតាមបរិបទនៃប្រធានសំណេរ ពិសេសធ្វើឱ្យអ្នកអាន អ្នកសិក្សាស្គាល់ពីលក្ខណៈនីមួយៗរបស់ប្រធានសំណេរ និងចេះពីការធ្វើគ្រោងឆ្អឹងសំណេរ។

តែទោះជាយ៉ាងណាក៏ស្នាដៃនេះគ្រាន់តែជាកិច្ចការស្រាវជ្រាវប៉ុណ្ណោះមិនទាន់មានលក្ខណៈល្អឥតខ្ចោះឡើយ តែអាចឱ្យអ្នកអាន អ្នកសិក្សាយកទៅធ្វើជាគំរូ ឬសិក្សាត្រួសៗបានយ៉ាងងាយស្រួល ហើយវាអាចជួយអ្នកសិក្សាឱ្យមានចំណេះដឹង បន្ថែមលើចំណេះដឹងដែលមានស្រាប់។ លើសពីនេះ ខ្លឹមសារនៃការស្រាវជ្រាវរបស់អ្នកគ្រូនៅមានកម្រិតពុំទាន់មានលក្ខណៈវិទ្យាសាស្ត្រ ជាសកលហើយក៏មិនទាន់ស៊ីជម្រៅលើការស្រាវជ្រាវនៅឡើយ ដែលបណ្តាលឱ្យមានចំណុចខ្វះចន្លោះឆកល្វែង

ទាំងឡាយ និងកើតឡើងដោយអចេតនាជាក់ជាពុំខាន។ អាស្រ័យដូច បានជម្រាបខាងលើ សូមលោកគ្រូ អ្នកគ្រូ និងមិត្តអ្នកសិក្សាស្រាវជ្រាវ និងកូនសិស្សជាទីរាប់អានមេត្តាជួយបំពេញបន្ថែមព្រមទាំង មេត្តាអធ្យាស្រ័យរាល់ចំណុចខ្វះខាតទាំងនេះ។

សូមឱ្យព្រលឹងអក្សរសាស្ត្រខ្មែរស្ថិតនៅគង់វង្សរីកចម្រើនក្នុងដួងចិត្តកុលបុត្រកុលធីតាខ្មែរគ្រប់ជំនាន់តទៅ។ ស្នាដៃមួយនេះកើតឡើងជារូបរាងបាន ដោយសារតែសេចក្តីស្រឡាញ់ ដែលមានចំពោះកូនសិស្សគ្រប់គ្នា!!!

# មាតិកា

អារម្ភកថា
សេចក្តីថ្លែងអំណរគុណ ........................................................................
ប្រធានទី១ ........................................................................ ១
ប្រធានទី២ ........................................................................ ៥
ប្រធានទី៣ ........................................................................ ៨
ប្រធានទី៤ ........................................................................ ១៤
ប្រធានទី៥ ........................................................................ ១៨
ប្រធានទី៦ ........................................................................ ២២
ប្រធានទី៧ ........................................................................ ២៧
ប្រធានទី៨ ........................................................................ ៣៣
ប្រធានទី៩ ........................................................................ ៣៧
ប្រធានទី១០ ........................................................................ ៤២
ប្រធានទី១១ ........................................................................ ៤៨
ប្រធានទី១២ ........................................................................ ៥៣

ប្រធានទី១៣ ........ ៥៨
ប្រធានទី១៤ ........ ៦២
ប្រធានទី១៥ ........ ៦៧
ប្រធានទី១៦ ........ ៧១
ប្រធានទី១៧ ........ ៧៥
ប្រធានទី១៨ ........ ៧៩
ប្រធានទី១៩ ........ ៨៣
ប្រធានទី២០ ........ ៨៨
ប្រធានទី២១ ........ ៩៣
ប្រធានទី២២ ........ ៩៩
ប្រធានទី២៣ ........ ១០៥
ប្រធានទី២៤ ........ ១១០
ប្រធានទី២៥ ........ ១១៥
ប្រធានទី២៦ ........ ១២០
ប្រធានទី២៧ ........ ១២៥
ប្រធានទី២៨ ........ ១៣០
ប្រធានទី២៩ ........ ១៣៥
ប្រធានទី៣០ ........ ១៤៣
ប្រធានទី៣១ ........ ១៤៩
ប្រធានទី៣២ ........ ១៥៣

ប្រធានទី៣៣.......................................................................................១៥៧
ប្រធានទី៣៤ .....................................................................................១៦០
ប្រធានទី៣៥ .....................................................................................១៦៣
ប្រធានទី៣៦.......................................................................................១៦៧
ប្រធានទី៣៧ ......................................................................................១៦៨
ប្រធានទី៣៨.......................................................................................១៧០
ប្រធានទី៣៩.......................................................................................១៧១
ប្រធានទី៤០.......................................................................................១៧២
ប្រធានទី៤១.......................................................................................១៧៣
ប្រធានទី៤២.......................................................................................១៧៤
ប្រធានទី៤៣.......................................................................................១៧៥
ប្រធានទី៤៤.......................................................................................១៧៦
ប្រធានទី៤៥.......................................................................................១៧៧
ប្រធានទី៤៦.......................................................................................១៧៨
ប្រធានទី៤៧.......................................................................................១៧៩
ឯកសារយោង ....................................................................................១៥៣

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងខ្ញុំ សូមសម្តែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាង ជ្រាលជ្រៅចំពោះលោកអ្នកមានគុណទាំងពីរដែលបានបូជានូវសាច់ស្រស់ ឈាមស្រស់ ក្នុងការតស៊ូបំពេញការងារក្នុងការចិញ្ចឹមបីបាច់ ថែរក្សាកូន ទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយគ្មានទាមទារ នូវអ្វី គឺសូមឱ្យតែកូនបានសេចក្តីសុខសុភមង្គល។ ស្នាដៃនេះត្រូវបានចេញពីស្មារតីឆន្ទៈដ៏មុតមាំរបស់អ្នកគ្រូ ឯកទេសអក្សរសាស្ត្រខ្មែរ។ អរគុណចំពោះ

- ពុកម៉ែ ដែលផ្តល់កំណើត ផ្តល់សំភារៈ ផ្តល់កម្លាំងចិត្ត ផ្តល់សេចក្តីស្រឡាញ់ ផ្តល់...គ្រប់យ៉ាង
- បងប្អូន ដែលផ្តល់ជាគំនិត យោបល់ លុយកាក់ ជំរុញទឹកចិត្ត...
- លោកគ្រូ អ្នកគ្រូ ដែលផ្តល់នូវចំណេះដឹង ការអប់រំទូន្មាន ផ្តល់ចំណង់មិត្តភាព...
- មិត្តភ័ក្ត ដែលផ្តល់នូវមិត្តភាពដ៏ល្អ បទពិសោធជីវិត...
- កូនសិស្សជាទីស្រឡាញ់ ដែលផ្តល់នូវស្នាមញញឹម ការរាប់អានដ៏ស្មោះត្រង់ ការយកចិត្តទុកដាក់...
- ខ្លួនឯងដែលមានជំហរដ៏រឹងមាំក្នុងឆន្ទៈជាគ្រូបង្រៀន...

ជាចុងក្រោយខ្ញុំសូមគោរពជូនពរ ដល់អ្នកដែលកំពុងតែអាននូវស្នាដៃនេះ ទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច គ្រប់ពេលវេលា ជាពិសេសឱ្យការសិក្សាកាន់តែមានភាពរីកចម្រើនឡើងៗ។

***ប្រធានទី១៖*** *ច្បាប់រាជនេតិ ឬច្បាប់ព្រះរាជសម្ភារបានថែងថា«ពាក្យគ្រូវែងវីង ស្រាវែងស្រវីង ពុំដែលពិសា ពាក្យពិតវែងស្លែង ពុំពីរោះថា បណ្ឌិតមេធា វែងថាពុំគាប់»។ ចូរពន្យល់ព្រមទាំងលើកឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់ ។*

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម៖

- ***លំនាំបញ្ហា៖*** *ព្រះរាជសម្ភារ ជាព្រះរាជកវីមួយរូបដែលមានចំណេះដឹង មានទេព្យកោសល្យ ប៉ិនប្រសប់ក្នុងការតាក់តែងកំណាព្យ...អប់រំទូន្មានដល់កូនចៅជំនាន់ក្រោយ។*
- ***ចំណូលបញ្ហា៖*** *ក្នុងចំណោមស្នាដៃជាច្រើន ក៏មានកំណាព្យមួយវគ្គបានពោលថែងថា« លើកប្រធានមកសរសេរ។*
- ***ចំណោទបញ្ហា៖*** *តើឃ្លាកំណាព្យខាងលើនេះមានអត្ថន័យខ្លឹមដូចម្តេច?*

### ខ. តួសេចក្តី

- *ឃ្លាភ្ជាប់ភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ...*
- *ពន្យល់ពាក្យ៖*
    - ✓ *គ្រូមានន័យថា អ្នកចេះដឹង មានចំណេះ ជាគំរូ*
    - ✓ *វែង៖ តែងតែ រមែង ច្រើនតែ...*
- *ពន្យល់ប្រធាន៖ ពាក្យសម្តី...ដែលនិយាយត្រង់ ឬណែនាំ... តែងតែញ៉ាំងឱ្យអ្នកដទៃមិនសប្បាយចិត្ត...។*

***បកស្រាយប្រធាន៖***

- *«ពាក្យគ្រូវែងវីង»៖ គ្រូជាគំរូ ត្រូវប្រកបដោយភាពរឹងមាំនូវ*

- ✓ សមត្ថភាព ចំណេះដឹង ជាទំនុកចិត្តសិស្សគ្រប់គ្នា
- ✓ គុណធម៌ សីលធម៌ ជាទីទំនុកចិត្តពីគ្រប់មជ្ឈដ្ឋាន
- ✓ ជាគំរូល្អដល់អ្នកដទៃ មានទំនួលខុសត្រូវ មានភាពយុត្តិធម៌...

- «ស្រាវែងស្រវឹង ពុំដែលពិសា» ស្រាផឹកទៅមិនដែលឈ្ងុយឆ្ងាញ់ពិសា គួរឱ្យចាប់ចិត្តទេ តែបើផឹកវាតែងតែស្រវឹង ដោយ៖
  - ✓ វង្វេងវង្វាន់ស្មារតី លែងដឹងខុសត្រូវល្អអាក្រក់
  - ✓ បាត់បង់គុណធម៌ សីលធម៌
  - ✓ អាប់ប្រាជ្ញា ខូចខួរក្បាល
  - ✓ កើតរោគ កើតជំងឺ
  - ✓ កើតមានអំពើហិង្សា អាស្រូវកេរ្តិ៍ ថោកទាប...

ឧទាហរណ៍៖ ក្នុងសង្គម៖ បុគ្គលខ្លះផឹកស្រាជាប់ញៀនស្រវឹងខូចសុខភាព វង្វេង គ្រោះថ្នាក់ស្លាប់...។

***ក្នុងអក្សរសិល្ប៍៖*** រឿងទុំទាវ៖ ទុំផឹកស្រាស្រវឹង ភ្លេចភ្លាំងស្មារតី ត្រូវគេសម្លាប់

រឿង តេជោយ៉ត៖ ស្តេចសំរែ ផឹកស្រាសន្លប់ គេចាប់បានកាត់ទោស ស្លាប់...។

- «ពាក្យពិតវែងស្លែង ពុំពីរោះ»៖ ពាក្យសម្តីពិតតែងនិយាយទៅធ្វើឱ្យទាស់ចិត្ត ទាស់ត្រចៀក អ្នកស្តាប់មិនចង់ឮ វាមិនមែនជាពាក្យដែលគួរឱ្យចង់ស្តាប់ ព្រោះពាក្យពិតខ្លះធ្វើឱ្យអ្នកដទៃ៖

- ក្តៅក្រហាយ ដោយសារតែគិតពីពាក្យសម្តី...
- មិនចូលចិត្ត ស្អប់ គ្រាន់ដឹងៗ ស្អប់តែម្តង
- កើតជាគំនិតគុំគួន ការសងសឹក
- ខូចខាតបាត់បង់ប្រយោជន៍
- ខឹងសម្បារ រករឿងឈ្លោះគ្នា នាំឱ្យរងទុក្ខ ឈឺចាប់ សោកស្តាយ...

ឧទាហរណ៍៖

- ក្នុងសង្គម៖ រឿងពិតដែលជាកិច្ចការសម្ងាត់របស់អ្នកដទៃ បើយើងនិយាយចេញមក គេដឹងនឹងកើតការចងគំនុំ នាំឈ្លោះគ្នា...។
- ក្នុងអក្សរសិល្ប៍៖
  - រឿង មនុស្សលោក៖ ក្មេងស្រីដែលនិយាយពិតពីខ្លាចាស់ថាធុំក្លិនស្អុយ...ត្រូវស្លាប់។
  - រឿង តាថេន ចៅសន៖ ចៅសននិយាយពិតគេធ្វើបានចង់ងាប់...
- «បណ្ឌិតមេធា រែងថាពុំគាប់» ពាក្យបណ្តាំហាមប្រាម ស្តីប្រដៅ ទូន្មានកូនចៅរបស់ឪពុកម្តាយចំពោះកូនរមែងមានភាពរឹង ដាក់កំហិត រហូតលោកហ៊ានះ
  - ជេរវាយស្តីប្រដៅដោយប្រើពាក្យទ្រគោះបោះបោក គំរោះគំរើយ
  - ឃាត់ឃាំង រាំងខ្ទប់មិនឱ្យកូនធ្វើអ្វីតាមចិត្ត

- ✓ អប់រំដោយចិត្តក្តៅត្រជាក់...តែងតែពុំគាប់ចិត្តកូនទេ ធ្វើឱ្យកូនមិនសប្បាយចិត្ត ខឹង តបមកវិញកមាន។តែពាក្យទាំងនោះជាបំណងល្អចង់ឱ្យកូនចៅបានល្អ...។

ឧទាហរណ៍៖

- ក្នុងសង្គម៖ ឪពុកម្តាយប្រៀនប្រដៅកូន...
- ក្នុងអក្សរសិល្ប៍៖ រឿង ក្បួនជីវិត៖ ពាក្យប្រៀនប្រដៅរបស់ឪពុកនាងមាលា...នាងមាលាមិនចង់ស្តាប់...
- រឿង ទុំទាវ៖ ម្តាយខំណែនាំ បង្ហាញផ្លូវដល់នាងទាវ...នាងមិនចង់ស្តាប់

សរុបសេចក្តីមក៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ខាងលើយ៉ាងក្បោះក្បាយលម្អិតរួចមក សបញ្ជាក់ឱ្យឃើញថា...

## គ. សេចក្តីបញ្ចប់

- ✓ វាយតម្លៃប្រធាន៖ ឆ្លងតាម ការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើពិតជាផ្តល់តម្លៃអប់រំយ៉ាងជ្រាលជ្រៅដល់កូនចៅជំនាន់ក្រោយ...។
- ✓ មតិផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែតស៊ូខិតខំរៀនសូត្រឱ្យបានជ្រៅជ្រះ ស្តាប់តាមការណែនាំរបស់ឪពុកម្តាយ...។

**ប្រធានទី២៖** មានកំណាព្យមួយឃ្លាលើកឡើងថា« ចំណេះកើតមានព្រោះការរៀន កម្ជិលរៀនប្រៀនកុំសម្ដែង ធ្វើឱ្យគេស្ញើចកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្ដីផ្ដើម៖

- ✓ លំនាំបញ្ហា៖ មនុស្សម្នាក់ៗកើតមកមិនដែលចេះឯងនោះទេ ត្រូវតែមានការហាត់រៀន ខំរៀនសូត្រជាប្រចាំទើបចេះបាន ហើយក៏មិនត្រូវមានគំនិតខ្ជិលច្រអូសនោះដែរ។
- ✓ ចំណូលបញ្ហា៖ អាស្រ័យហេតុនេះហើយទើបមានកំណាព្យ«............»
- ✓ ចំណោទបញ្ហា៖ ចោទសួរបែបពន្យល់

### ខ. តួសេចក្ដី

- ✓ ឃ្លាភ្ជាប់សេចក្ដី៖
- ✓ ពន្យល់ពាក្យគន្លឹះ
    - ចំណេះមានន័យថា ការចេះ ចេះដឹង យល់ដឹង...
    - កម្ជិល មានន័យថា ខ្ជិលច្រអូស មិនឧស្សាហ៍...
    - ស្លាក់ស្លែងមានន័យថា ទូគោះបោះបោក កំហែងគំហក...
- ✓ ពន្យល់ន័យប្រធាន៖
- ✓ បកស្រាយប្រធាន៖

- ចំណេះកើតមានព្រោះការរៀន៖ មានន័យថា មានចំណេះដឹង មានសមត្ថភាព បញ្ញាញាណ ភ្លឺស្វាង ទាល់តែមានការឆ្លងកាត់ការរៀនសូត្រដោយ៖
  -ខំស្រវាស្រទេញ សិក្សាស្រាវជ្រាវជាប្រចាំ
  -ធ្វើលំហាត់ដែលគ្រូដាក់ឱ្យ
  -ខំត្រងត្រាប់ស្តាប់ការណែនាំរបស់គ្រូ
  -ស្តាប់ពាក្យអប់រំ សួរនាំគ្រូឱ្យអស់ចម្ងល់
  -ស្វ័យសិក្សារៀនសូត្រដោយខ្លួនឯង
  -ខំរៀនទាំងយប់ថ្ងៃ ខែ ឆ្នាំ ទើបទទួលបានចំណេះ...
- ឃ្លា«កម្ជិលអៀនប្រៀនកុំសម្តែង» មានន័យថាមនុស្សយើងមិនត្រូវមានភាពខ្ជិលច្រអូស ទម្រន់ តំអក់ និងមិនត្រូវអៀនប្រៀនខ្មាសគេខុសបែបបទ ខ្វះភាពក្លាហាន មិនហ៊ានប្រឈមមុខ គិតតែពីអៀនអន់ មុជមិនជ្រៅទៅមិនឆ្ងាយ ការងារទាំងឡាយក៏មិនសម្រេចតាមបំណងដែរ។
- ឃ្លា«ធ្វើឱ្យស្មើចកោតក្រែង»មានន័យថា កើតមកជាមនុស្សមិនត្រូវធ្វើឱ្យមានកេរ្តិ៍ឈ្មោះមិនល្អនោះឡើយ តែត្រូវខិតខំធ្វើយ៉ាងណា ដើម្បីឱ្យខ្លួនឯងមានកេរ្តិ៍ឈ្មោះកិត្តិយសថ្លៃថ្នូរ រុងរឿងជាទីកោតក្រែងពីសំណាក់អ្នកដទៃ...។
- ឃ្លា«ស្លាក់ស្លែងទេកុំរិះគន់គេ» មានន័យថា មិនត្រូវប្រើពាក្យសម្តីទ្រគោះបោះបោក កំហែងគំហក ទៅឱ្យគេ

និយាយល្អ ទាំងយើងស្មាក់ស្មើរ ទៅរិះគន់វាយតប់អ្នកដទៃ ថាជាមនុស្សមិនដែលល្អឡើយ។ ការរិះគន់ផ្តេសផ្តាសជារឿងមិនល្អទេព្រោះ៖

- ✓ ត្រូវគេស្អប់ខ្ពើម ខឹង
- ✓ គុំគួនសងសឹក មានរឿងមិនចេះចប់
- ✓ គេមិនស្រឡាញ់រាប់អាន គេចាប់ទោសអូសដំណើរ...

- ឧទាហរណ៍ក្នុងអក្សរសិល្ប៍៖
  - ✓ រឿង កុលាបប៉ៃលិន៖ ចៅចិត្រខំរៀន ចេះចាំ អាចអនុវត្តបាន ទទួលបានការងារធ្វើ...។
  - ✓ រឿង តេជោយ៉ត៖ យ៉តខំរៀន ជាក្មេងឧស្សាហ៍ក្លាហាន មិនខ្ជិលច្រអូស ............................មានសក្តិយស។
  - ✓ រឿង រាមកេរ្តិ៍៖ ដោយសារតែព្រះរាមមានតម្រិះ មានឫទ្ធិអំណាច មានគេកោតស្ញប់ស្ញែង...។
- **សរុបសេចក្តី៖**

## គ. សេចក្តីបញ្ចប់៖

- វាយតម្លៃប្រធាន៖ ...ឃ្លាកំណាព្យល្អ អប់រំមនុស្សឱ្យខំរៀនដើម្បីមានចំណេះដឹង និងត្រូវមានភាពក្លាហាន ...ឱ្យតម្លៃ។
- មតិផ្ទាល់ខ្លួន៖

**ប្រធានទី៣៖** ច្បាប់ព្រះរាជសម្ភារបានចែងថា«កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្ក្រម៍ កុំទុកចិត្តអភិប្រាយ ប្រើទុំលែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ បណ្តាំមេជី»។ ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ក. សេចក្តីផ្តើម៖

- លំនាំបញ្ហា៖ ព្រះរាជសម្ភារជាកវីមួយរូប...
- ចំណូលបញ្ហា៖ ក្នុងចំណោមស្នាដៃទាំងនោះក៏មានឃ្លាកំណាព្យ«....»
- ចំណោទបញ្ហា៖ តើ.................................មានខ្លឹមសារយ៉ាងដូចម្តេច?

### ខ. តួសេចក្តី៖

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យគន្លឹះ៖

  -បរទេសមានន័យថាជាជាតិសាសន៍ដទៃ

  -អភិនេស្ក្រម៍ មានន័យថា អ្នកលះបង់ទ្រព្យរក្សាសីល

  -អភិប្រាយ អ្នកពូកែនិយាយ រៅហារ
- ពន្យល់ន័យប្រធាន៖ មិនត្រូវទុកចិត្តជាតិសាសន៍ដទៃ............................។
- បកស្រាយប្រធាន
  - ✓ ឃ្លា«កុំទុកចិត្តបរទេស» កុំឱ្យជឿជាក់ឬទុកចិត្តលើសាសន៍ដទៃ ព្រោះគេតែងតែមានទំនៀមទម្លាប់

ប្រពៃណី ជំនឿសាសនា វប្បធម៌ខុសពីម្ចាស់ស្រុក។ បើទោះបីជាពួកនេះកើតក្នុងប្រទេសយើងក្តី ចូលសញ្ជាតិយើងក្តី ក៏កុំទុកចិត្តឱ្យអស់ពីពោះឡើយ។ យើងដឹងហើយថា ជាតិដទៃតែងតែ៖

- កេងចំណេញពីយើង
- គេមិនចោលជាតិសាសន៍គេទេ
- គេអាចធ្វើឱ្យជាតិសាសន៍យើងអន្តរាយ
- ................................................................

- ឃ្លា«កុំទុកចិត្តអភិនេស្ក្រម៍» ជាពួកជន ដែលតាំងខ្លួនជាអ្នកប្រព្រឹត្តនូវព្រហ្មចរិយាធម៌ ប្រកាន់ខ្ជាប់សីលទាន សីលភាវនា គឺរាប់ទាំងអ្នកបួសដែលតាំងខ្លួនជាអ្នកស្ងប់ប្រកបដោយគុណធម៌ខ្ពស់ វិសេសវិសាលក្រៃលែង...។ ជនជំពូកនោះ ខ្លះមានឫកពារសមរម្យ ស្រគត់ស្រគំ សង្រួមឥន្ទ្រិយ៍គួរឱ្យគោរព ឯមួយចំនួនតូចទៀត គ្រាន់តែយកខ្លួនមកជ្រកកោនក្រោមស្លាកសាសនា ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែសកម្មភាពបែរជាបោកប្រាក់គេ។ ជនជំពូកនេះកុំទុកចិត្តខ្លាំងពេក ព្រោះល្អតែខាងក្រៅក្នុងចិត្តពិសពុលគ្មានគុណធម៌។ ការទុកចិត្តជនទាំងនោះ ដោយមិនគិតពិចារណាបានហ្មត់ចត់ នោះយើងនឹងចាញ់បោកជាពុំខាន មកពីយើងមិនអាចសម្គាល់បានមនុស្សល្អ អាក្រក់ត្រឹមតែសម្បកក្រៅនោះទេ។

**ឧទាហរណ៍៖**

- រឿង តាថេនចៅសនះ តាថេនជាអ្នកបួស ធ្វើឱ្យអ្នកភូមិមានទំនុកចិត្តជឿថា ល្អបរិសុទ្ធ តែតាមពិតធាតុពិតតាថេនជាមនុស្សគ្មានសីល ស៊ីសាច់ ផឹកស្រា បោកប្រាក់អ្នកភូមិ...។
- រឿងត្បាល់គ្បឿង៖ មានលោកសង្ឃជាអ្នកបួសតាំងខ្លួនជាអ្នកចេះមើលជំងឺ ធ្វើឱ្យស្ត្រីមេម៉ាយម្នាក់អញ្ជើញឱ្យមើលជំងឺខ្លួន។ ពេលមើលជំងឺសង្ឃកំហូចបានបង្គាប់ស្ត្រីនោះឱ្យទៅជាន់បំបះអង្រែដើម្បីយកកូនមកដាក់ក្នុងត្បាល់ រួចខ្លួនក៏ឡើងទៅរុះរើយកទ្រព្យរបស់អស់ពីផ្ទះ។ ឯស្ត្រីមិនហ៊ានចេញខ្លាចអង្រែធ្លាក់សង្កត់លើកូន បានត្រឹមតែឈរស្រែកឱ្យគេជួយតែគ្មានបានផល
- រឿងសង្រួមហួសប្រមាណ៖ តាបស ជាអ្នកកាន់សីល មានទំនាក់ទំនងនឹងសេដ្ឋី តែងប្រគេនចង្ហាន់ដោយគោរព។ ថ្ងៃមួយតាបសមកលេងផ្ទះសេដ្ឋីធ្វើជាជាប់កម្ទេចស្បូវនឹងក្បាលក៏យកមកឱ្យសេដ្ឋីវិញ។ សេដ្ឋីឃើញបែបនោះនឹកគិតថាតាបសជាមនុស្សល្អម្ល៉េះ គ្រាន់តែកម្ទេចស្បូវសោះក៏យកមកឱ្យវិញដែរ។ ដល់ស្រុកមានចោរច្រើន សេដ្ឋីក៏យកទ្រព្យទៅផ្ញើនឹងតាបស បានឱកាស តាបសយកអស់តែម្តង...។
- «កុំទុកចិត្តអភិប្រាយ» គឺសំដៅដល់ជនដែលពូកែខាងវោហារសព្ទ និងមានសម្តីថ្វីមាត់ពូកែប្រាជ្ញព្រោក និយាយមិនចេះហត់ ធ្វើឱ្យគេឆាប់ជឿសម្តីខ្លួនណាស់។ ជនប្រភេទនេះក៏មិនគួរឱ្យទុកចិត្តទាំងអស់បានដែរទេ ព្រោះ៖

- ✓ ជនដែលពូកែចរចា និយាយស្ដី ហាវមកហាក់មានទំនុកចិត្ត
- ✓ ជនដែលពូកែពូកែទាក់ទាញដោយប្រើថ្វីមាត់ ឱ្យគេឆាប់ជឿមកលើខ្លួន
- ✓ ជនដែលនិយាយហាក់រលូន និយាយស្រួល និយាយល្អគ្មានស្ទាក់ស្ទើរ
- ✓ .....................................................................................................................
- ✓ ជនប្រភេទនេះភាគច្រើនជាជនដែលពូកែបោកប្រាក់កេងបន្លំអ្នកដទៃក៏មាន...។

**ឧទាហរណ៍៖**

- រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់៖ តំណាងរាស្ត្រយ៉េង ជាអ្នកពូកបន្និយាយ ពូកែលួងលោមអមជាមួយវោហារសព្ទទៅឃោសនាបញ្ចុះបញ្ចូលចិត្តសម និងក្រុមកម្មករឱ្យបោះឆ្នោតឱ្យ........................................តែធាតុពិតជាមនុស្សអាក្រក់ មិនបានធ្វើដូចការនិយាយរបស់ខ្លួនឡើយ។
- រឿង ព្រះវេស្សន្តរ៖ តាជូជកមានថ្វីមាត់និយាយបោកប្រាក់ចេតបុត្រថាខ្លួនជាអ្នកនាំសាររបស់ព្រះបាទស្រីសញ្ជ័យ រហូតចេតបុត្រជឿ លែងសម្លាប់ខ្លួន.........................................។ តែតាមពិតពាក្យសម្ដីតាជូជកជាពាក្យកុហកសោះ។

- ឃ្លា«ប្រើទុំលៃងខ្ពស់ រំពឹងឱ្យឆ្ងាយ» គឺជាពាក្យដែលចង់ឱ្យមនុស្សយើងគិតឱ្យបានវែងឆ្ងាយ ច្បាស់លាស់ មុននឹងទៅចូលកាន់ក្នុងកន្លែងអង្គុយ ឬកន្លែងណាមួយ ព្រោះកន្លែងអង្គុយខ្លះអាចឱ្យយើងមានក្តីអាម៉ាស់ អាចខ្មាសគេក្នុងរៀងជំនុំ ពោលគឺត្រូវចូលទៅអង្គុយនៅកន្លែងទាបសិន ........................ប្រសិនបើខុសកន្លែងទើបមានគេអញ្ជើញឱ្យអង្គុយនៅកន្លែងខ្ពស់ទើបមានកិត្តិយស...។

**ឧទាហរណ៍៖** ដូចជាការប្រជុំក្រុមប្រឹក្សាភិបាលខេត្ត តែងមានគណៈអធិបតី មានមេស្រុក មេស្រុករង មានចៅហ្វាយខេត្ត ...............................ស្រាប់យើងជាលេខា ឬជា........................មកអង្គុយត្រង់កៅអីគណៈអធិបតី គេនឹងឱ្យយើងដើរចេញ ..........................................បានក្តីអាម៉ាស់មកវិញ។

- ឃ្លា«ស្តាប់ពាក្យបរិយាយ បណ្តាំមរដី» មានន័យថាកូនចៅ ប្រុស ស្រីគ្រប់រូបត្រូវចេះស្តាប់តាមការទូន្មានប្រៀនប្រដៅ អប់រំណែនាំរបស់ឪពុកម្តាយ ជីដូនជីតា ចាស់ព្រឹទ្ធាចារ្យ គ្រូអាចារ្យ ព្រោះលោកតែងណែនាំយើងឱ្យដើរក្នុងផ្លូវល្អ ឱ្យមានភាពរុងរឿង។ បើយើងអនុវត្តតាមការណែនាំទាំងនោះ យើងនឹងមានក្តីសុខចម្រើន...។

**ឧទាហរណ៍៖** រឿង កុលាប៉ៃលិន៖ ចៅចិត្រស្តាប់តាមការណែនាំតាមពាក្យទូន្មានរបស់ឪពុកខ្លួន...............................មានការងារ មានគេស្រឡាញ់រាប់អាន មានទ្រព្យ មានសេចក្តីសុខ។

*រឿង ចង្កឹះមួយបាច់៖ កូនទាំងបីរបស់កសិករបានធ្វើតាមការណែនាំរបស់ឪពុកខ្លួន........................................មានជីវភាពធូរធារ។*

- ***សរុបសេចក្ដី៖ សរុបនូវអ្វីដែលយើងបកស្រាយ***

***គ. សេចក្ដីបញ្ចប់***

- *វាយតម្លៃប្រធាន៖ ..............................មានអត្ថន័យល្អ ផ្ដល់តម្លៃអប់រំ*

  *..........................................................................................។*
- *មតិផ្ទាល់ខ្លួន៖ដូចនេះ......................................................។*

***ប្រធានទី៤៖*** *មានទស្សនៈមួយពោលថា៖"ការធ្វើពាហិរទាន និងអជ្ឈត្តិកទាន របស់ព្រះពោធិសត្វនៅជាតិទី១០ គឺជាការគាំទ្រឱ្យឧត្តមគតិសាសនា"។ ចូរធ្វើការបកស្រាយ ដោយឧទាហរណ៍បញ្ជាក់។*

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- *លំនាំបញ្ហា៖ យោងតាមការសិក្សាពុទ្ធប្រវត្តិដែលមាននៅក្នុងសៀវភៅទសជាតកទាំងដប់រឿង បានបញ្ជាក់ឱ្យឃើញថា រឿងនីមួយៗសុទ្ធតែបានបង្ហាញពីការសាងនូវបារមី របស់ព្រះពោធិសត្វទាំងអស់ គឺគ្រាន់តែបារមីទាំងនោះមានលក្ខណៈខុសប្លែកៗគ្នាតែប៉ុណ្ណោះ។ រាល់ព្រះពោធិសត្វចាំបាច់ត្រូវតែបំពេញនូវបារមីមួយ ដើម្បីសម្រេចក្នុងការត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ចំណែកឯរឿងព្រះវេស្សន្តរជាតកក៏បានបង្ហាញពីការបំពេញបារមីរបស់តួអង្គព្រះវេស្សន្តរ ក្នុងបំណងសម្រេច នូវការត្រាស់ដឹងនេះដែរ។*
- *ចំណោលបញ្ហា៖ ដោយមើលឃើញពីលក្ខណៈពិសេសក្នុងរឿងទសជាតកបែបនេះហើយ ទើបមានទស្សនៈមួយពោលឡើងថា៖"ការធ្វើពាហិរទាន និងអជ្ឈត្តិកទាន របស់ព្រះពោធិសត្វនៅជាតិទី១០ គឺជាការគាំទ្រឱ្យឧត្តមគតិសាសនា"។*
- *ចំណោទបញ្ហា៖ តើសម្ដីខាងលើនេះបានបង្កប់នូវអត្ថន័យដូចម្ដេចខ្លះ?*

### ខ. តួសេចក្ដី

- *ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ...*

- ពន្យល់ពាក្យគន្លឹះ៖ ពាហិរទានមានន័យថា ទានក្រៅខ្លួន។ អជ្ឈត្តិកទានមានន័យថា ទានក្នុងខ្លួន។ ឧត្តមគតិសាសនាមានន័យថា គំនិតប្រសើររបស់សាសនា។
- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះដែលបានពន្យល់រួចទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍ ដូចខាងក្រោម៖
  - ជាការពិតណាស់ ការធ្វើពាហិរទាន និងអជ្ឈត្តិកទានរបស់ព្រះវេស្សន្តរក្នុងជាតិទិ១០ គឺជា៖
    - ✓ ការគាំទ្រឱ្យឧត្តមគតិសាសនារបស់ព្រះពុទ្ធ
    - ✓ ព្រោះវាជាបច្ច័យធ្វើឱ្យព្រះពោធិសត្វរូបនេះឈានទៅរក ការត្រាស់ដឹងដែលអាចកំចាត់កាមកិលេសតណ្ហា ការលោភ ការកើត ការចាស់ ការឈឺ ការស្លាប់ ដើម្បីធ្វើជាយានចម្លងមនុស្សទូទៅតាមរយៈការបំពេញទានបារមីមួយចំនួនដូចជា៖ ធនបរិច្ចាគ បុត្តបរិច្ចាគ ភរិយាបរិច្ចាគ អង្គបរិច្ចាគ និងជីវិតបរិច្ចាគ។

    ជាក់ស្តែងក្នុងរឿងមហាវេស្សន្តរព្រះអង្គបានធ្វើការបរិច្ចាគនូវទានបញ្ចមហាបរិច្ចាគនេះក្នុងគោលបំណងដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធ។ ការបំពេញទានបារមីរបស់ព្រះវេស្សន្តរព្រះអង្គបានបរិច្ចាគ៖

- ❖ ធនបរិច្ចាគៈ លះបង់ទ្រព្យសម្បត្តិដោយព្រះទ័យស្មោះត្រង់ដល់ជនទាំងពួង តាំងពីពេលកើត តាំងពីពេលចេញពីនគរ រហូតត្រឡប់។
- ❖ បុត្តបរិច្ចាគៈ លះបង់កូនឱ្យជូជកព្រាហ្មណ៍ ដោយព្រះទ័យដូចទន្លេពេញប្រៀបដោយទឹកមិនចេះរីងស្ងួត ដោយទឹកព្រះទ័យក្នុងការធ្វើទាន។
- ❖ ទារបរិច្ចាគ (ភរិយាបរិច្ចាគ)៖ លះបង់នាងមទ្រីដែលជាមហេសីឱ្យទៅព្រាហ្មណ៍ចាស់ជរា(ឥន្ទ្រព្រាហ្មណ៍) ដែលព្រះនាងមទ្រីបានពេញព្រះទ័យតាមព្រះអង្គដែរ។
- ❖ អង្គបរិច្ចាគ និងជីវិតបរិច្ចាគៈ ទោះបីព្រះអង្គមិនទាន់បំពេញក៏ពិតមែន តែព្រះអង្គក៏បានប្រកាស កាលពីព្រះជន្ម៨វស្សាថា ព្រះអង្គនឹងលះបង់ ហើយត្រៀមព្រះកាយ ដើម្បីបំពេញនៅពេលមាននរណាម្នាក់មកសុំ។

- សរុបសេចក្តី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ខាងលើយ៉ាងក្បោះក្បាយលម្អិតរួចមក សបញ្ជាក់ឱ្យឃើញថា រាល់ទង្វើរបស់ព្រះវេស្សន្តរដែលបានបំពេញនូវទានបារមី ដែលរួមមានពាហិរទាន និងអជ្ឈត្តិកទានក្នុងជាតិទី១០នៃរឿងមហាព្រះវេស្សន្តរជាតកនេះពិតជាបានចូលរួមជ្រោមជ្រែង និងទ្រទ្រង់គាំទ្រនូវឧត្តមគតិសាសនារបស់ព្រះពុទ្ធពិតប្រាកដមែន។

**គ. សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាម ការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើពិតជាផ្តល់តម្លៃអប់រំយ៉ាងជ្រាលជ្រៅដល់សាធុជនទាំងឡាយឱ្យចេះចែករំលែកនូវសេចក្តីសុខទាំងឡាយដែលខ្លួនមានសម្រាប់អ្នកដែលមានទុក្ខ តាមរយៈការផ្តល់នូវទាន ហើយគំនិតប្រធានក៏បានបណ្តុះទឹកចិត្តនរជនគ្រប់រូប ឱ្យចេះធ្វើអ្វីៗ ដើម្បីប្រយោជន៍ដល់មនុស្សទូទៅ។
- ទស្សនៈផ្ទាល់ខ្លួន៖ ក្នុងនាមយើង ជាពលរដ្ឋខ្មែរ ត្រូវតែហ៊ានលះបង់ផលប្រយោជន៍ខ្លួន សេចក្តីសុខផ្ទាល់ខ្លួន និងចេះចែកចាយនូវធនធានខ្លះៗ ដែលខ្លួនមានដើម្បីជួយដល់អ្នកដែលស្រេកឃ្លានក្រខ្សត់ ក្នុងបំណងបាននូវប្រយោជន៍ដ៏ប្រពៃសម្រាប់មនុស្សទូទៅនៅក្នុងសង្គមជាតិ។

***ប្រធានទី៥៖*** *ទស្សនៈវិទូមួយបានលើកឡើងថា៖«ជីវិត គឺជាការតស៊ូ»។ តើក្នុងការរស់នៅ របស់មនុស្សយើងចាំបាច់តស៊ូ នឹងអ្វីខ្លះដើម្បីសុខៈនោះ? ចូរបង្ហាញ ដោយលើកឧទាហរណ៍បញ្ជាក់ឱ្យបានក្បោះក្បាយ។*

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សយើងម្នាក់ៗ ដែលកើតមកនៅលើលោកសន្និវាសយើងនេះ តែងតែជួបប្រទះ ឬប្រឈមមុខទៅនឹងបញ្ហានៃសេចក្តីទុក្ខវេទនាគ្រប់បែបយ៉ាង ដែលវាជាវិបត្តិដ៏ស្មុគស្មាញជំពាក់វាក់វិន ពិបាកនឹងដោះស្រាយឱ្យដាច់ស្រឡះបានឡើយ។ ក្នុងករណីនេះទាមទារឱ្យមនុស្សយើងត្រូវចេះតស៊ូ តតាំងនឹងឧបសគ្គទាំងនោះទើបខ្លួនអាចនឹងទទួលបាន នូវសេចក្តីសុខសាន្ត។
- ចំណូលបញ្ហា៖ អាស្រ័យដោយឃើញពីលក្ខណៈបែបនេះហើយទើបមានទស្សនៈមួយពោលឡើងថា៖«ជីវិត គឺជាការតស៊ូ» ទុកដើម្បីជាគតិសម្រាប់ឱ្យយើងសិក្សាពិចារណា។
- ចំណោទបញ្ហា៖ តើយើងត្រូវមានការតស៊ូ ក្នុងជីវិតដូចម្តេចខ្លះដើម្បីឱ្យការរស់នៅ របស់យើងប្រកបដោយភាពសុខសាន្ត?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធានខាងលើឱ្យមានភាពស៊ីជម្រៅកាន់តែល្អនោះយើងគប្បីស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ពាក្យជីវិត មានន័យថាដំណើរនៃការរស់នៅ។ ឯពាក្យការតស៊ូ មានន័យថាការខិតខំប្រឹងប្រែង។
- ពន្យល់ន័យប្រធាន៖ ដូចនេះទស្សនៈរបស់ប្រធានមានន័យថារឿងដំណើរនៃការរស់នៅ គឺជាការខិតខំប្រឹងប្រែងនឹងអ្វីៗគ្រប់យ៉ាង។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការពិតណាស់ភាពជាមនុស្ស ដែលរស់នៅក្នុងសង្គម អាចនឹងទទួលបាននូវកិត្តិយស ទ្រព្យសម្បត្តិ ចំណេះវិជ្ជា រួមទាំងអ្វីៗគ្រប់យ៉ាងជាច្រើនទៀត ប៉ុន្តែទម្រាំតែបាននូវអ្វីៗទាំងអស់នេះលុះត្រា តែយើងម្នាក់ៗធ្វើការ ប្រឆាំងនឹងអំពើបាបរបស់ខ្លួន ដែលចាំតែអូសទាញទៅរកសេចក្តីអាក្រក់ ប្រឆាំងនឹងគំនាបបុគ្គល គំនាបធម្មជាតិ គំនាបសង្គម ដោយខំតស៊ូតទៅលើ៖
    - ➢ តស៊ូជម្នះខ្លួនឯងដោយ ទប់ចិត្តយកឈ្នះលោភៈ ទោសៈ មោហៈ ត្រូវខំរៀន ខំធ្វើការ
    - ➢ តស៊ូនឹងគំនាបបុគ្គល ដោយរើបម្រះរំដោះខ្លួន ពីការជិះជាន់នៃជនអាក្រក់ ចេះទាមទាររកយុត្តិធម៌
    - ➢ តស៊ូនឹងគំនាបសង្គម ដោយប្រឹងប្រែងអប់រំគ្នា លុបបំបាត់ទស្សនៈចាស់គំរិល ប្រពៃណីចាស់ៗ
    - ➢ តស៊ូប្រឹងប្រែងក្នុង ការទាញយកប្រយោជន៍ពីធម្មជាតិ កែច្នៃធម្មជាតិជាសម្ភារ ខំស្រាវជ្រាវរកថ្នាំ

➢ តស៊ូជម្នះឧបសគ្គដែលនៅចំពោះមុខមិនរាថយទោះបី លំបាកយ៉ាងណា...យើងមិនបោះបង់ចោលកិច្ចការ ហើយខិតខំប្រឹងជម្នះនោះនឹងសម្រេចតាមបំណង។

**ឧទាហរណ៍**

- រឿងទុំទាវ ទុំ និងទាវតស៊ូរួមគ្នាជំទាស់គំនាបរបស់ម្តាយ គំនាបប្រពៃណី ទស្សនៈចាស់គំរិល។
- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ សមតស៊ូ នឹងការ ដាច់ពោះស្លាប់ តស៊ូធ្វើជាកសិករថ្មីលើដីកេររបស់ខ្លួន។
- រឿង ភូមិតិរច្ឆាន អ្នកភូមិក្រាំងលាវ មានជួន នៅ នាងនី នាងប៊ីបានខិតខំតស៊ូរើបំរះនៃការគ្រប់គ្រងរបស់នឹម អាណានិគមនិយមបារាំងរហូតដល់បានទទួលការយក ចិត្តទុកដាក់ពីថ្នាក់លើ។

- សរុបមតិ៖ សរុបសេចក្តីមកក្រោយពីបានធ្វើ ការបកស្រាយ បញ្ជាក់ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថានៅ ក្នុងជីវិតមនុស្សយើងគ្រប់រូប គឺត្រូវតែតស៊ូ យកឈ្នះលើចិត្តបាប ចេះកំចាត់ជនអាក្រក់ដែលតែងតែយាយីយើង ហើយត្រូវរួមគ្នាកែ ប្រែភាពអន់ថយដែលមានក្នុងសង្គម និងចូលរួមកែច្នៃចម្មជាតិឱ្យ មានប្រយោជន៍ទើបសមជាមនុស្សមានតម្លៃនៅក្នុងសង្គម។

**គ. បញ្ចប់សេចក្តី**

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបក ស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើនេះពិតជា ផ្តល់តម្លៃអប់រំ ដល់មនុស្សយើងឱ្យស្គាល់ខ្លួនឯង ឱ្យកាន់តែច្បាស់

ដោយបានបណ្តុះគំនិត ក្នុងការតស៊ូក្នុងឆាកជីវិតឆ្ពោះទៅរកភាពជោគជ័យ ដែលពោរពេញទៅដោយសុភមង្គលជានិរន្តរ៍តរៀងរហូតទៅ។

- ទស្សនៈផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែតស៊ូខិតខំរៀនសូត្រឱ្យបានជ្រៅជ្រះដើម្បីក្លាយជាមនុស្សប្រកបដោយធនធាន ហើយក៏ត្រូវតស៊ូក្នុងការចូលរួម កសាងស្ថាបនា សង្គមជាតិទាំងមូលឱ្យរីកចម្រើនសម្រេចដូចអារ្យប្រទេស។

**ប្រធានទី៦៖** គេថា៖«រាល់ទង្វើដោយកង្វះពិចារណា ធ្វើឱ្យបាត់បង់សារប្រយោជន៍ បាត់បង់កិត្តិយស បាត់បង់អាយុជីវិត»។ ចូរបកស្រាយដោយលើកឧទាហរណ៍ពីក្នុងសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍ថ្នាក់ទី១២ដែលអ្នកបានសិក្សារួចមកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ ជាទូទៅយើងតែងសង្កេតឃើញថាបុគ្គលគ្រប់រូបមិនថាចាស់ក្មេង អ្នកធំអ្នកតូច ព្រះសង្ឃ ឬគ្រហស្ថទេ ប្រសិនបើអ្នកទាំងនោះធ្វើនូវសកម្មភាពផ្សេងៗ ដែលពុំរិះគិតឱ្យបានល្អិតល្អន់ គឺធ្វើតែតាមការនឹកឃើញ តាមកំហឹងចិត្តពុះពាររបស់ខ្លួន នោះនឹងធ្វើឱ្យពួកគេជួបប្រទះផលវិបាកធ្ងន់ធ្ងរជាច្រើន។ ផលវិបាកនោះ គឺអាចធ្វើឱ្យរលាយអស់រលីង នូវវត្ថុជាទីគាប់ចិត្តអាប់ឱនបុណ្យសក្តិតួនាទី រហូតឈានដល់សេចក្តីអន្តរាយអាយុជីវិតថែមទៀតផង។
- ចំណូលបញ្ហា៖ ក្នុងន័យបែបនេះហើយ មានទស្សនៈមួយលើកឡើងថា៖«រាល់ទង្វើដោយ កង្វះពិចារណា ធ្វើឱ្យបាត់បង់សារប្រយោជន៍ បាត់បង់កិត្តិយស បាត់បង់អាយុជីវិត»។
- ចំណោទបញ្ហា៖ តើទស្សនៈនេះបង្កប់នូវអត្ថន័យដូចម្តេចខ្លះ? តើក្នុងសង្គមប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មានចំណុចណាខ្លះបញ្ជាក់?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ

យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ទង្វើកង្វះពិចារណា ការធ្វើដោយគ្មានគិតមុខគិតក្រោយឱ្យល្អិតល្អន់។ សារប្រយោជន៍ មានន័យថាប្រយោជន៍សំខាន់។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថា រាល់ការធ្វើដោយគ្មានគិតមុខគិតក្រោយ ឱ្យល្អិតល្អន់ ធ្វើឱ្យបាត់បង់ប្រយោជន៍សំខាន់ បាត់បង់កិត្តិយស បាត់បង់អាយុជីវិត។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
    - ❖ ជាតថភាពជាក់ស្តែង យើងឃើញថាការគិតពិចារណារបស់មនុស្សម្នាក់ៗវាតែងតែហុចផលឱ្យជាបែបបទលក្ខណៈនៃគំនិត ប៉ុន្តែបើយើងម្នាក់ៗមានការប្រមាថលើបញ្ហានេះ ដោយធ្វើអ្វីមួយមិនបានឆ្លងកាត់ ការគិតពិចារណាឱ្យល្អិតល្អន់ទេនោះៗភាពវិនាសអន្តរាយច្បាស់ជាកើតមានឡើងជាប្រាកដ។
    - ❖ រូបភាពនៃទង្វើខ្វះការពិចារណាដូចជា៖ ការរំលោភសិទ្ធិអ្នកដទៃ បំប៉ោងអំណាចឱ្យគេខ្លបខ្លាច ចង់បានប្រយោជន៍តែខ្លួនស៊ូបំផ្លាញអ្នកដទៃតាមវិធីដែលអាចធ្វើបាន ការជឿតាមការញុះញុងមិនស្វែងរកការពិត ធ្វើការទៅតាមតែការបញ្ជាគ្មានគោលដៅច្បាស់លាស់ជាដើម។

- ❖ ចំណុចទាំងនេះកើតឡើងដោយអសមត្ថភាព គ្មានការគិត គ្មានចំណេះដឹង។
- ❖ លទ្ធផលគឺនាំឱ្យវិនាសអន្តរាយខូចប្រយោជន៍មិនសម្រេច តាមបំណងជាក់ជាមិនខាន។
- ❖ ទន្ទឹមនឹងការយល់ឃើញបែបនេះ យើងក៏មានហេតុផល តាមរយៈសង្គមប្រវត្តិដូចជា៖

**បកស្រាយផ្អែកលើសង្គមប្រវត្តិសាស្ត្រ**

- ➢ ពួកជ្រុលនិយមប៉ុលពត(បង្កវិនាសកម្មលើជាតិសាសន៍ឯង ខ្វះការពិចារណា ដោយចង់បំបាត់នូវអ្វីដែលជាកម្មសិទ្ធិ ដើម្បីឱ្យមានភាពស្មើគ្នារវាងអ្នកមាន និងអ្នកក្របណ្តេញរាស្ត្រពីក្រុងទៅស្រែ... ទីបំផុតត្រូវវិនាសបាត់បង់កេរ្តិ៍ឈ្មោះ ស្លាប់)។
- ➢ ពួកហ្វាស៊ីស ហ៊ីត្លែ អាល្លឺម៉ង់(ចចើងបង្អួតឫទ្ធិបង្កាត់ភ្លើងសង្គ្រាមសកលលោកឱ្យឆេះសន្ធោសន្ធៅ ដោយពុំគិតពីសុខទុក្ខរាស្ត្ររាប់សិបលាននាក់ បង្កឱ្យមានការហិនហោចសម្បត្តិស្នាដៃមនុស្ស។ គេចង់ក្តោបក្តាប់ត្រួតត្រាពិភពលោក ធ្វើឱ្យពិភពលោកព្រឺស្មើបញ្ជាក់សាច់ កាលណាឮឈ្មោះពួកគេ។ ប៉ុន្តែបំណងរបស់អាល្លឺម៉ង់នេះត្រូវរលាយជាផេះ ជាតិខ្លួនត្រូវគ្រាំគ្រាសកលលោកថ្កោលទោស មេដឹកនាំព្រៃត្រូវអន្តរាយជីវិតយ៉ាងទាន់ហន់“សាបព្រោះខ្យល់ បានព្យុះសង្ឃរា”)

**បកស្រាយផ្អែកលើអក្សរសិល្ប៍**

- ➢ រឿងព្រះអាទិត្យថ្មី(ថៅកែហុក រំលោភប្រពន្ធសម...) (ឧកញ៉ាសម្បូរសម្បត្តិ ពេលសមយកទ្រព្យសម្បត្តិទៅឱ្យវិញបានចោទសមប្តឹងចាប់ដាក់គុក... ត្រូវគេរិះគន់ខូចកិត្តិយស) (តំណាងរាស្ត្រយ៉េង មាក់ងាយល្មើសគុណសម...ខូចកិត្តិយស) (សម សងសឹកថៅកែហុក ឆក់កាបូបគេ ជឿការឃោសនាគេខ្វះការពិចារណា... ទទួលទណ្ឌកម្មពីបុគ្គលពាល)។
- ➢ រឿងភូមិតិរច្ឆាន ដោយមិនបានគិតឱ្យគ្រប់ជ្រុងជ្រោងនៃក្រុមបាតុករចេះតែធ្វើតាមការបញ្ជា គ្មានផែនការនិងធនធានគ្រប់គ្រាន់...ធ្វើឱ្យក្រុមបាតុករជួន និងនៅត្រូវគេចាប់ដាក់គុកបាន។
- ➢ រឿងថៅកែចិត្តចោរ(ពូហំ លង់ខ្លួនព្រមធ្វើតាមថៅកែចិត្តចោរខ្វះការពិចារណា... ប្រាក់ក៏បង់ផង់ដីដាចសាច់ពុំបានស៊ី យកឆ្អឹងព្យួរក លុយក៏មិនបាន ខ្លួនក៏ជាប់គុក)

- សរុបសេចក្តី៖ សរុបសេចក្តីមកយោងតាមការបកស្រាយបង្ហាញខាងលើ សបញ្ជាក់ឱ្យឃើញថាមនុស្សដែលចូលចិត្តដើរបង្កសង្គ្រាមជម្លោះរំខានសុភមង្គលអ្នកដទៃ ធ្វើទុក្ខបុកម្នេញលើអ្នកទន់ខ្សោយ ដោយអំណាចក្បត់នូវពាក្យសន្យាប្រកាន់ជំនឿអ្វីមួយឥតថ្លឹងថ្លែង យើងកំណត់បានថាជាទង្វើកង្វះពិចារណា។ កាលណាមនុស្សប្រព្រឹត្តបែបនេះ នឹងធ្វើឱ្យពួកគេត្រូវវលាយអស់ នូវទ្រព្យធន បុណ្យសក្តិ អាស្រូវកេរ្តិ៍ឈ្មោះ ស្លាប់ទាំងខ្លួនទៀតផង។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈ របស់ប្រធានខាងលើពិតជាផ្តល់តម្លៃអប់រំយ៉ាងល្អជ្រាលជ្រៅ ព្រោះបានរួមចំណែកផ្តល់ជាគតិដល់ជនគ្រប់រូបឱ្យមើលឃើញអំពីផលអាក្រក់ដែលកើតចេញពីសកម្មភាពព្រៃផ្សៃរំលោភបំពានសិទ្ធិមនុស្ស ដោយឥតគិតត្រិះរិះឱ្យបានវែងឆ្ងាយ។ ផ្តើមចេញពីនេះនរជនទាំងឡាយ បើមុននឹងធ្វើអំពើអ្វីមួយនោះ គោងគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវចេះ ពិចារណាប្រកបដោយគតិបណ្ឌិត ក្នុងការប្រព្រឹត្តអ្វីមួយដើម្បីកាត់បន្ថយនូវគុណវិបត្តិទាំងឡាយ ដែលនឹងកើតមាន បន្ទាប់អំពីយើងបានប្រព្រឹត្តរួច។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី៧៖** មានមតិមួយបានលើកឡើងថា៖ «ស្រ្តីបង្វិលជើងក្រានមិនជុំ»។ ចំពោះអ្នកវិញ តើយល់យ៉ាងណាដែរ? ចូរពិភាក្សា ដោយផ្សារភ្ជាប់នូវអំណោះអំណាងផង។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- *លំនាំបញ្ហា៖* នៅក្នុងសង្គមដែលយើងរស់នៅសព្វថ្ងៃនេះ យើងឃើញថាក្នុងសង្គមគ្រួសារនីមួយៗពិតជាមានស្ត្រីភាគច្រើន គឺជាមេផ្ទះដែលពួកគាត់អាចមានតួនាទីក្នុងការបំពេញ នូវកិច្ចការអ្វីៗធំដុំឱ្យដូចជាបុរសទូទៅបានសោះឡើយ។
- *ចំណូលបញ្ហា៖* អាស្រ័យដោយមានលំនាំបែបនេះហើយ ទើបមានទស្សនៈមតិខ្លះបានលើកឡើងថា៖ «ស្ត្រីបង្វិលជើងក្រានមិនជុំ»
- *ចំណោទបញ្ហា៖* តើទស្សនៈមតិដែលបានពោលខាងលើនេះត្រឹមត្រូវឬទេ?

### ខ. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖* ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
- *ពន្យល់ពាក្យគន្លឹះ៖* បង្វិលចង្ក្រានមិនជុំ មានន័យថាវិលវល់តែកិច្ចការក្នុងចង្ក្រានបាយ កិច្ចការកំប៉ិកកំប៉ុកក្នុងផ្ទះ មិនអាចជួយកិច្ចការសង្គមបាន។

- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថា ស្ត្រីមួយថ្ងៃៗ គឺវិលវល់តែកិច្ចការក្នុងចង្ក្រានបាយដែលជាកិច្ចការកំប៉ិកកំប៉ុកក្នុងផ្ទះហើយមិនអាចជួយកិច្ចការសង្គមបាន។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម

១. មតិស្រប៖ (ស្ត្រីបង្វិលជើងក្រានមិនជុំ)

❖ ជាការពិតណាស់ស្ត្រី គឺជាមនុស្សដែលមិនមានលទ្ធភាពធ្វើអ្វីៗបានដូចជាបុរសនោះទេ ព្រោះស្ត្រីជាភេទទន់ខ្សោយ គ្មានកម្លាំងកំហែងអាចកាន់កិច្ចការជាដុំកំភួនបានឡើយ។ នៅពេលមានគ្រោះអាសន្នកើតឡើង ស្ត្រីចាំបាច់ត្រូវពឹងពាក់បុរសដោយខ្វះមិនបាន។ បើគ្រួសារណាដែលមានបុរស ជាអ្នកដឹកនាំ ជាអ្នកជួយទំនុកបម្រុងរ៉ាប់រងគ្រប់កិច្ចការទាំងអស់នោះៗគ្រួសារនោះច្បាស់ជាមាននូវសេចក្តីសុខសុភមង្គលជាក់ជាមិនខាន។ ពំនោលដែលថា៖ «ស្ត្រីបង្វិលចង្ក្រានមិនជុំ» ព្រោះគេយល់ថាស្ត្រី៖

- ពុំអាចចេញពីការងារផ្ទះបានឡើយ គឺមួយថ្ងៃៗនៅតែដាំស្ល ផ្គត់ផ្គង់នំចំណីអាហារ បង្អែមចម្អាប ដល់ក្រុមគ្រួសារមិនដែលខកខាន។
- គ្រប់គ្រងបានតែការងារតូចតាចដូចជាមើលថែកូនបោកសម្លៀកបំពាក់ ជូតសម្អាតផ្ទះសម្បែង ទទួលភ្ញៀវពន្លឺជិតឆ្ងាយ...។

- ពុំមានលទ្ធភាពរៀនសូត្រឱ្យមានចំណេះដឹងឱ្យដូចបុរសបាន មានគំនិតសុញទាល់មុជមិនជ្រៅ ទៅមិនឆ្ងាយ...។
- ពុំមានលទ្ធភាពគ្រប់គ្រងការងារធំដុំ ឱ្យដូចបុរសបាន ដូចជាជំនួញ វិនិយោគបណ្តាក់ទុនរកស៊ីផ្សេងៗ...។
- នៅតែផ្ទះចាំតែ កម្លាំងប្តីគ្រប់បែបយ៉ាង...។
- មានកម្លាំងទន់ខ្សោយមិនអាចធ្វើការធ្ងន់បាន...។
- ..........................................................................។

**ឧទាហរណ៍**

**ក្នុងសង្គម៖**

- ស្ត្រីមិនអាចលីសែង ឬជញ្ជូនឥដ្ឋធ្វើអគារខ្ពស់កប់ពពកបានទេ។

**ក្នុងអក្សរសិល្ប៍៖**

- រឿងព្រះអាទិត្យថ្មី(នាងសយប្រពន្ធសម ជាស្ត្រីខ្វះចំណេះដឹង រស់នៅពឹងកម្លាំង មុជមិនជ្រៅ នៅតែចង្ក្រាន...)
- រឿងគូលីកំនែន(យាយចាន់ នាងវ៉ែន ជាស្ត្រីសង្គមមិនឱ្យតម្លៃ គិតតែពីទាក់ប្រុស ដឹកញីបន្សុីឈ្មោល...)
- រឿងភូមិតិរច្ឆាន(នាងតន់ប្រពន្ធសុវណ្ណ ពុំបានជួយបញ្ហាសង្គម ធ្វើការកំប៉ិកកំប៉ុក មើលថែកូនសុវណ្ណ...)
  - ⇨ សរុបមតិស្រប៖ សរុបសេចក្តីមក ឃើញថាការបកស្រាយខាងលើពិតជាបង្ហាញថា ស្ត្រីពិតជាមុជមិនជ្រៅ ទៅមិនឆ្ងាយមែន គឺបានត្រឹមតែកិច្ចការតូចតាច កំប៉ិកកំប៉ុក ចង្ក្រានជើងឆ្នាំង តុបតែងខ្លួនបង្អួតប្តីបង្អួត

អ្នកដទៃ និងមើលថែកូនផ្ទះសម្បែងតែប៉ុណ្ណោះ។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

❋ *សំណួរភ្ជាប់សេចក្តី៖ តើស្ត្រីពិតជាបង្វិលចង្ក្រានមិនជុំឬ?*

២. មតិផ្ទុយ៖ ទោះបីជាមជ្ឈដ្ឋានខាងលើខំធ្វើការអះអាងជាមួយនឹងភស្តុតាងយ៉ាងជាក់ស្តែងគួរឱ្យស្តាប់បានយ៉ាងណា ក៏ដោយក៏គេនៅតែឃើញមានមតិមួយចំនួនទៀត ដែលមិនយល់ស្របតាមគំនិតខាងលើនេះ ទាំងស្រុងនោះដែរ ព្រោះស្ត្រីពិតជាអាចបំពេញកិច្ចការធំដុំបានដូចបុរស៖

- ស្ត្រី ជាអ្នករ៉ាប់រងការងារនានាពេលប្តីអវត្តមាន...។
- ស្ត្រី ជាអ្នករួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស...។
- ស្ត្រី ជាវេជ្ជបណ្ឌិតដ៏ពូកែ...។
- ស្ត្រីជាដៃគូដ៏សំខាន់ជាមួយបុរស...។
- ស្ត្រីជាមាតានៃពិភពលោក...ខ្វះស្ត្រីមិនបាន។
- ស្ត្រី ជាអ្នកអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យរីកចម្រើន...។
- ស្ត្រី ជានិយោជក ជានាយិកា ជាមេឃុំ ជាសមាជិករាជរដ្ឋាភិបាល តំណាងរាស្ត្រ...។

**ឧទាហរណ៍**

**ក្នុងសង្គម៖**

- តួនាទីស្ត្រីក្នុងជួរក្រសួងសុខាភិបាល លោកស្រី ឱ វណ្ណីន...។

**ក្នុងប្រវត្តិសាស្ត្រ**

- ប្រវត្តិសាស្ត្រ(ព្រះនាងលីវយី ដឹកនាំប្រទេស...) (ព្រះនាងឥន្រ្ទទេវី ជាមុក្ខទេ្ទសង័ឆ្នើមនៃព្រះបាទជ័យវរ្ម័នទី៧)

**ក្នុងអក្សរសិល្ប៍**

- រឿងគូលីកំណៃាន(អ្នកគ្រូគូ រស់ បណ្តុះធនធានមនុស្ស...)
- រឿងភូមិតិរច្ឆាន(នាងនី នាងបី បានជួយវិបត្តិសង្គម...)
- រឿងតេជោយ៉ត(ជំទាវស្រែន ជួយកំចាត់ជនក្បត់ជាតិ...)។
  - ⇨ សរុបមតិផ្ទុយ៖ សរុបសេចក្តីមកឃើញថាស្ត្រីពិតជាអាចធ្វើការធំដុំដូចបុរសពិតប្រាកដមែន។ ការយល់បែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- ពិភាក្សាមតិ៖ ជារួមមកយើងឃើញថា ការបកស្រាយបង្ហាញខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្មតបានថាមតិទីមួយដែលបានលើកឡើង ហាក់ដូចជាបានបន្ទាបបន្ថោកស្ត្រីជ្រុលហួសហេតុពេក ព្រោះស្ត្រីពុំសុទ្ធតែជាមនុស្សឥតបានការ ល្ងង់ខ្វះសមត្ថភាពដូចមតិទីមួយថានោះទេ។ ឯមតិទីពីរវិញមានន័យត្រឹមត្រូវ យល់បានទូលំទូលាយ ហើយបានធ្វើការស្រាវជ្រាវឱ្យឃើញថា មានការងារខ្លះបុរសធ្វើមិនបាន តែស្ត្រីអាចធ្វើបាន។ ការងារផ្ទះស្រាលតែសំខាន់បើគ្មានស្ត្រីរ៉ាប់រងបុរសពុំអាចសម្រេចវាបានទេ។

**គ. សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយបង្ហាញខាងលើ អាចសបញ្ជាក់ឱ្យឃើញថា ទស្សនៈរបស់ប្រធានខាងលើដែលបានលើកឡើងជាមតិដែលពុំត្រឹមត្រូវនោះ

ទេ។ ឯមតិទីពីរវិញជាមតិដែលត្រឹមត្រូវ ព្រោះបានបកស្រាយយ៉ាងច្បាស់ គ្មានស្រពិចស្រពិលសោះឡើយ ដែលទាក់ទងទៅនឹងតម្លៃរបស់ស្ត្រី នៅក្នុងសង្គមគ្រួសារ ក៏ដូចជានៅក្នុងសង្គមជាតិទាំងមូល។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវចេះឱ្យតម្លៃស្ត្រី លើកតម្កើងស្ត្រី ស្រឡាញ់គោរពស្ត្រី គ្រប់កាលៈទេសៈទាំងអស់ ពីព្រោះស្ត្រី គឺជាមាតានៃពិភពលោកទាំងមូល។
- ពាក្យស្លោក ឬសុភាសិត

***ប្រធានទី៨៖*** *តើរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់បានរួមចំណែកដោះស្រាយបញ្ហាសង្គមដូចម្តេចខ្លះ? ចូរពន្យល់ឱ្យបានក្បោះក្បាយដោយលើកយកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។*

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- *លំនាំបញ្ហា៖ រាល់ស្នាដៃអក្សរសិល្ប៍សុទ្ធតែបានលើកយកនូវបញ្ហាដ៏ស្មុគស្មាញ របស់មនុស្សនៅក្នុងសង្គមមកចោទ និងដោះស្រាយ។ អក្សរសិល្ប៍បានបង្ហាញពីមូលហេតុ នៃបញ្ហាដែលមានចោទឡើងក្នុងសង្គមផង ហើយជាមួយគ្នានោះវាក៏បានបង្ហាញពីវិធីដោះស្រាយទាំងនោះ យ៉ាងសមរម្យទៀតផង គឺដោះស្រាយទៅតាមឧត្តមគតិរបស់អ្នកនិពន្ធ។ ចំណែករឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់របស់លោកស្ងួន សុរិន្ទ ក៏បានរួមចំណែកក្នុងការដោះស្រាយបញ្ហាក្នុងសង្គមខ្មែរបានមួយចំនួនដែរ។*
- *ចំណូលបញ្ហា៖ ដោយហេតុនេះហើយ ទើបមានទស្សនៈរបស់ប្រធានតម្រូវឱ្យយើងធ្វើការបកស្រាយបង្ហាញអំពីការរួមចំណែកដោះស្រាយបញ្ហាសង្គម នៃរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់។*
- *ចំណោទបញ្ហា៖ តើរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ បានរួមចំណែកដោះស្រាយបញ្ហាសង្គមខ្មែរយ៉ាងដូចម្តេចខ្លះ?*

### ខ. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ...*
- *ពន្យល់ពាក្យគន្លឹះ៖ ពាក្យរួមចំណែក មានន័យថារួមជាគំនិតយោបល់។ រីឯពាក្យបញ្ហា មានន័យថាផលកង្វះខាត វិបត្តិផ្សេងៗ។*

- ពន្យល់ន័យប្រធានៈ យកន័យរបស់ពាក្យគន្លឹះដែលបានពន្យល់រួច ទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធានៈ បកស្រាយពិស្តារ រួមផ្សំហេតុផល និង ឧទាហរណ៍ដូចខាងក្រោមៈ
  - ❖ ជាការពិតណាស់ រាល់ស្នាដៃអក្សរសិល្ប៍ ដែលអ្នកនិពន្ធ បានតាក់តែងមកសុទ្ធតែបានបង្ហាញពីបញ្ហាប្រឈម និង វិធីនៃដំណោះស្រាយ ដែលមាននៅក្នុងសង្គមជាក់ស្តែង។
  - ❖ បញ្ហាសង្គមមានមិនចេះចប់មិនថាពីមុន ឬបច្ចុប្បន្ននោះទេ ដែលបញ្ហាកើតឡើងចំពោះសង្គមជាតិទាំងនោះមានដូចជា អសន្តិសុខក្នុងសង្គម ការរាំងស្ងួត ការបោកប្រាស់ ភាព អយុត្តិធម៌ សីលធម៌ ចលនាតស៊ូជាដើម។
  - ❖ នៅពេលលេចចេញជាបញ្ហាគឺតែងតែមានដំណោះស្រាយ មិនថាល្អឬអាក្រក់ទេច្រើនតែមានដំណោះស្រាយ...។
  - ❖ យ៉ាងណាមិញ នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ បានលើកយកបញ្ហា និងដំណោះស្រាយមួយចំនួនដូចជាៈ
    - **បញ្ហាចោទក្នុងសង្គម**
      - ⇨ អសន្តិសុខសង្គម
      - ⇨ ការរាំងស្ងួត
      - ⇨ ជីវិតចាកចេញពីស្រុកកំណើតរបស់សម មករស់នៅ ឯភ្នំពេញ ដែលជួបតែវិបត្តិធ្ងន់ធ្ងរជាប់ជានិច្ច រហូតរស់ នៅភ្នំពេញមិនបាន

⇨ ចំណូលដីច្រើនលើសលប់របស់កសិករ ទៅរស់នៅក្នុងក្រុង បង្កវិបត្តិឥតការងារធ្វើ

⇨ អ្នកនយោបាយបោកប្រាស់(បក្សពួកលោកយ៉េង)។

- **បញ្ហាដំណោះស្រាយ**

⇨ តួអង្គសម តស៊ូក្នុងឆាកជីវិតដើម្បីស្វែងរកសុភមង្គល

⇨ លោករដ្ឋមន្ត្រីវ័យក្មេង ជួយដោះស្រាយបញ្ហាទុក្ខលំបាករបស់ប្រជាជន(ជួយសម ឱ្យមានការងារធ្វើ)

⇨ យកចិត្តទុកដាក់លើនយោបាយទឹក

⇨ កំលាំងភ្ញាក់រឭក បង្កបង្កើនផលកសិកម្ម

⇨ បណ្តុះទឹកចិត្តមន្ត្រីរាជការឱ្យស្រឡាញ់កសិកម្ម

⇨ ជំនួយឧបត្ថម្ភពីរដ្ឋាភិបាល(រកទីផ្សារដល់កសិករ)

⇨ បង្កើតឱ្យមានសមាជជាតិ(សមបានទៅចូលរួម)

- សរុបសេចក្តី៖ សរុបសេចក្តីជារួមមក ក្រោយពីបានធ្វើការបកស្រាយយ៉ាងលម្អិតឃើញថា ទស្សនៈរបស់ប្រធានខាងលើបានរួមចំណែកដោះស្រាយបញ្ហាសង្គមដូចជា ការផ្តល់ជានយោបាយទឹកក្នុងការដោះស្រាយបញ្ហាកសិកម្ម ដែលជាបញ្ហាគន្លឹះចំបងបំផុតក្នុងការកសាងសេដ្ឋកិច្ចកម្ពុជា និងកម្លាំងភ្ញាក់រឭកជឿនលឿនរបស់កសិករផ្ទាល់ គួបផ្សំនឹងកំលាំងជួយឧបត្ថម្ភ របស់រាជរដ្ឋាភិបាល ដែលជាប្រភពនៃសុភមង្គល របស់ប្រជាពលរដ្ឋ និងការរីកចម្រើនថ្កុំថ្កើងនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

**គ. សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ឆ្លងតាមរយៈនៃការបកស្រាយយ៉ាងក្បោះក្បាយរួចរាល់ខាងលើមកនេះ យើងអាចវាយតម្លៃបានថា ប្រធានខាងលើពិតជាបង្កប់ នូវអត្ថន័យខ្លឹមសារល្អយ៉ាងជ្រាលជ្រៅ ព្រោះបានបំផុសស្មារតីភ្ញាក់រឭកដល់ប្រជាកសិករខ្មែរតាមរយៈរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់នេះ ដោយបានរួមចំណែកយ៉ាងសំខាន់ ក្នុងការដោះស្រាយបញ្ហាវិបត្តិ ក្នុងសង្គមខ្មែរទាំងផ្នែកសង្គមកិច្ច នយោបាយ និងផ្នែកសេដ្ឋកិច្ចជាតិ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមខ្ញុំជាកុលបុត្រខ្មែរមួយរូប យល់ឃើញថារឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ពិតជាស្នាដៃមួយ ដែលបានចូលរួមចំណែក ក្នុងការដោះស្រាយបញ្ហា នៃសង្គមខ្មែរយ៉ាងច្រើន ជាពិសេសរាជរដ្ឋាភិបាលដែលដឹកនាំដោយអង្គសម្តេចឪ ហើយខ្ញុំសង្ឃឹមថារាជរដ្ឋាភិបាលសម័យបច្ចុប្បន្ននេះ ដែលបានបន្តវេនដឹកនាំប្រទេសគួរអនុវត្តនយោបាយទឹក ដើម្បីស្តារ និងកសាងសេដ្ឋកិច្ចជាតិ ដែលត្រូវបានប្រជាពលរដ្ឋទូទាំងប្រទេសគាំទ្រ និងចូលរួមយ៉ាងសកម្មបំផុត។
- ពាក្យស្លោក ឬសុភាសិត៖ សមនឹងទស្សនៈមួយបានពោលថា៖«ប្រទេសកម្ពុជា ជាប្រទេសពឹងផ្អែកលើវិស័យ កសិកម្ម»។

**ប្រធានទី៩៖** ក្រោយពីបានសិក្សាអក្សរសិល្ប៍ខ្មែរមួយចំនួន មានមតិខ្លះយល់ថា៖ "ភក្តីភាពមានតម្លៃជាងជីវិត"។ ឯមតិមួយទៀតយល់ថា៖ "ជីវិតមានតម្លៃជាងភក្តីភាព"។ តើមតិទាំងពីរនេះមួយណាត្រឹមត្រូវជាង? ចូរពិភាក្សាដោយលើកយកឧទាហរណ៍ ក្នុងអក្សរសិល្ប៍មកបញ្ជាក់ផង។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សរមែងតែងទទួលឥទ្ធិពលចំពោះការរស់នៅរបស់ពួកគេក្នុងសង្គម។ ជួនកាលរបស់តែមួយ វត្ថុតែមួយ ចំណុចតែមួយ រឿងតែមួយ មានខ្លះយល់បែបនោះ ខ្លះយល់បែបនេះដែលទាក់ទងទៅនឹងការរស់នៅ ចំណេះដឹង កម្រិតវប្បធម៌ និងទិដ្ឋភាពជុំវិញខ្លួន។
- ចំណូលបញ្ហា៖ ដោយសារចំណុចខាងលើនេះហើយទើបមានមតិខ្លះបានលើកឡើងថា៖ "ភក្តីភាពមានតម្លៃជាងជីវិត"។ ឯមតិមួយទៀតយល់ថា៖ "ជីវិតមានតម្លៃជាងភក្តីភាព" សម្រាប់ទុកឱ្យកូនខ្មែរដែលជាអ្នកសិក្សាធ្វើការពិចារណា។
- ចំណោទបញ្ហា៖ តើទស្សនៈមតិទាំងពីរដែលបានពោលខាងលើនេះ មួយណាត្រឹមត្រូវជាងមួយណា?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ នូវទស្សនៈរបស់ប្រធានខាងលើ ជាបឋមយើងគប្បីស្វែងយល់នូវពាក្យគន្លឹះរបស់ប្រធានឱ្យបានច្បាស់ជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ពាក្យភក្តីភាព មានន័យថាភាពស្មោះត្រង់។ រីឯពាក្យជីវិត មានន័យថាដំណើរនៃការរស់នៅ។
- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះ ដែលបានពន្យល់រួច ទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផលនិងអំណះអំណាងបញ្ជាក់ដូចខាងក្រោម៖
  - ❖ ជាការពិតណាស់មនុស្សយើងម្នាក់ៗ ដែលកើតឡើងមកនៅលើលោកសន្និវាសយើងនេះ ត្រូវការចាំបាច់ណាស់នូវភាពស្មោះត្រង់ ភក្តីភាព រវាងគ្នា និងគ្នាជួនកាលមនុស្សយើងរហូតដល់ថ្នាក់ហ៊ានលះបង់ កម្លាំងកាយ វាចា ចិត្ត និងអាយុជីវិតក៏ព្រោះតែភក្តីភាព។

    + មតិស្រប៖ ជាការត្រឹមត្រូវណាស់គេតែងតែឱ្យតម្លៃទៅលើភក្តីភាព ដែលមានតម្លៃប្រសើរជាងជីវិតព្រោះ៖

      - ⇨ មានភក្តីភាពធ្វើឱ្យគេស្រឡាញ់រាប់អានច្រើន ចូលចិត្ត
      - ⇨ មានភក្តីភាពធ្វើឱ្យមានកេរ្តិ៍ឈ្មោះ កិត្តិយស ឋានៈ តួនាទី
      - ⇨ មានភក្តីភាពធ្វើឱ្យមានជីវភាពរីកចម្រើន សុភមង្គល
      - ⇨ មានភក្តីភាពធ្វើឱ្យចំណងសាមគ្គីរឹងមាំ រក្សាបានទំនាក់ទំនងល្អ
      - ⇨ ដោយសារភក្តីភាព គេអាចសុខចិត្តបូជាកម្លាំងកាយ ចិត្ត និងជីវិត

⇨ មានភក្តីភាពនឹងមានសន្តិភាព

⇨ មានភក្តីភាព មានក្តីអាណិត...។

**ឧទាហរណ៍៖**

⇨ រឿងរាមកេរ្តិ៍(ព្រះនាងសីតាមានភក្តីភាពចំពោះព្រះរាម ទោះយក្សចាប់យកទៅក៏ដោយ)

⇨ រឿងទុំទាវ(នាងទាវភក្តីចំពោះទុំ ទោះបីដឹងថាស្តេចអាចនឹងយកទោសដល់ជីវិត)

⇨ រឿងព្រះវេស្សន្តរ ព្រះនាងមទ្រីមានភក្តីភាពបចំពោះព្រះស្វាមីយាងទៅជាមួយព្រះអង្គក្នុងព្រៃ...។

- សរុបមតិស្របៈ សរុបសេក្តីមកឃើញថា ការបកស្រាយបង្ហាញខាងលើ ពិតជាគេឱ្យតម្លៃទៅលើភក្តីភាពជាកត្តាសំខាន់ដែលអាចបញ្ជាក់ពីទំហំនៃមនោសញ្ចេតនាពិតមែន។

✵ **សំណួរភ្ជាប់សេចក្តី៖ តើភក្តីភាពពិតជាមានតម្លៃជាងជីវិតពិតមែនឬ?**

\+ មតិផ្ទុយ៖ ទោះបីជាមជ្ឈដ្ឋានខាងលើខំធ្វើការអះអាងជាមួយនឹងភស្តុតាងយ៉ាងជាក់ស្តែងគួរឱ្យស្តាប់បានយ៉ាងណាក៏ដោយ ក៏គេនៅតែឃើញមានទស្សនៈមួយទៀតបានប្រឆាំងយ៉ាងដាច់អហង្ការដែរ ដោយគេយល់ឃើញថាជីវិតមានតម្លៃជាងភក្តីភាព។មនុស្សគ្រប់រូបបានស្វះស្វែងធ្វើអ្វីគ្រប់យ៉ាងកដោយសារតែចង់រក្សាជីវិតរបស់គេដូចជា៖

⇨ ការប្រឹងប្រែងគ្រប់យ៉ាង គឺដើម្បីរកអ្វីមកចិញ្ចឹមជីវិត...

- ⇨ ខិតខំស្វែងរកចំណេះដឹង ឱ្យបានជ្រៅជ្រះសព្វថ្ងៃក៏ដើម្បីជីវិត
- ⇨ ខិតខំធ្វើការ ចំណាយកម្លាំង កាយចិត្តក៏ព្រោះតែជីវិត
- ⇨ ខិតខំហាត់ប្រាណក៏ព្រោះចង់បានសុខភាពល្អដើម្បីរក្សាជីវិតឱ្យបានយូរអង្វែង
- ⇨ លះបង់ទ្រព្យសម្បត្តិយ៉ាងច្រើនដើម្បីការពារជីវិតពិសេសពេលមានជំងឺ
- ⇨ មានសង្ខារត្រូវមានសង្ឃឹម មេឃស្រឡះក្រោយពេលមេឃភ្លៀងរលឹម
- ⇨ ជួនកាលជីវិតតម្រូវឱ្យធ្វើ នូវអំពើអាក្រក់តែបានល្អ ឬធ្វើល្អបានអាក្រក់(ផ្លូវវៀចកុំបោះបង់ ផ្លូវត្រង់...)

## ឧទាហរណ៍

- ⇨ រឿងរាមកេរ្តិ៍(ពិភេកសុខចិត្តចូលនឹងព្រះរាម ដើម្បីជីវិតប្រសើរ ស៊ូលះបង់ភក្តីភាពរវាងខ្លួន ជាមួយក្រុងរាពណ៍ជាបង។ សុគ្រីព ចុះចូលព្រះរាមក្បត់ពាលីជាបង)។
- ⇨ រឿងថៅកែចិត្តចោរ(ភាពក្រីក្រ បំសុខចិត្តបើកឡានបុកឡានថៅកែហុងលី ដើម្បីជីវិតសុខស្រួល)
- ⇨ រឿងមហាវេស្សន្តរជាតក(តាជូជកដើរសុំទានពីដែនមួយទៅដល់ដែនមួយក៏ព្រោះចិញ្ចឹមជីវិត)។

- ▪ សរុបមតិផ្ទុយ៖ សរុបសេក្តីមកឃើញថា ការបកស្រាយបង្ហាញខាងលើ ពិតជាគេឱ្យតម្លៃទៅលើជីវិត

ជាកត្តាសំខាន់ក្នុងការក្តាប់ឱកាសឆ្ពោះទៅរកភាពជោគជ័យ សម្រាប់នាពេលអនាគត ប្រកបដោយសុភមង្គល។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សំយោគមតិ៖ ជារួមមកយើងឃើញថាការបកស្រាយខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និតបានថាបណ្តាមតិទាំងពីរខាងលើសុទ្ធតែមានអំណះអំណាងសមហេតុផលដូចគ្នាមិនអាចខ្វះមួយណាបានទេ ព្រោះភាពពិតរបស់មនុស្សត្រូវការរក្សាជីវិតប្រកបដោយភក្តីភាព និងគុណធម៌ ជាកត្តាចាំបាច់បំផុត។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មតិរបស់ប្រធានមានន័យត្រឹមត្រូវ ព្រោះតម្លៃនៃជីវិតរបស់មនុស្សស្ថិតនៅលើភក្តីភាព តែបើគ្មានភក្តីភាពជីវិតរបស់មនុស្សម្នាក់ៗក៏គ្មានតម្លៃជាមនុស្សដែរ។ តែទោះបីយ៉ាងណាក៏វិសេសតម្លៃនៃមតិទាំងពីរមាន ភាពលម្អៀងទៅមតិទី២ដែលមានតម្លៃជាអាទិភាពជាងមតិទី១ ព្រោះបើយើងរក្សាព្រៃឱ្យគង់វង្សពិតជាមិនខ្វះឧសដុតនោះទេ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាកុលបុត្រខ្មែរមួយរូប យល់ឃើញថាចំណុចខាងលើនេះអាចធ្វើឱ្យយើងជាបច្ឆាជនជំនាន់ក្រោយប្រមូលយកមកទុកជាគតិអប់រំខ្លួន ឱ្យចេះឱ្យតម្លៃទៅលើជីវិត ដោយមិនត្រូវប្រមាថ ឬកាប់សម្លាប់មនុស្សតាមអំណាច...។

- ***ប្រធានទី១០៖*** *សិក្សារឿងទុំទាវ មានមតិមួយយល់ថា៖«ការទុកដាក់កូនចៅឱ្យមានគូស្រករ គឺអាស្រ័យលើឪពុកម្តាយ ជាអ្នកសម្រេច»។ តើអ្នកយល់យ៉ាងណា? ចូរពិភាក្សាដោយលើកអំណះអំណាងមកបញ្ជាក់។*

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- *លំនាំបញ្ហា៖ ក្រោយពីបានសិក្សារឿងទុំទាវចប់ ដែលស្ថិតក្នុងចលនាអក្សរសិល្ប៍ខេមរនិយម យើងឃើញថារឿងទុំទាវត្រង់វគ្គដែលម្តាយទាវ បានលើកនាងទាវឱ្យទៅកូនឧកញ៉ាអរជូន ក៏បានបង្ហាញពីតួនាទីរបស់អាណាព្យាបាល ក្នុងការកំណត់នូវជោគវាសនាដល់កូនទូទៅ។ ជុំវិញបញ្ហានៃការរើសគូស្រករឱ្យកូនដែលកូនម្នាក់ៗមិនមានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសមនុស្សជាទីស្រឡាញ់ពេញចិត្ត ដោយខ្លួនឯងនោះឡើយ។*
- ចំណូលបញ្ហា៖បែបនេះហើយទើបមានមតិខ្លះបានលើកឡើងថា៖«ការទុកដាក់កូនចៅឱ្យមានគូស្រករ គឺអាស្រ័យលើឪពុកម្តាយជាអ្នកសម្រេច» ដើម្បីទុកជាទស្សនទានឱ្យយើងធ្វើការពិចារណា។
- ចំណោទបញ្ហា៖ តើទស្សនៈមតិដែលបានពោលខាងលើនេះត្រឹមត្រូវឬទេ?

### ខ. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ នូវទស្សនៈរបស់ប្រធានខាងលើ ជាបឋមយើងគប្បីស្វែងយល់នូវពាក្យគន្លឹះរបស់ប្រធានឱ្យបានច្បាស់ជាមុនសិន។*

- ពន្យល់ពាក្យគន្លឹះ៖ ពាក្យការទុកដាក់កូនចៅមានន័យថា ការរៀបចំផ្សំផ្គុំកូនឱ្យមានគូស្រករ។ ចំណែកឯពាក្យអ្នកសម្រេចមានន័យថា អ្នកកំណត់ឱ្យដាក់ស្រេច។
- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះ ដែលបានពន្យល់រួចទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងអំណះអំណាងបញ្ជាក់ដូចខាងក្រោម៖
    - ❖ ជាការពិតណាស់ ខ្មែរយើងតាំងពីបរមបុរាណមក តែងតែប្រកាន់នូវទំនៀមទម្លាប់ប្រពៃណីដ៏ផូរផង់ ដែលបុព្វនៃមហាបុរសខ្មែរបានខិតខំរៀបចំរក្សាយ៉ាងខ្ជាប់ខ្ជួនទុកសម្រាប់កូនចៅជំនាន់ក្រោយ
    - ❖ យើងជាកូនត្រូវធ្វើតាម ម៉ែទុកឪពុកដាក់ឱ្យមានគូស្រករ រៀបការរាបក្បាលដល់កន្ទេល ព្រោះគាត់ គឺជាភ្នែក ជាចម្រុះនៃកូនទូទៅ។
    - ❖ ជួនកាលគ្រួសារខ្លះកូនក្រមុំកូនកំលោះមិនទាំងស្គាល់គ្នាផង
    - ❖ គំនិតចាស់ដែលចាត់ទុកថាខ្លួនជាអ្នកបង្កើតកូនមកត្រូវធ្វើតាមបំណងរបស់ខ្លួន
    - ❖ ចាស់ខ្លះគិតថាកូនចៅមិនទាន់មានបទពិសោធ ខ្លួនមានបទពិសោធយកបទពិសោធទាំងនោះមកចាត់ចែងទុកដាក់កូនចៅ...។

    \+ មតិស្រប៖ ដូចនេះការរៀបចំគូស្រករឱ្យកូន គឺអាស្រ័យលើឪពុកម្តាយជាអ្នកសម្រេចព្រោះ៖

⇨ ឪពុកម្ដាយ ជាអ្នកឱ្យកំណើត ចង់ឱ្យកូនមានទ្រព្យ បុណ្យសក្ដិ កិត្តិយស។

ឧទាហរណ៍៖ ម្ដាយឱ្យទៅកូនចៅហ្វាយស្រុកបានសុខដោយ បុណ្យដោយបានថ្កើង

⇨ បង្ហាញពីតួនាទីឪពុកម្ដាយ ជាអ្នករអារកាត់គ្រប់រឿង

ឧទាហរណ៍៖ មិនដែលសោះឡើយទាវអើយនំ ច្រឡឹសបើស ធំម្ដេចជាងនាឡិ...

⇨ កូនត្រូវរស់ក្រោមសិទ្ធិគ្រប់គ្រងរបស់ឪពុកម្ដាយ។

ឧទាហរណ៍៖ កូនគោកាចក្បៀចដោយព្រៃវាល រោលរាលឈឺ ខ្លួនជូនដល់ស្លាប់...

⇨ ឪពុកម្ដាយអាចនឹងបំផ្លាញកូន បើកូនមិនធ្វើតាម

ឧទាហរណ៍៖ អញផ្ដាច់ពង្រាត់ពីអានេះ មិនមានសន្និះគិត សង្កា កិច្ចកលឧបាយតាមប្រាជ្ញា ផ្ដាច់អាទុំចោរចិត្តទុស្ដក្បត់។

- សរុបមតិស្របៈ សរុបមកឃើញថា មនុស្សយើងម្នាក់ៗត្រូវតែមានគូស្រករគ្រប់ៗគ្នា ដោយត្រូវជ្រើសរើសយកនរណាម្នាក់ អាស្រ័យលើ ឪពុកម្ដាយ ជាអ្នកកំណត់ ព្រោះមិនមានឪពុកម្ដាយណានៅលើលោកយើងនេះមិនចង់ឱ្យកូនមានសុភមង្គលនៅក្នុងសង្គមនោះទេ គឺតែងតែរំពៃរកកូនអ្នកដែលមានទ្រព្យស្ដុកស្ដម្ភឱ្យកូនជានិច្ច ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

❋ *សំណួរភ្ជាប់សេចក្តី៖ តើការរៀបចំកូនចៅឱ្យបានជា ប្តីប្រពន្ធ គឺអាស្រ័យលើឪពុកម្តាយជាអ្នកចាត់ចែងតែម្យ៉ាងឬ?*

+មតិផ្ទុយ៖ ទោះបីមជ្ឈដ្ឋានខាងលើខំធ្វើការអះអាងជាមួយនឹងភ័ស្តុតាងយ៉ាងជាក់ស្តែងគួរឱ្យស្តាប់បានយ៉ាងណាក៏ដោយ ក៏គេនៅតែឃើញមានទស្សនៈមួយទៀតបានប្រឆាំងយ៉ាងដាច់អហង្ការដែរ ដោយគេមិនយល់ស្របគំនិត ខាងលើនេះទាំងស្រុងនោះដែរព្រោះអាចធ្វើឱ្យបែកបាក់គ្រួសារ រស់នៅមិនចុះសម្រុងនឹងគ្នា

⇨ យ៉ាងណាមិញក្នុងរឿងទុំទាវ

⇨ ទាវគ្មានសុភមង្គល កើតទុក្ខព្រួយជូនកាលត្រូវបាត់បង់ជីវិតក៏មាន...

ឧទាហរណ៍៖ ទាវឮម្តាយប្រាប់ចាប់ចាំទុក ស្ទើរធ្លាក់ថ្លើមក្តុកពុំរសាយ...

⇨ ធ្វើឱ្យកូនខ្វះសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ បើជាការល្អគួរសួរហេតុផលពីកូនខ្លះផង...

ឧទាហរណ៍៖ ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី...

⇨ សេចក្តីស្នេហាមិនប្រកាន់វណ្ណៈពណ៌សម្បុរ...

ឧទាហរណ៍៖ (ត្រូវចំណុចម្តាយទាវមើលងាយ ថាទុំជាមនុស្សខ្វាត់ព្រាត់...)

⇨ សុភមង្គល គឺមិនស្ថិតនៅលើបុណ្យសក្តិមាសប្រាក់ទេ

ឧទាហរណ៍៖ (ត្រង់ចំណុចនាងទាវ ប្រកែកមិនព្រមយកម៉ឺនងួន ស្ដេចរាមា...)

- សរុបមតិផ្ទុយ៖ សរុបសេចក្ដីមកឃើញថា ការបកស្រាយបង្ហាញខាងលើ ពិតជាគេឱ្យតម្លៃទៅលើជីវិត គូស្រករណាដែលមានសុភមង្គលហើយដោយយល់ព្រមពីសំណាក់ឪពុកម្ដាយផង និងពីសំណាក់សាមីខ្លួនផង ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សំយោគមតិ៖ ជារួមមកយើងឃើញថាការបកស្រាយខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និដ្ឋានបានថាជុំវិញបញ្ហាការជ្រើសរើសគូស្រករឱ្យកូនត្រូវមានការយល់ព្រមពីឪពុកម្ដាយផង ពីកូនផងទើបល្អ ព្រោះដើម្បីឱ្យកូនមានសិទ្ធិក្នុងការកំណត់ នូវជោគវាសនារបស់ខ្លួន ហើយម្យ៉ាងទៀត ឪពុកម្ដាយក៏មិនអាចនៅមើលថែកូនខ្លួនជារៀងរហូតដែរ។

### គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់យើងឃើញថាមតិរបស់ប្រធានមានន័យមិនទាន់ត្រឹមត្រូវទាំងស្រុងនោះទេ ព្រោះការស្វែងរកគូអនាគត ឱ្យកូនវាជារឿងសំខាន់ណាស់ ព្រោះឪពុកម្ដាយបានត្រឹមតែផ្ដល់កំណើត និងចិញ្ចឹមបីបាច់មើលថែកូនរហូតមានគ្រួសារតែប៉ុណ្ណោះ ចំណែកអនាគតនៅថ្ងៃខាងមុខ គឺពួកគេជាអ្នកសម្រេចដោយខ្លួនឯង ដូច្នេះយើងត្រូវតែផ្ដល់នូវសិទ្ធិស្វ័យសម្រេចខ្លះសម្រាប់ពួកគេជាដាច់ខាត។

- *ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមខ្ញុំ ជាកុលបុត្រខ្មែរមួយរូប យល់ឃើញថា ចំណុចខាងលើនេះអាចធ្វើឱ្យយើងជាបច្ឆាជនជំនាន់ក្រោយស្វែង យល់បានយ៉ាងច្បាស់ថា ប្រសិនបើយើងជាអាណាព្យាបាល ត្រូវ តែស្វែងយល់អំពីកូនជាទីស្រឡាញ់របស់ខ្លួនឱ្យបានច្បាស់ ជា ពិសេសឱ្យសិទ្ធិដល់កូន ក្នុងការជ្រើសរើសគូស្រករ។ បើយើងជា កូនវិញត្រូវស្តាប់ដំបូន្មានឪពុកម្តាយ ចេះផ្តល់ហេតុផលចំពោះ គាត់ ដោយមិនត្រូវអត្តនោម័ត តែឯកឯង ក្នុងការជ្រើសរើសគូ ស្រករនោះទេ។*

**ប្រធានទី១១៖** គេថា៖«រឿងព្រះវេស្សន្តរ ជាស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ»។ ចូរពន្យល់ដោយរកអំណះអំណាងមកបញ្ជាក់។

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ តាមរយៈនៃការសិក្សាអក្សរសិល្ប៍របស់ខ្មែរយើង ឃើញថាគេបែងចែកអក្សរសិល្ប៍ជាបីប្រភេទ ហើយចែកចេញជាបួនចលនា ដែលក្នុងនោះមានចលនាអក្សរសិល្ប៍ពុទ្ធនិយមត្រូវបានអ្នកអក្សរសាស្ត្របែងចែកជា ផ្នែកផ្សេងៗទៀត។ ក្នុងនោះដែរក្រោយពីបានសិក្សាស្នាដៃរឿងព្រះវេស្សន្តររួចមក យើងឃើញថា រឿងនេះបានបង្ហាញពីការធ្វើទាន បារមីរបស់ព្រះពោធិសត្វនាជាតិទីដប់ ដែលមាននៅក្នុងសៀវភៅសង្ខេបទសជាតក។
- ចំណូលបញ្ហា៖ ដោយមើលឃើញចំណុចទាំងនេះហើយ ទើបអ្នកសិក្សាអក្សរសាស្ត្រជាច្រើនក៏បានលើកឡើងថា៖«រឿងព្រះវេស្សន្តរជាស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ»។
- ចំណោទបញ្ហា៖ តើគេមានអំណះអំណាងបែបណាខ្លះ បានជាគេពោលដូចនេះ?

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ នូវទស្សនៈរបស់ប្រធានខាងលើ ជាបឋមយើងគប្បីស្វែងយល់នូវពាក្យគន្លឹះរបស់ប្រធានឱ្យបានច្បាស់លាស់ជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ពាក្យពុទ្ធនិយមសុទ្ធសាធ សំដៅដល់រឿងទាំងឡាយណាដែលស្ថិតនៅ ក្នុងគម្ពីរទសជាតក។

- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះដែលបានពន្យល់រួចទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការត្រឹមត្រូវណាស់ នៅក្នុងរឿងព្រះវេស្សន្តរពិតជា រឿងដែលស្ថិត ក្នុងអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធមែន ព្រោះរឿងនេះបានបង្ហាញពីទង្វើរបស់តួអង្គព្រះវេស្សន្តរ ក្នុងការប្រព្រឹត្តនូវអំពើល្អប្រកប ដោយសីលធម៌យ៉ាងបូរិបូរណ៍ មិនប្រព្រឹត្តអំពើអាក្រក់សូម្បីជាមួយអ្នកនគរដទៃ។
  - ❖ យើងដឹងមកហើយថាអក្សរសិល្ប៍ពុទ្ធនិយមជាអក្សរសិល្ប៍ដែលនិយាយទាក់ទងទៅនឹងការបំពេញទានរបស់ព្រះពោធិសត្វដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធ។ ផ្ទៃរឿងទាំងមូលលាតត្រដាងអំពីការបំពេញទានសន្សំកុសល និងស្វែងត្រាស់ដឹងចម្លងសត្វលោកឱ្យរួចផុតពីវដ្តសង្សារ។
  - ❖ រាល់សកម្មភាពនៃដំណើរជីវិតរបស់តួអង្គព្រះពធិសត្វគឺប្រកាន់ភ្ជាប់នូវធម៌ខន្តី មេត្តា ករុណាជាដើម។
  - ❖ ការបញ្ចាប់សាច់រឿងក៏បង្ហាញពីការសរជាតិនៃតួអង្គ
  - ❖ ម្យ៉ាងទៀតរឿងនេះបានបង្ហាញពីការបំពេញបារមីដប់យ៉ាងដូចខាងក្រោម៖
    - ⇨ ព្រះអង្គបានបំពេញនូវទានបារមី ត្រង់ព្រះអង្គបានបរិច្ចាគនូវពាហិរទាន រួមមានបុត្តបរិច្ចាគ ទារបរិច្ចាគ ធន

បរិច្ចាគ និងអជ្ឈត្តិកទាន(គ្រាន់តែបានប្រកាសប៉ុណ្ណោះ) ដល់ពួកព្រាហ្មណ៍ទាំងឡាយ។

- ព្រះវេស្សន្តរ បានបំពេញនេក្ខកម្មបារមី នៅត្រង់ព្រះអង្គសុខចិត្តចេញទៅបួសជាឥសីនៅ ឯភ្នំគិរីវង្កត បន្ទាប់ពីបាននិរទេសពីនគរ។
- ទ្រង់បំពេញ វីរិយបារមីនៅពេលព្រះអង្គមិនទម្លាក់ការងារនៅកណ្តាលផ្លូវ តួយ៉ាងដូចជាព្រះអង្គមិនរួញរា និងមិនព្រមបោះបង់ការទៅបួសនៅ ឯព្រៃទោះបីធ្វើដំណើរមានឧបសគ្គយ៉ាងណាក៏ដោយ។
- ទ្រង់បំពេញមេត្តាបារមី គឺនៅពេលដែលព្រះអង្គផ្សាយនូវសេចក្តីអាណិតស្រឡាញ់ រាប់អាន មិនរើសមុខ ដល់ពួកស្មូមយាចកទាំងឡាយទោះបីគេធ្វើយ៉ាងណា ចំពោះព្រះអង្គក៏ដោយ។
- ទ្រង់បំពេញអធិដ្ឋានបារមី គឺព្រះអង្គតាំងចិត្តមាំមួន ដើម្បីសម្រេចបំណងប្រាថ្នា គឺព្រះនិព្វានបានន័យថា ទោះខ្លួនត្រូវទៅជាយ៉ាងណា ក៏ដោយក៏មិនគិត គឺគិតតែម្យ៉ាងឱ្យតែបានសម្រេចការត្រាស់ដឹងតែប៉ុណ្ណោះ។
- បញ្ញាបារមី គឺនៅពេលដែលព្រះវេស្សន្តរចេះដោះស្រាយនូវបញ្ហានានា ដែលចោទមាននៅក្នុងជីវិតរស់នៅ តួយ៉ាងដូចជាព្រះអង្គបានកំណត់តម្លៃយ៉ាងខ្ពស់ចំពោះបុត្រទាំងពីររបស់ព្រះអង្គនៅពេលដែលទ្រង់ប្រគល់ឱ្យទៅ

តាជូជកមាន តែស្តេចផែនដីទេ ដែលអាចលោះបុត្រទាំងពីរនេះបាន។

- ព្រះវេស្សន្តរបំពេញ នូវសីលបារមីនៅពេលដែលព្រះអង្គរក្សាកាយ វាចា ចិត្តបានល្អប្រពៃ ដូចជាមិនជួបជាមួយនឹងនាងមទ្រីនៅពេលយប់ ខណៈដែលទ្រង់កំពុងតាំងសីលភាវនាធម៌ ពេលនោះដែរ នាងមទ្រីបានយល់សប្តិចម្លែកចង់ឱ្យព្រះអង្គជួយបកស្រាយប្រាប់ តែព្រះអង្គបានហាមនាងមទ្រីមិនឱ្យជួបមុខទ្រង់ទេ គ្រាន់តែប្រាប់ថាសុបិន្តនោះវាជាការល្អប៉ុណ្ណោះ។
- ខន្តីបារមី ពេលដែលព្រះអង្គមានចិត្តអំណត់ ក្នុងគ្រាបុត្រទាំងពីរត្រូវតាជូជកវាយដំក៏ស៊ូទ្រាំនៅរក្សាចិត្តស្ងប់ជានិច្ច។
- ចំពោះឧបេក្ខាបារមី គឺនៅត្រង់ព្រះវេស្សន្តរបានតាំងចិត្តជាកណ្តាលមិនលម្អៀងទៅភាគីម្ខាងៗដូចជា មិនលម្អៀងទៅខាងព្រះបាទស្រីសញ្ជ័យ ឬពួកអ្នកស្រីពិរាស្ត្រឡើយនៅពេលដែលទ្រង់ត្រូវបំបរបង់ពីនគរ។
- រីឯសច្ចបារមីវិញ គឺព្រះវេស្សន្តរមិនប្រែក្រឡះសម្តីនិយាយបាតដៃខ្នងដៃទេ គឺប្រកាន់ពាក្យពិតរហូត ដូចជាបានសន្យាថានឹងឱ្យទានដល់បុគ្គលណា ដែលមកសុំព្រះអង្គទោះបីជីវិតក៏ដោយ។

- សរុបសេចក្តី៖ សរុបសេចក្តីមកឃើញថា រឿងព្រះវេស្សន្តរជាតកពិតជាអក្សរសិល្ប៍ពុទ្ធិនិយមសុទ្ធសាធដែលបានលើកយក

សកម្មភាព របស់ព្រះពោធិសត្វមកលាតត្រដាងទៅតាម បរេណី នៃពោធិសត្វនីមួយៗក្នុងការសម្រេចការត្រាស់ដឹង ជាព្រះសម្មាសម្ពុទ្ធ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ក្រោយពីបានធ្វើការបកស្រាយនូវទស្សនៈរបស់ប្រធានរួចមក សបញ្ជាក់ឱ្យឃើញថា គំនិតប្រធានខាងលើពិតជាមានតម្លៃ អត្ថន័យល្អៗជាច្រើន ដែលទាក់ទងទៅនឹងសកម្មភាពរបស់ព្រះពោធិសត្វវេស្សន្តរ សម្រាប់ជាគតិអប់រំដល់មនុស្សទូទៅក្នុងលោក។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមជាកូនខ្មែរម្នាក់ ដែលប្រកាន់នូវលទ្ធិព្រះពុទ្ធសាសនា ត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវរាល់សេចក្តីល្អសព្វគ្រប់បែបយ៉ាង ដើម្បីរស់នៅប្រកបដោយសុភមង្គលទាំងក្នុងសង្គមគ្រួសារ និងសង្គមជាតិ។
- ពាក្យស្លោក ឬសុភាសិត៖ សមដូចទស្សនៈមួយបានពោលឡើងថា៖«ពុទ្ធសាសនានាំមកនូវសុខសន្តិភាព និងអភិវឌ្ឍន៍ ព្រោះព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ»។

**ប្រធានទី១២៖** ក្នុងរឿងថៅកែចិត្តចោរ ពូហំបានពោលថា៖«អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះ ដើម្បីសេចក្តីពិតផុះឡើង»។ ចូរពន្យល់គំនិតខាងលើនេះឱ្យបានក្បោះក្បាយ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យោងតាមការសិក្សាអក្សរសិល្ប៍ទំនើប របស់អ្នកនិពន្ធពីររូបគឺលោកអ៊ុំ ឈឺន និងលោកពៅ យូឡេង ទាក់ទងទៅនឹងស្នាដៃរឿងថៅកែចិត្តចោរ បានបង្ហាញឱ្យឃើញថារឿងនេះបានលើកយក ពីបញ្ហាទំនាស់តួអង្គហំ និងតួអង្គថៅកែ។ ស្ថានភាពនៃទំនាស់បានធ្វើឱ្យកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់តួអង្គហំត្រូវបាត់បង់ តែបន្ទាប់ពីនោះតួអង្គហំ ក៏បានភ្ញាក់រឭកមករកផ្លូវត្រូវវិញ ដោយសុខចិត្តឱ្យវង្សត្រកូលខ្លួនក្រ ក៏ក្រចុះស្លាប់ក៏ស្លាប់ចុះ ដើម្បីឱ្យសេចក្តីពិតផុះឡើង។
- ចំណូលបញ្ហា៖ ដោយទាក់ទងទៅនឹងការវិនិច្ឆ័យបែបនេះហើយ ទើបក្នុងរឿងនេះពូហំពោលថា៖«អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះ ដើម្បីសេចក្តីពិតផុះឡើង»។
- ចំណោទបញ្ហា៖ តើពូហំមានគំនិតដូចម្តេចខ្លះ បានជាគាត់ពោលដូចនេះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ

យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ វង្សត្រកូលមានន័យថាគ្រួសារ ពូជអំបូរ។ សេចក្តីពិត រឿងមូលហេតុនៃទំនាស់រវាងពូហំ និងថៅកែ។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថាអញសុខចិត្តឱ្យគ្រួសារ ពូជអំបូរអញស្លាប់ចុះ ដើម្បីឱ្យរឿងមូលហេតុនៃទំនាស់រវាងខ្លួនអញ និងថៅកែផ្ទុះឡើង។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម
    - ❖ ជាភាពជាក់ស្តែងបើយើងក្រលេកមើលពីបញ្ហានៃអក្សរសិល្ប៍ក្នុងរឿងថៅកែចិត្តចោរនេះស្តែងឱ្យឃើញថាជារឿងមួយដែលបានបង្ហាញពី៖
        - ✓ អំពើស៊ីសំណូកសូកប៉ាន់
        - ✓ អំពើជិះជាន់
        - ✓ កេងប្រវ័ញ្ចពីបណ្តាអ្នកមានអំណាចបុណ្យស័ក្តិ អ្នកមានលុយស្តុកស្តម្ភ មកលើអ្នកទន់ខ្សោយ
        - ✓ បង្ហាញពីការតស៊ូរើបម្រះចំពោះការជិះជាន់
        - ✓ និងភាពអយុត្តិធម៌សម្រាប់អ្នកទន់ខ្សោយ ទង្វើទាំងនេះបានបន្សល់ទុកតាំងពីសម័យអាណានិគមបារាំង រហូតដល់សម័យសង្គមរាស្ត្រនិយមដែលទើបនឹងទទួលបាននូវឯករាជថ្មីៗ តាមរយៈសកម្មភាពតួអង្គ៖

## បង្ហាញសកម្មភាពតួអង្គនៃរឿងអក្សរសិល្ប៍៖

⇨ ស្ថានភាពគ្រួសារពូហំ

- ប្រពន្ធពូហំឈឺ គ្មានប្រាក់ព្យាបាល
- កូនត្រូវបន្តការសិក្សា
- ម្តាយចាស់ចង់ធ្វើបុណ្យ ត្រូវការលុយ។

⇨ វិធីរកប្រាក់របស់ពូហំ

- គាត់សល់តែមធ្យោបាយចុងក្រោយមួយ គឺការប្រថុយជីវិតជាមួយថៅកែ ដើម្បីប្រាក់មួយម៉ឺនរៀល
- កិច្ចសន្យារវាងពូហំ និងថៅកែដោយពូហំសុខចិត្តធ្វើតាមគំនិតរបស់ថៅកែ ដើម្បីប្រាក់មួយម៉ឺនរៀល
- ការបោកប្រាស់របស់ថៅកែ ដោយថៅកែមិនគោរពកិច្ចសន្យា ហើយឱ្យពូហំរត់គេចខ្លួន និងឱ្យប្រាក់ពីររយរៀល

⇨ ការភ្ញាក់រឭករបស់ពូហំ

- ការប្រឆាំងតបតទៅនឹងគំនិតបោកប្រាស់ របស់ថៅកែ
- បំណងចង់បានយុត្តិធម៌សម្រាប់អ្នកក្រ កម្មករ សង្គម
- ពូហំចង់ឱ្យថៅកែទទួលកំហុសដូចគ្នាដែរ...
- ឧត្តមគតិពូហំគឺ ក្រក៏ក្រចុះ ស្លាប់ក៏ស្លាប់ចុះ ឱ្យតែថ្លៃថ្នូរមានយុត្តិធម៌...
- ការចូលរួមរបស់តួអង្គដទៃទៀតដើម្បីយុត្តិធម៌ដូចជា (មីងយ៉ាន គង់ មាន ទ្រី សុខ ផានិត)។

- សរុបសេចក្ដី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថាក្រោយពីការប្រព្រឹត្តអំពើទុច្ចរិតរបស់ពូហំ និងថៅកែរួចមកបានធ្វើឱ្យតួអង្គហំមានការភ្ញាក់រឭកមករកសេចក្ដីសុចរិតវិញ។ ក្នុងកាលៈទេសៈបែបនេះ បានជំរុញឱ្យពូហំសុខចិត្តលះបង់សេចក្ដីសុខក្នុងគ្រួសារដើម្បីសេចក្ដីសុខរួម និងយុត្តិធម៌សង្គម។

## គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើនេះ យើងឃើញថាទស្សនៈរបស់ប្រធានខាងលើពិតជាផ្ដល់តម្លៃអប់រំយ៉ាងជ្រាលជ្រៅ ព្រោះការភ្ញាក់រឭករបស់ពូហំជាអំពើមួយល្អកម្ររកបាននៅក្នុងសង្គម។ ហើយសេចក្ដីភ្ញាក់រឭកនេះបានផ្ដល់ជាគតិសម្រាប់ក្រើនរំឭកដល់នរជនទាំងឡាយ ដែលបានប្រព្រឹត្តនូវអំពើឆ្គាំឆ្គងខ្វះការពិចារណា ប្រែក្លាយជាមានគំនិតចេះ ភ្ញាក់រឭកកែប្រែកំហុសខ្លួនដោយកុំឱ្យកម្លាំងទឹកប្រាក់អូសទាញបាន ហើយងាកមករកសុចរិតភាពវិញ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សាត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយយើងត្រូវចេះមានគំនិតភ្ញាក់រឭកបែបនេះដែរ ព្រោះមនុស្សម្នាក់ៗដែលកើតមកហើយ រមែងមានកំហុសជារឿងធម្មតារបស់មនុស្ស តែសំខាន់ គឺការភ្ញាក់រឭកកែប្រែខ្លួនទៅរកអ្វីដែលល្អនេះឯង។

- *ពាក្យស្លោក ឬសុភាសិត៖ សមទស្សនៈមួយពោលថា៖«អ្នកដែលធ្វើខុសប្រសើរជាង អ្នកដែលមិនបានធ្វើខុសប្រសិនបើអ្នកដែលបានធ្វើខុសនោះ ចេះយកកំហុសរបស់ខ្លួន មកធ្វើជាមេរៀនទៅថ្ងៃអនាគត»។*

**ប្រធានទី១៣៖** គ្រប់ជាតិសាសន៍សុទ្ធតែមានជំនឿផ្សេងៗគ្នា។ តើជំនឿមានឥទ្ធិពលដូចម្តេចខ្លះចំពោះជីវិតមនុស្ស? ចូរបង្ហាញដោយភ្ជាប់ ឧទាហរណ៍ពីក្នុងសង្គម និងអក្សរសិល្ប៍ដែលអ្នកបានសិក្សារួច។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ លើលោកយើងនេះមានសាសនាជាច្រើន ដែលមនុស្សតែងនាំគ្នាគោរព រួមមានសាសនាមហាម៉ាត់ យេស៊ូសាសនាតៅ ពុទ្ធសាសនា និងព្រហ្មញ្ញសាសនាជាដើម។ ប្រការដែលគេនាំគ្នាគោរពបែបនេះដោយសារ គេមានជំនឿថារាល់សាសនាទាំងអស់នោះផ្តល់នូវផលប្រយោជន៍ ដ៏ប្រសើរសម្រាប់ពួកគេ។
- ចំណូលបញ្ហា៖ ដោយទាក់ទងទៅនឹងការវិនិច្ឆ័យបែបនេះហើយ ទើបគេយល់ថា៖«ជំនឿតែងតែមានឥទ្ធិពលចំពោះជីវិតមនុស្ស»។
- ចំណោទបញ្ហា៖ តើជំនឿមានឥទ្ធិពលដូចម្តេចខ្លះចំពោះជីវិតមនុស្ស? ចុះក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ បានបង្ហាញពីទំនាក់ទំនងនៃជំនឿជុំវិញជីវិតមនុស្សយើងបែបណាខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននូវការបកស្រាយទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់និងកាន់តែល្អនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន

- ពន្យល់ពាក្យគន្លឹះ៖ ជំនឿ មានន័យថាការជឿជាក់លើអ្វីមួយ។ ឥទ្ធិពល មានន័យថាកម្លាំងគ្របដណ្តប់ដែលអាចបង្កើតនូវអ្វីផ្សេងបាន។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថា ការជឿជាក់លើអ្វីមួយ តែងតែមានកម្លាំងគ្របដណ្តប់ ដែលអាចបង្កើតនូវអ្វីផ្សេងៗបាន ចំពោះជីវិតមនុស្ស។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម
  - ❖ ជាភាពជាក់ស្តែងបើយើងឈរលើការនិទស្សន៍(ការពន្យល់ឱ្យឃើញហេតុផល) ទាក់ទងទៅនឹងស្មារតីមនុស្ស បានស្តែងឱ្យឃើញយ៉ាងច្បាស់ថាជំនឿជាកម្លាំងធ្វើឱ្យមនុស្សមានសេចក្តីក្លាហានពុះពារចំពោះគ្រប់ឧបសគ្គ ដោយមនុស្សព្យាយាមធ្វើឱ្យកិច្ចការ ដែលខ្លួនបំពេញបានសម្រេចដូចបំណង។
  - ❖ ជំនឿមានពីរប្រភេទ៖ ការជឿលើកម្លាំងក្នុងខ្លួន ជាជំនឿជាក់លើខ្លួនឯង ំ និងកម្លាំងក្រៅខ្លួនដែលទាក់ទងទៅនឹងអបិយជំនឿ។
  - ❖ ជំនឿអរូបិយទាក់ទងទៅនឹងវត្ថុសក្តិសិទ្ធិ មន្តអាគម ការពារ ...។
  - ❖ ការមានជំនឿជាក់លើខ្លួនឯង ពិតជាអាចធ្វើឱ្យមនុស្សមានភាពជោគជ័យស្ទើរតែគ្រប់ភារកិច្ចទាំងអស់ ទោះភារកិច្ចនោះតូចក្តី ធំក្តី។

**ក. បង្ហាញពីសង្គមជាក់ស្តែង**

- ⇨ កសិករខំធ្វើការហាលក្តៅ ហាលភ្លៀង ហាលខ្យល់ ព្រោះមានជំនឿថានឹងទទួលបានផលនាពេលអនាគត
- ⇨ សិស្ស និស្សិត ខិតខំសិក្សារៀនសូត្រឱ្យបានពូកែព្រោះគេមានជំនឿថា នឹងបានប្រឡងជាប់ មានការងារធ្វើ
- ⇨ អាជីវករ ខិតខំរកស៊ីចំណាយកម្លាំងកាយ បញ្ញាយ៉ាងសន្ធឹកសន្ធាប់ ព្រោះគេមានជំនឿថានឹងបានរីកចម្រើន
- ⇨ ប្រជាជនធ្វើការបន់ស្រន់សុំសេចក្តីសុខពេលជួបទុក្ខលំបាក...។

**ខ. បង្ហាញពីអក្សរសិល្ប៍**

- ⇨ រឿងភូមិតិរច្ឆាន(នៅ ជួន នាងនី នាងប៊ី រួមនឹងអ្នកស្រុកក្រាំងលាវ រួមគ្នាកំចាត់បារាំង ព្រោះមានជំនឿថាពួកគេពិតជាដណ្តើមសិទ្ធិសេរីភាព សេចក្តីសុខពីពួកបារាំងដោយតស៊ូមិនតក់ស្លុត និងទារុណកម្ម)។
- ⇨ រឿងព្រះអាទិត្យថ្មី(សមជឿលើនយោបាយទឹកក្រោមការដឹកនាំរបស់អង្គសម្តេចឪ អាចឱ្យជីវិតរុងរឿង)។
- ⇨ រឿងគូលីកំនែន(នូ ដួង ឧបាសកឃឹម លឹម ម៉ឺង មានការតស៊ូទាមទារសិទ្ធិពីពួកបារាំង ព្រោះពួកគេមានជំនឿថាពេលអនាគត នឹងអាចស្វែងរកសិទ្ធិសេរីភាពជូនជាតិមាតុភូមិបាន យ៉ាងពិតប្រាកដ...)
- ⇨ រឿងភ្នំនាងកង្រីពេលដែលសេដ្ឋីគ្មានកូនបាននាំគ្នាទៅបន់ស្រន់អ្នកតាក្រោមដើមជ្រៃ...។។

- សរុបសេចក្តី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថាជំនឿវត្ថុជំរុញឱ្យមនុស្ស ក្លាហាន អត់ធ្មត់នឹងការងារ អាចធ្វើឱ្យមនុស្សទទួលបាននូវអ្វីៗដែលខ្លួនប៉ងប្រាថ្នាសម្រាប់អនាគត។ ដោយសារហេតុទាំងនេះហើយ បានជាគ្រប់ជាតិសាសន៍នៅក្នុងលោកពុំអាចផ្តាច់ខ្លួន ពីបញ្ហាជំនឿផ្សេងៗបាននោះ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិត ចំពោះទស្សនៈរបស់ប្រធានខាងលើនេះ យើងឃើញថាទស្សនៈរបស់ប្រធានខាងលើ ពិតជាផ្តល់តម្លៃអប់រំយ៉ាងជ្រាលជ្រៅ ព្រោះដរាបណានៅមានជំនឿវានឹងធ្វើឱ្យមនុស្សទម្លាយបាននូវរាល់ការលំបាក។ ជំនឿបានផ្សាំងមនុស្សឱ្យបែរមុខឆ្ពោះទៅរកមាគ៌ាដ៏ប្រពៃ ដែលមនុស្សទៅទៅចង់បាន តែមនុស្សក៏គួរតែចៀស វាងដែរនូវជំនឿណាដែលបង្កឱ្យមានភាពអន់ថយស្មោកគ្រោក មិនទាន់សម័យនោះទើបយើងអាចរក្សាតម្លៃជីវិតឱ្យខ្ពស់ត្រដែតតរៀងរហូតទៅ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សាត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវមានជំនឿជាក់យ៉ាងមុតមាំក្នុងការបំពេញការងារតួនាទីអ្វីមួយ ដែលជាកាតព្វកិច្ចត្រូវបំពេញជូនគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូល ឱ្យបានរីកចម្រើនតរៀងទៅ។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី១៤៖**មានមតិមួយយល់ថា៖«មនុស្សរស់នៅត្រូវពឹងខ្លួនឯង»។ ឯមតិមួយទៀតយល់ថា៖«មនុស្សរស់នៅត្រូវពឹងអ្នកដទៃ»។ ចូរពិភាក្សា ដោយលើកឧទាហរណ៍មកបញ្ជាក់ឱ្យបានក្បោះក្បាយ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សយើងម្នាក់ៗដែលបានកើតមកនៅលើលោកសន្និវាសយើងនេះ តែងតែជួបប្រទះ ឬប្រឈមមុខទៅនឹងបញ្ហានៃសេចក្តីទុក្ខវេទនាគ្រប់បែបយ៉ាងដែលវាជាវិបត្តិដ៏ស្មុគស្មាញ ជំពាក់វាក់វិន ពិបាកនឹងដោះស្រាយឱ្យដាច់ស្រឡះបានឡើយ។ ក្នុងករណីនេះទាមទារឱ្យមនុស្សយើងត្រូវចេះដោះស្រាយបញ្ហានានា ដោយផ្ទាល់ខ្លួន ជួនកាលករណីខ្លះខ្លួនឯង ក៏មិនអាចដោះស្រាយបានឡើយ គឺចាំបាច់ត្រូវសុំអន្តរាគមន៍ ពីជនានុជនផងដែរ។
- ចំណូលបញ្ហា៖ វិភាគទាក់ទងនឹងបញ្ហាខាងលើ ទើបធ្វើឱ្យមានមតិមួយបានយល់ឃើញថា៖«មនុស្សរស់នៅត្រូវពឹងខ្លួនឯង»។ ឯមតិមួយទៀតយល់ថា៖«មនុស្សរស់នៅត្រូវពឹងអ្នកដទៃ»ដើម្បីទុកជាទស្សនៈទានឱ្យយើងធ្វើការពិចារណា។
- ចំណោទបញ្ហា៖ តើទស្សនៈមតិទាំងពីរដែលបានពោលខាងលើនេះមួយណាត្រឹមត្រូវជាងមួយណា?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ នូវទស្សនៈរបស់ប្រធានខាងលើ ជាបឋមយើងគប្បីស្វែងយល់នូវពាក្យគន្លឹះរបស់ប្រធានឱ្យបានច្បាស់ជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ មនុស្សរស់នៅមានន័យថា ជនដែលមានជីវិតស្ថិតក្នុងសង្គម។ ពឹងខ្លួនឯងមានន័យថា សមត្ថភាពមាន សម្រាប់ជួយខ្លួនឯងដោយកម្លាំងកាយចិត្ត។ ពឹងអ្នកដទៃមានន័យថា សុំការជ្រោមជ្រែងពីមនុស្សនានាឱ្យជួយគិតគូរដោះស្រាយ។
- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះ ដែលបានពន្យល់រួច ទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តាររួមផ្សំហេតុផល និងអំណះអំណាងបញ្ជាក់ដូចខាងក្រោម៖
  - ❖ ជាការពិតណាស់ មនុស្សយើងម្នាក់ៗត្រូវតែខិតខំធ្វើអ្វីគ្រប់យ៉ាង ដោយប្រើសមត្ថភាពផ្ទាល់ខ្លួនជាឯកជនភាព ដើម្បីសម្រេចនូវការងារបែបណាមួយប្រកបដោយភាពជោគជ័យ ដែលពុំត្រូវការជំនួយពីអ្នកណាម្នាក់ឡើយ តែករណីមួយចំនួន យើងក៏អាចត្រូវការអ្នកដទៃជាចាំបាច់ដែរ ព្រោះវាគឺជាច្បាប់ធម្មជាតិទៅហើយ។
    - ⇨ ពេលពេញវ័យមានកម្លាំងមាំមួន មិនសុំទានគេ កុំដេកស៊ីកម្លាំងគេ ត្រូវចេះធ្វើការ។
    - ⇨ ពេលជួបទុក្ខដោយវិបត្តិផ្ទាល់ខ្លួន តោងប្រឹងស្រាយយោងហេតុផល ទើបសម្រេចផលល្អ។
    - ⇨ មិនដេកផ្សងសំណាង រង់ចាំរបស់មករកខ្លួនឯងដោយមិនចាំបាច់ខំប្រឹងទេ។
    - ⇨ ចេះជួយខ្លួនឯងបានសិន ទើបទេវតា ជួយយើងបានជាក្រោយ។

⇨ គ្មានអ្វីដែលកើតឡើងដោយគ្មានការខំប្រឹងព្យាយាមធ្វើវានោះទេ។

ឧទាហរណ៍

⇨ រឿងកុមារកំព្រា៖ ឪពុកស្លាប់មិនព្រមធ្វើខ្ញុំគេ មិនសុំទានគេ រកស៊ីខ្លួនឯងរហូតបានថ្កើងថ្កាន។

⇨ រឿងកូលាបប៉ៃលិន៖ ចៅចិត្រគោរពបណ្ដាំឪពុក"អត្តាហិ អត្តនោ នាថោ" តស៊ូធ្វើការ។

⇨ រឿងទុំទាវ៖ ពេលនៅក្នុងវាំងពឹងលើការប្ដូរផ្ដាច់ក្លាហានរបស់ខ្លួន ទីបំផុតបានគ្នាជាគូគ្រង។

+ សរុបមតិស្របៈ សរុបមកឃើញថា មនុស្សយើងម្នាក់ៗត្រូវមានចំណេះដឹង ចំណេះធ្វើ ជាការចាំបាច់ព្រោះត្រូវយកបទពិសោធទាំងនោះ មកធ្វើជាទីពឹង សម្រាប់ខ្លួនឯងផ្ទាល់ ព្រោះការរស់នៅដោយពឹងលើកម្លាំងរបស់អ្នកដទៃ ពិតជាមិនអាចធ្វើឱ្យជីវិតមានសេចក្ដីថ្លៃថ្នូរនោះទេ។ ដូចនេះមានតែខ្លួនទីពឹងខ្លួន តែប៉ុណ្ណោះទើបប្រសើរ។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

✵ សំណួរភ្ជាប់សេចក្ដី៖ តើមនុស្សយើងម្នាក់ៗរស់នៅដោយមិនត្រូវពឹងពាក់លើអ្នកដទៃឬយ៉ាងណា?

+ មតិផ្ទុយ៖ ទោះបីមជ្ឈដ្ឋានខាងលើខំធ្វើការអះអាង ជាមួយនឹងភស្តុតាងយ៉ាងជាក់ស្ដែងគួរឱ្យស្ដាប់បានយ៉ាងណាក៏ដោយ ក៏គេនៅតែឃើញទស្សនៈមួយទៀតប្រឆាំងយ៉ាងដាច់អហង្ការដែរ ដោយគេយល់ថាមនុស្សម្នាក់ៗមិនអាចរស់នៅស្ថិតក្នុងភាពឯកោនោះទេ គឺត្រូវតែពឹងពាក់គ្នាជាដាច់ខាតព្រោះ៖

⇨ បញ្ហាខ្លះជារឿងធំពេក ស្រាយម្នាក់ឯងពុំបានត្រូវសុំអន្តរាគមន៍ពីមហាជន ទើបចម្លងបញ្ហាដល់ទីបញ្ចប់។
⇨ ពឹងអ្នកដទៃពេលកម្ចាត់ក្រុមជនអន្ធពាល
⇨ ស្ពាបនាសមិទ្ធផលធំៗបម្រើជីវភាព(លើកផ្ទះ)
⇨ ទប់ស្កាត់ការគម្រាមពីជំងឺរាតត្បាត
⇨ ខ្វះទុនពង្រីកមុខរបរ មានលក្ខណៈទ្រង់ទ្រាយធំត្រូវពឹងពាក់អ្នកដទៃ ឬធនាគារ។

## ឧទាហរណ៍

⇨ រឿងអាខ្វាក់អាខ្វិនៈ រត់គេចពីចៅហ្វាយ ពួកគេពឹងគ្នាជួបខ្លា ជួបយក្សរួមគ្នាកំចាត់។
⇨ រឿងតេជោយ៉តៈ កំចាត់ស្ដេចសម្រែ ពឹងពួកអ្នកបម្រើប្រុសស្រី ជួយអនុវត្តល្បិចសម្ងាត់។
⇨ រឿងកុលាបប៉ៃលិនៈ កំចាត់មន្ត្រីខូច មេចោរទុយិស ចៅចិត្ររួមកម្លាំងពីសំណាក់កម្មករ។

\+ សរុបមតិផ្ទុយៈ សរុបសេចក្ដីមកឃើញថា ការបកស្រាយបង្ហាញខាងលើ ពិតជាតម្រូវឱ្យមនុស្សទូទៅ ត្រូវមានការពឹងពាក់គ្នាទៅវិញទៅមកដើម្បីដោះស្រាយបញ្ហា គ្រប់បែបយ៉ាង ដែលកើតមានឡើង ប្រកបដោយមោទនភាព យ៉ាងប្រត្យក្ស។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សំយោគមតិៈ ជារួមមកយើងឃើញថាការបកស្រាយខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និដ្ឋានបាន

ថាជុំវិញ នៃការរស់នៅរបស់មនុស្សត្រូវតែមានលក្ខណៈឯករាជ្យ ពុះពារជួយខ្លួនឯងសិន ទើបមានតម្លៃសមជាមនុស្ស ហើយពេលយើងប្រើអស់លទ្ធភាពហើយ ទើបយើងងាកមកសុំជំនួយជាមតិគំនិត ទុន ពីអ្នកដទៃ។ ការដែលមានជំហរ បែបនេះទើបនាំឱ្យជីវិតរស់នៅមានភាពត្រចះត្រចង់។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់យើងឃើញ ថាមតិរបស់ប្រធានមិនទាន់មានន័យត្រឹមត្រូវនោះទេ ព្រោះមតិនីមួយៗ ពុំទាន់មានន័យគ្រប់ជ្រុងជ្រោយនោះឡើយ ដោយមនុស្សយើងម្នាក់ៗពុំអាចរស់នៅ ដោយឯកោតែម្នាក់ឯងបានទេ ហើយក៏មិនត្រូវចេះតែពឹងពាក់គេខ្លាំងពេកនោះដែរ។ នរជនទូទៅគប្បីមានឆន្ទៈកសាងជីវិតខ្លួនឯងឱ្យខ្លាំងក្លាចាកផុតពីការប្រមាថ ថាជាជនបញ្ញើក្អែក គឺត្រូវធ្វើខ្លួនជាឱសថទិព្វសម្រាប់ព្យាបាលអ្នកដទៃ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមខ្ញុំជាកុលបុត្រខ្មែរមួយរូប ដែលជាបច្ឆាជនជំនាន់ក្រោយ ត្រូវខិតខំរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ដើម្បីជួយខ្លួនឯង ដោយប្រើសមត្ថភាពផ្ទាល់ខ្លួនដោយមិនចាំបាច់ពឹងពាក់អ្នកដទៃឡើយ តែត្រូវតែតាំងខ្លួនឯង គឺជាជំនួយដ៏សំខាន់មួយ ក្នុងការជួយអ្នកដទៃឱ្យសម្រេចជោគជ័យគ្រប់បែបយ៉ាង។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី១៥៖** មានទស្សនៈមួយបានលើកឡើងថា៖«មូលដ្ឋាននៃសេចក្តីទុក្ខ របស់មនុស្សកើតមកពី លោភៈ ទោសៈ មោហៈ»។ ចូរបង្ហាញ រួចបញ្ជាក់ពីវិធីលុបបំបាត់ នូវសេចក្តីអាក្រក់ទាំងបី ខាងលើតាមលទ្ធិពុទ្ធសាសនា។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សយើងម្នាក់ៗបើបានប្រព្រឹត្តអំពើអាក្រក់ ដោយខ្វះសតិក្នុងការពិចារណា ហើយមានការងប់ងុលលើអ្វីមួយ ដោយទុច្ចរិតនោះនឹងនាំយើង ឱ្យទទួលរងនូវភាពក្តៅក្រហាយ រស់នៅពុំបានសុខឡើយ។ ករណីនេះក៏បណ្តាលមកពីសេចក្តី លោភៈ ទោសៈ មោហៈរបស់មនុស្សយើងម្នាក់ៗ ដែលជាឫសគល់នៃសេចក្តីទុក្ខ។
- ចំណូលបញ្ហា៖ អាស្រ័យដោយមើលឃើញពីលក្ខណៈបែបនេះហើយ ទើបមានទស្សនៈមួយពោលឡើងថា៖«មូលដ្ឋាននៃសេចក្តីទុក្ខរបស់មនុស្សកើតមកពីលោភៈ ទោសៈ មោហៈ»។
- ចំណោទបញ្ហា៖ តើលោភៈ ទោសៈ មោហៈជាមូលដ្ឋាននៃសេចក្តីទុក្ខយ៉ាងដូចម្តេចខ្លះ? ហើយយើងត្រូវលុបបំបាត់ សេចក្តីអាក្រក់ទាំងបីខាងលើ តាមរយៈលទ្ធិពុទ្ធសាសនាដូចម្តេចដែរ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធានខាងលើឱ្យមានភាពស៊ីជម្រៅ និងកាន់តែល្អនោះ

យើង គប្បីស្វែងយល់ឱ្យបានច្បាស់ នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ សេចក្តីទុក្ខមានន័យថា ការលំបាកវេទនា។ រីឯលោភៈមានន័យថា ការលោភលន់មិនចេះឆ្អែតឆ្អន់។ ពាក្យទោសៈមានន័យថា កំហឹងក្រេវក្រោធ ច្រឡោតទទឹងទិស។ មោហៈមានន័យថា ការវង្វេងមិនដឹងខុសត្រូវ មិនស្គាល់គុណទោស។
- ពន្យល់ន័យប្រធាន៖ ដូចនេះទស្សនៈរបស់ប្រធានមានន័យថាមូលដ្ឋាននៃការលំបាកវេទនារបស់មនុស្សកើតមកពីការលំបាកវេទនា ការលោភលន់មិនចេះឆ្អែតឆ្អន់ ការខឹងក្រេវក្រោធច្រឡោតទទឹងទិស ការវង្វេងមិនដឹងខុសត្រូវ មិនស្គាល់គុណទោស។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍ដូចខាងក្រោម៖
    - ❖ ជាការពិតណាស់ភាពជាមនុស្សដែលរស់នៅក្នុងសង្គមអាចនឹងទទួលបាន នូវសេចក្តីសុខសុភមង្គល ប្រសិនបើយើងមានសុចរិតនៅក្នុងគំនិត ប៉ុន្តែបើយើងម្នាក់ៗនៅតែប្រកាន់ខ្ជាប់នូវភ្លើងលោភៈ ទោសៈ មោហៈនោះសេចក្តីទុក្ខនឹងនៅតែតាមយាយី គ្មានទីបញ្ចប់ឡើយ។ ទាំងនេះក៏ព្រោះតែភ្លើងទាំងបីខាងលើជាឫសគល់បង្កើត នូវការកេងប្រវ័ញ្ចអំពើហិង្សា ការរើសអើង ការឈ្នានីស មានះរឹងរូសប្រទូស្តនឹងអ្វីៗដែលល្អដើម្បីប្រយោជន៍សួនតួ រហូតវិនាសខ្លួនឯង។
        - ▪ វិភាគផ្នែកសង្គម(តាមរយៈលោភៈ ទោសៈ មោហៈ)

⇨ ជនអាត្មានិយម គិតតែប្រយោជន៍ផ្ទាល់ខ្លួន ប្រាថ្នាចង់បានហួសហេតុ បំពានលើ... នឹងត្រូវមានទុក្ខ។
⇨ បុគ្គលចិត្តស្រាលតែងតែមានអារម្មណ៍មួម៉ៅច្រើន ខឹងខូច ខឹងខុស ខឹងខាត... នឹងត្រូវមានទុក្ខ។
⇨ ជនដែលមានចរិតពិសពុលវង្វេងឥតស្គាល់គុណម៉ែឪ ធ្វើអំពើអបាយមុខ... នឹងត្រូវមានទុក្ខ។

- វិភាគផ្នែកអក្សរសិល្ប៍(តាមរយៈលោភៈ ទោសៈ មោហៈ)

⇨ រឿងទុំទាវ៖ ចិត្តលោភលន់របស់ម្ដាយទាវ... ការសម្លាប់ទុំរបស់អរ ជូន... នឹងត្រូវមានទុក្ខ។
⇨ រឿងរាមកេរ្តិ៍៖ ក្រុងរាពណ៍ច្រឡោតខឹង មិនពិចារណាបន្ទាប់ពីពិភេគទាយ និងរិះគន់...នឹងត្រូវមានទុក្ខ។
⇨ រឿងថៅកែចិត្តចោរ៖ ពូហំវង្វេងនឹងប្រាក់បានប្រព្រឹត្តតាមថៅកែបើកឡានបុកគេ... នឹងត្រូវមានទុក្ខ។

- វិធីបំបាត់ទុក្ខ(តាមរយៈការយកសមាធិ សីល បញ្ញា សមាធិ មកកំចាត់លោភៈ ទោសៈ មោហៈ)

⇨ ការរក្សាសីល៖ ការយកសីល មកដាក់ខ្លួនដើម្បីកាត់បន្ថយនូវសេចក្ដីប្រាថ្នាចង់បាននៃលោភៈ។
⇨ ការប្រើបញ្ញា៖ ការយកបញ្ញាដែលខ្លួនមានមកបង្ក្រាបនូវកំហឹង កំហុសនៃភ្លើងទោសៈ។
⇨ ការសមាធិ៖ ការតាំងចិត្តស្ងប់ មិនវង្វេងភ្លាត់ទៅធ្វើអ្វីៗជាអកុសលដែលជាសេចក្ដីវង្វេងនៃមោហៈ។

- សរុបសេចក្តី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថាសេចក្តីទុក្ខទាំងឡាយរបស់មនុស្ស តែងតែកើតមានឡើងដោយសេចក្តីប្រហែសធ្វេសនៃមនុស្ស ដែលបណ្តាលឱ្យខ្លួនលង់ផុងទៅនឹងភ្លើងអបាយទាំងបីនៃសេចក្តី លោភៈ ទោសៈ មោហៈ នេះឯងដែលវាជាមូលដ្ឋាននៃទុក្ខ។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើនេះ ពិតជាផ្តល់តម្លៃអប់រំយ៉ាងល្អ ព្រោះបានរួមចំណែកក្នុងការអប់រំមនុស្សទូទៅឱ្យចេះស្គាល់ល្អអាក្រក់ បាប បុណ្យ បានជួយរំលត់នូវភ្លើងអប្រិយ ដែលបានកើតចេញតាមរយៈ លោភៈ ទោសៈ មោហៈ។ លើសពីនេះនោះគឺបានជួយបណ្តុះចំណេះដឹងតាមបែបពុទ្ធសាសនាដល់អ្នកសិក្សាបានយល់អំពីមាគ៌ា នៃការរំលត់ទុក្ខរបស់ព្រះបរមគ្រូនៃយើង។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែតស៊ូខិតខំរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាមនុស្សប្រកបដោយធនធាន ហើយចេះដើរតាមគន្លង នៃព្រះពុទ្ធសាសនាដោយដើរតាមមាគ៌ានៃការរំលត់ទុក្ខ របស់ព្រះអង្គតាមរយៈការយក សីល បញ្ញា សមាធិ មកកំចាត់បង់ នូវភ្លើងលោភៈ ទោសៈ និងមោហៈឱ្យអន្តរធានរលត់បាត់សូន្យទៅ។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី១៦៖** គេថា៖«រឿងរាមកេរ្តិ៍ ជារឿងមនុស្ស»។ ចូរបកស្រាយដោយលើកយកឧទាហរណ៍មកបញ្ជាក់ឱ្យបានក្បោះក្បាយ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យោងតាមការសិក្សាអក្សរសិល្ប៍ បានធ្វើឱ្យយើងឃើញថារាល់ស្នាដៃអក្សរសិល្ប៍ទាំងអស់ ពិតជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនូវរាល់សកម្មភាពគ្រប់បែបយ៉ាង ដែលកើតមាននៅក្នុងសង្គម។ ជាពិសេសទៀតនោះ គឺអក្សរសិល្ប៍សុទ្ធតែបានឯកភាពគ្នាជាធ្លុងមួយ ដោយត្រូវបានអ្នកនិពន្ធតាក់តែងឡើងក្នុងគោលបំណងលើកយកបញ្ហារបស់មនុស្សមកចោទ និងដោះស្រាយ។ ចំណែករឿងរាមកេរ្តិ៍ដែលជាស្នាដៃរបស់អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស ក៏បានលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយដែរ ទោះបីតួអង្គទាំងនោះ ជាសត្វក៏ដោយ ក៏វាត្រូវបានគេតំណាងឱ្យមនុស្សក្នុងប្រភេទណាមួយផងដែរ។
- ចំណូលបញ្ហា៖ អាស្រ័យដោយមើលឃើញពីលក្ខណៈ បែបនេះហើយទើបគេថា៖«រឿងរាមកេរ្តិ៍ជារឿងមនុស្ស»។
- ចំណោទបញ្ហា៖ តើរឿងរាមកេរ្តិ៍បានបង្ហាញពីរឿងមនុស្សយ៉ាងដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពស៊ីជម្រៅ និងកាន់តែល្អនោះ

យើង គប្បីស្វែងយល់ឱ្យបានច្បាស់ នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ឃ្លារឿងមនុស្សមានន័យថា រឿងដែលបង្ហាញពីការពិតទាក់ទងនឹងមនុស្ស មានលក្ខណៈមនុស្ស។
- ពន្យល់ន័យប្រធាន៖ ដូចនេះទស្សនៈរបស់ប្រធានមានន័យថា រឿងរាមកេរ្តិ៍មិនត្រឹមតែបញ្ចូលរឿងរ៉ាវអាទិទេពតែប៉ុណ្ណោះទេ តែរឿងនេះក៏បានបង្ហាញការពិតទាក់ទងនឹងមនុស្ស មានលក្ខណៈមនុស្សយ៉ាងជាក់ស្តែង។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផលនិងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
    - ❖ ជាការពិតណាស់រឿងគ្រប់ប្រភេទរបស់អក្សរសិល្ប៍ មិនថារឿងអក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ទំនើប ឬក៏ជារឿងអក្សរសិល្ប៍ប្រជាប្រិយនោះទេ គឺសុទ្ធតែបានយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមសកម្មភាពធម្មតារបស់មនុស្ស ដែលគេហៅថាបញ្ហាមនុស្ស។
    - ❖ បញ្ហាមនុស្សមានច្រើនណាស់ដូចជា៖ ទំនាស់ក្នុងគ្រួសារ ទំនាស់ក្នុងសង្គម ការក្បត់ដើម្បីតែអំណាចរបស់ខ្លួន...។
    - ❖ ចំណែកឯតួអង្គក្នុងរឿង គឺមានលក្ខណៈជាមនុស្ស សត្វ ទេវ អ្នកតា ខ្មោច ព្រាយ បិសាច រុក្ខជាតិ និងវត្ថុមានវិញ្ញាណ ។

**រឿងរាមកេរ្តិ៍ ជារឿងមនុស្ស(ចោទ និងដោះស្រាយបញ្ហាមនុស្ស)**

- ⇨ ទំនាស់គ្រួសារព្រះរាម(ការច្រណែនឈ្នានីសនៃនាងកៃកេសី តែត្រូវដោះស្រាយដោយសន្តិវិធី)។
- ⇨ ទំនាស់ព្រះរាម និងក្រុងរាពណ៍(ឆេវឆាវឥតពិចារណា រហូតសង្គ្រាមសឹកគ្នាមិនចេះចប់)
- ⇨ ជម្លោះនាងសីតា និងព្រះរាម(ការប្រចណ្ឌ ការប្រមាថជីវិត រហូតសីតាមិនជួបព្រះរាមតាមពាក្យសច្ចៈ)។
- ⇨ ជម្លោះព្រះរាម និងរាជបុត្រ(អំណួតនឹងអំណាចច្បាំងគ្នា រហូតស្គាល់គ្នាជាសាច់ឈាម)។

**តួអង្គក្នុងរឿងគ្រប់ប្រភេទ(តំណាងឱ្យមនុស្ស)**

- ⇨ ព្រះរាម មនុស្សមានចរិតល្អ អាក្រក់ អាត្មានិយម។
- ⇨ នាងសីតា មនុស្សមានចិត្តភក្តីភាព ចិត្តរឹងមាំ។
- ⇨ ក្រុងរាពណ៍ បងការពារប្អូន ចូលចិត្តសង្គ្រាមស្នេហាតួនិយម
- ⇨ ពិភេក ជាជនក្បត់ជាតិបម្រើបរទេស នេះក៏ព្រោះតែអំណាច។
- ⇨ ហនុមាន ស្មោះត្រង់នឹងម្ចាស់ បម្រើម្ចាស់ ក្លាហាន។
- ⇨ សូរបនខា ស្រីកាមរាគ បង្កបញ្ហាដល់គ្រួសារ។
- ⇨ ពាលី ស្រឡាញ់ជាតិសាសន៍ រាស្ត្រ សុខចិត្តស្លាប់។
- ⇨ ទូភី ជាកូនមហិង្សារាជ ដើរតាមគន្លងរបស់ឪពុក។

- សរុបសេចក្តី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យយើងឃើញថារឿងរាមកេរ្តិ៍ពិតជារឿងដែលមានលក្ខណៈមនុស្ស ដោយអ្នកនិពន្ធបានលើក

យកសកម្មភាពរបស់តួអង្គគ្រប់ប្រភេទទោះតួអង្គទាំងនោះ ស្ថិតនៅក្នុងស្ថានភាពជាអ្វីក៏ដោយ ក៏សកម្មភាពនៃតួអង្គទាំងនោះបានតំណាងឱ្យបញ្ហា នៃមនុស្សទូទៅនៅក្នុងសង្គម ដែលមានការច្រណែន អាត្មានិយម លោភលន់ ភក្តីភាព ក្លាហានជាដើម។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើនេះយើងឃើញថាមតិរបស់ប្រធានពិតជាមានន័យល្អ ព្រោះបានយល់ច្បាស់ពីធាតុពិត នៃអក្សរសិល្ប៍ ដែលបានលើកយកពីបញ្ហាមនុស្សមកចោទ និងដោះស្រាយតាមរយៈរឿងរាមកេរ្តិ៍ទាំងមូលមកលាតត្រដាង។ នេះចង់សបញ្ជាក់ប្រាប់ដល់អ្នកសិក្សាទូទៅ ឱ្យបានដឹងពីបញ្ហាមនុស្សនៅក្នុងសង្គមសព្វថ្ងៃ ក៏ដូចជាអនាគតត្រូវបានអ្នកនិពន្ធចាប់ច្បិចយកទៅបង្ហាញឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែតស៊ូខិតខំរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវចេះឱ្យតម្លៃលើអត្ថបទអក្សរសិល្ប៍ ដែលជាស្នាដៃរបស់កវីបណ្ឌិតគ្រប់ជំនាន់ ដោយលោកបានខិតខំចងក្រងទុក នូវខ្លឹមសារ អត្ថន័យយ៉ាងច្រើនសម្បូណ៌បែប ប្រៀបបាននឹងកំណប់មាសប្រាក់ មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលទាក់ទងនឹងបញ្ហាមនុស្ស។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី១៧៖** មានទស្សនៈមួយបានលើកឡើងថា៖«រឿងទុំទាវ បានបង្ហាញនូវទំនាស់វណ្ណៈក្នុងសម័យលង្វែក»។ ចូរបង្ហាញ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យោងតាមការសិក្សាអក្សរសិល្ប៍ចលនាខេមរនិយមរបស់ព្រះបទុមត្ថេរសោម យើងឃើញថារឿងទុំទាវបានលាតត្រដាងនូវបញ្ហាសំខាន់ៗក្នុងសង្គមខ្មែរដែលកើតមានជាក់ស្តែងនាសម័យលង្វែក ដោយវាជាបញ្ហាទំនាស់វណ្ណៈដ៏ស្មុគស្មាញប្រទាក់ក្រឡាគ្នា ស្តីអំពីឋានៈ តួនាទី មនុស្សតាំងពីថ្នាក់ទាប រហូតដល់ថ្នាក់កំពូល។
- ចំណូលបញ្ហា៖ ដោយមើលឃើញពីលក្ខណៈប្រការបែបនេះហើយទើបមានទស្សនៈមួយពោលថា៖«រឿងទុំទាវ បានបង្ហាញនូវទំនាស់វណ្ណៈក្នុងសម័យលង្វែក» ដើម្បីទុកជាគតិសម្រាប់ឱ្យយើងសិក្សាពិចារណា។
- ចំណោទបញ្ហា៖ តើភ័ស្តុតាងត្រង់ណាខ្លះដែលបញ្ជាក់ថារឿងទុំទាវជារឿងដែលបានលាតត្រដាងពីបញ្ហាទំនាស់វណ្ណៈ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធានខាងលើឱ្យមានភាពស៊ីជម្រៅកាន់តែល្អនោះយើងគប្បីស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន
- ពន្យល់ពាក្យគន្លឹះ៖ ចំពោះពាក្យទំនាស់វណ្ណៈ មានន័យថាការខ្វែងគំនិតគ្នានៃមនុស្សក្នុងឋានៈ តួនាទីផ្សេងៗគ្នា។

- ពន្យល់ន័យប្រធានៈ ដូចនេះទស្សនៈរបស់ប្រធានមានន័យថា រឿងទុំទាវ បានបង្ហាញនូវការខ្វែងគំនិតគ្នានៃមនុស្សក្នុងឋានៈតួនាទីផ្សេងៗគ្នា។
- បកស្រាយប្រធានៈ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម
  - ❖ ជាការពិតណាស់ទិដ្ឋភាពទំនាស់ក្នុងអក្សរសិល្ប៍ខែមរនិយមនៃរឿងខាងលើ គឺបានបង្ហាញពីបញ្ហានេះ
  - ❖ ទំនាស់ដែលទាក់ទងនឹងអ្នកតូចជាមួយអ្នកធំ
  - ❖ អ្នកមានជាមួយអ្នកក្រ
  - ❖ ហើយហេតុនៃទំនាស់នេះបណ្តាលមកពីទស្សនៈផ្ទុយគ្នា ការដណ្តើមប្រយោជន៍ ការរក្សាតម្លៃជាតិ ទើបបង្កឱ្យមានការកាប់សម្លាប់តស៊ូប្រឆាំងបណ្តាលឱ្យសង្គមវឹកវរតាមរយៈទំនាស់ដូចជា៖
    - ⇨ ទាវមិនឱ្យតម្លៃមាសប្រាក់ អំណាច សុខចិត្តស្រឡាញ់ទុំ ដោយម្តាយទាវនិយមលាភយស មិនគិតពីចិត្តកូន។
    - ⇨ កើតជារឿងទាស់ប្រកែកគ្នាខ្លាំង រហូតម្តាយទាវប្រើគ្រប់វិធីបង្ខំដើម្បីពង្រាត់កូន។
    - ⇨ ម្តាយទាវស្អប់ទុំ ក្ររហាម ជាកូនកសិករ មានចំណេះដឹងតែឥតទ្រព្យ ពុំអាចទ្រទ្រង់ជីវិតទាវបាន។
    - ⇨ ទុំព្យាយាមប្រើគ្រប់វិធី យកទាវជាប្រពន្ធ ដោយតស៊ូ... តែត្រូវបរាជ័យរហូតស្លាប់ខ្លួន។

⇨ អរ ជូនប្រើអំណាច ឃុបឃិតម្តាយទាវ ដើម្បីយកទាវមកការ ដោយមើលងាយទុំជាមន្ត្រីតូច។

⇨ ទុំប្រើបុព្វសិទ្ធិ(សិទ្ធិវរជនត្រូវមានតាមមុខតំណែង)ខ្លួនតតាំង អរ ជូនរួមកម្លាំងខ្លួនឯងរហូតបានយុត្តិធម៌។

⇨ ម្តាយទាវដៀល អរ ជូន រួចបង្ខំអរ ជូន ឱ្យយកទុំទៅសម្លាប់ចោលលុះទីបំផុតវិនាសទាំងពីរ។

⇨ ស្តេចយាងមកកាត់ទោស ម្តាយទាវ អរ ជូន អ្នកត្បូងឃ្មុំដែលហ៊ានបំពានរាជអាជ្ញា(ដោយទទួលរងការរិះគន់ថាខឹងគោ វាយរទេះ)។

- សរុបសេចក្តី៖ សរុបសេចក្តីមកក្រោយពីបានធ្វើការបកស្រាយបញ្ហាក់ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថា វាល់ទង្វើរបស់តួរអង្គខាងលើមកពីបញ្ហា ទំនាស់ក្នុងគ្រួសារ(ទាវ និងម្តាយ) ទំនាស់អ្នកមាន និងអ្នកក្រ(ទុំ និងម្តាយទាវ) ទំនាស់បុណ្យសក្តិ(ទុំតតាំងជាមួយអរ ជូន) ទំនាស់អ្នកមានទ្រព្យ និងអ្នកមានអំណាច(ម្តាយទាវ និងអរ ជូន) ទំនាស់រវាងអ្នកធំ និងអ្នកតូច(ស្តេច និងម្តាយទាវ អរ ជូន) លុះជាលទ្ធផលបានត្រឹមតែវិនាសទាំងសងខាង និងបានធ្វើឱ្យសង្គមជាតិជួបប្រទះនូវការអន់ថយស្ទើរតែគ្រប់បែបយ៉ាង។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើនេះ ពិតជាផ្តល់តម្លៃអប់រំយ៉ាងល្អជ្រាលជ្រៅ ដល់សាធុជនទាំងឡាយឱ្យបាន

ស្គាល់ពីផលនៃបញ្ហាទំនាស់វណ្ណៈ ដែលមាននៅក្នុងសង្គមខ្មែរនាសម័យលង្វែក ក៏ដូចជាសម័យនាពេលបច្ចុប្បន្ននេះ និងចេះដកស្រង់នូវបទពិសោធទាំងនោះ យកមកទុកជាគត់ក្នុងការពិចារណាទៅថ្ងៃអនាគត។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាសិក្ខាកាម ត្រូវខិតខំបន្តនូវការសិក្សារៀនសូត្រឱ្យបានខ្ពង់ខ្ពស់ ហើយត្រូវតាំងស្មារតីបញ្ចៀសឱ្យបានជាដាច់ខាត នូវបញ្ហាទំនាស់គ្រប់បែបយ៉ាងដើម្បីជួយសម្រួលដល់ការកសាងសង្គមជាតិឱ្យមានភាពរីកចម្រើនទៅថ្ងៃអនាគត។
- ពាក្យស្លោក ឬសុភាសិត៖ សមនឹងទស្សនៈមួយពោលថា៖«ជម្លោះនាំគ្រោះគ្មានចំណេញ ស្រុះស្រួលគ្នាវិញប្រសើរជាជាង»។

**ប្រធានទី១៨៖** គេយល់ថា៖«ទោះបីមានប្រភព ពីរឿងរាមាយណៈឥណ្ឌា ក៏រឿងរាមកេរ្តិ៍ខ្មែរបានរក្សានូវអត្តសញ្ញាណជាតិខ្មែរជានិច្ច»។ ចូរពន្យល់ដោយលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ នៅក្នុងវណ្ណកម្មអក្សរសិល្ប៍បុរាណក្តី អក្សរសិល្ប៍ទំនើបក្តី អក្សរសិល្ប៍ប្រជាប្រិយក្តីសុទ្ធតែត្រូវបានអ្នកនិពន្ធខិតខំសម្រិតសម្រាំង នូវគំនិត និងសិល្បវិធីរបស់ខ្លួនប្រកបដោយភាពប៉ិនប្រសប់រៀងៗខ្លួន ដើម្បីទាក់ទាញនូវអារម្មណ៍របស់អ្នកអានអ្នកសិក្សាស្លុងអារម្មណ៍ទៅលើស្នាដៃទាំងនោះផងដែរ។ លើសពីនេះទៅទៀតអ្នកនិពន្ធក៏មិនបំភ្លេចដែរ នូវការបញ្ចូលផ្នត់គំនិតនិងទំនៀមទម្លាប់ប្រពៃណី ដែលជាអត្តសញ្ញាណជាតិរបស់ខ្មែរមានតាំងពីយូរលង់ណាស់មកហើយ ទៅក្នុងស្នាដៃខ្លួន។
- ចំណូលបញ្ហា៖ ដោយមានមូលហេតុនេះហើយ ទើបមានទស្សនៈមួយគេយល់ថា៖«ទោះបីមានប្រភព ពីរឿងរាមាយណៈឥណ្ឌា ក៏រឿងរាមកេរ្តិ៍ខ្មែរបានរក្សានូវអត្តសញ្ញាណជាតិខ្មែរជានិច្ច»។
- ចំណោទបញ្ហា៖ តើចំណុចត្រង់ណាដែលបញ្ជាក់ថា រឿងរាមកេរ្តិ៍ខ្មែរ បានរក្សានូវអត្តសញ្ញាណជាតិខ្មែរជានិច្ចនោះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ...
- ពន្យល់ពាក្យគន្លឹះ៖ អត្តសញ្ញាណជាតិខ្មែរ មានន័យថាអ្វីៗគ្រប់យ៉ាង ដែលជាគ្រឿងសម្គាល់របស់ជាតិខ្មែរ...។

- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះដែលបានពន្យល់រួចទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម
  - ❖ ជាការពិតណាស់រឿងរាមកេរ្តិ៍ខ្មែរមានប្រភពមកពី រឿងរាមាយណៈក៏ពិតមែន ប៉ុន្តែរឿងនេះក៏បានរក្សានូវអត្តសញ្ញាណជាតិខ្មែរជាច្រើន។ ផ្ទៃរឿងបានលាតត្រដាងពីប្រពៃណីទំនៀមទម្លាប់ខ្មែរដូចជាការរៀបមង្គលការ ការឱ្យតម្លៃស្ត្រីជាធំ ការប្រកាន់ជំនឿ ការរៀបពិធីបុណ្យជាតិជាដើម ...................................................................................។
  - ❖ ឧទាហរណ៍ក្នុងសាច់រឿងបានបង្ហាញពីអត្តសញ្ញាណជាតិខ្មែរដូចជា៖
    - ⇨ មាតាបិតានិយមជ្រើសរើសគូស្រករឱ្យកូនដោយឱ្យតម្លៃទៅលើសមត្ថភាពកូនកំលោះ។ ឧទាហរណ៍ ការល្បងលើកធ្នូសរ ជ្រើសរើសរកសុណិសារបស់ព្រះបាទជនក...។
    - ⇨ ខ្មែរឱ្យតម្លៃទៅលើគ្រូដែលជាអ្នកអប់រំបង្រៀនសិស្សឱ្យទៅជាអ្នកខ្លាំងពូកែ...។ ឧទាហរណ៍ ព្រះរាមខ្លាំងពូកែដោយសារឥសីពិស្វាមិត្របានបង្ហាត់បង្រៀនគួបផ្សំនឹងមហិទ្ធិឫទ្ធិអាទិទេព អវតារព្រះវិស្ណុ។

⇨ រៀបការកូននៅផ្ទះខាងស្រីតាមរបៀបមាតាធិបតេយ្យ ឧទាហរណ៍ ព្រះរាមរាជាភិសេក និងនាងសីតានៅនគរមិថិលា។

⇨ ការគោរពពាក្យសត្យមិននិយាយបាតដៃខ្នងដៃ...។ ឧទាហរណ៍ ព្រះបាទជនកលើកសីតាឱ្យទៅព្រះរាមតាមសន្យា។ ព្រះបាទទសរថប្រគល់រាជ្យសម្បត្តិឱ្យទៅព្រះភិរុតតាមពាក្យសច្ចៈ។ ព្រះរាមមិនយាងចូលគ្រងរាជ្យបើមិនបានបួសជាតាបស គម្រប់១៤ឆ្នាំ។

⇨ នាងសីតាមិនយាងចូលនគរវិញទេ កាលណាព្រះរាមមិនទាន់ចូលទិវង្គត។

⇨ ខ្មែរមានជំនឿថា សត្វកុក ខ្លែងស្រាក់ លលកខ្មោច ជាសត្វចង្រៃ។ ឧទាហរណ៍ កុកនាំសម្តីនាងសីតាទៅប្រាប់ព្រះរាម និងព្រះលក្ស្មណ៍ បែរជាមានទោស។

⇨ ពិធីច្រត់ព្រះរាជនង្គ័ល គឺជាប្រពៃណីខ្មែរតាំងពីសម័យអង្គរមកម្ល៉េះ ដែលប្រារព្ធដើម្បីសុំពរជ័យក្នុងរបរកសិកម្ម ។ ឧទាហរណ៍ ព្រះបាទជនកបានប្រារព្ធពិធីច្រត់ព្រះនង្គ័លនៅមាត់ស្ទឹងយមុនា។

- សរុបសេចក្តី៖ សរុបសេចក្តីមកឃើញថា ខ្មែរពិតជាបានរក្សានូវអត្តសញ្ញាណជាតិ របស់ខ្លួនមែន ទោះបីខ្មែរចម្លងពីឥណ្ឌាក៏ដោយ

**គ. សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន៖ មតិរបស់ប្រធានមានខ្លឹមសារល្អ ហើយបានអប់រំកូនខ្មែរឱ្យស្គាល់នូវអត្តសញ្ញាណជាតិរបស់ខ្លួន...។

- *ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមជាកូនខ្មែរជំនាន់ក្រោយគប្បីថែរក្សាមរតកវប្បធម៌ទាំងនេះឱ្យបានគង់វង្សដើម្បីទុកឱ្យ...។*
- *ពាក្យស្លោក ឬសុភាសិត*

**ប្រធានទី១៩៖** ទស្សនៈមួយបានចែងថា៖ "យុត្តិធម៌ តែងឈ្នះលើអយុត្តិធម៌"។ ចូរពន្យល់ដោយលើកឧទាហរណ៍ ពីក្នុងជីវតថ និងពីក្នុងស្នាដៃអក្សរសិល្ប៍នានា ដែលអ្នកបានសិក្សារួចយកមកបញ្ជាក់ផង។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យោងទៅតាមផ្នែកបរិបទនៃសង្គម គេតែងតែធ្វើការសង្កេតឃើញថាសង្គមដែលអនុវត្តច្បាប់បានល្អត្រឹមត្រូវ នឹងបានចូលរួមលើកតម្កើងនូវសេចក្តីយុត្តិធម៌ ចំណែកឯសេចក្តីអយុត្តិធម៌វិញ នឹងត្រូវបរាជ័យទាំងស្រុងព្រោះមានមនុស្សភាគច្រើនបានឱ្យតម្លៃទៅលើភាពយុត្តិធម៌ រីឯភាពអយុត្តិធម៌គេតែងតែស្អប់ខ្ពើមដើរចៀសគ្រប់ៗគ្នា។
- ចំណូលបញ្ហា៖ អាស្រ័យដោយមានលំនាំជាតឹកតាងបែបនេះហើយទើបមានទស្សនៈមួយបានចែងថា៖ "យុត្តិធម៌ តែងឈ្នះលើអយុត្តិធម៌" ទុកសម្រាប់ឱ្យសិក្ខាកាមទូទៅធ្វើការស្វែងយល់។
- ចំណោទបញ្ហា៖ តើយុត្តិធម៌បានឈ្នះ លើអយុត្តិធម៌ក្នុងជីវតថ និងក្នុងស្នាដៃអក្សរសិល្ប៍យ៉ាងដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពស៊ីជម្រៅ និងកាន់តែល្អនោះយើង គប្បីស្វែងយល់ឱ្យបានច្បាស់ នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ យុត្តិធម៌ មានន័យថាភាពទៀតត្រង់ ត្រឹមត្រូវ។ អយុត្តិធម៌ មានន័យថាភាពលម្អៀង ដែលវៀរចាកភាពត្រឹមត្រូវ។
- ពន្យល់ន័យប្រធាន៖ ដូចនេះទស្សនៈរបស់ប្រធានមានន័យថាភាពទៀតត្រង់ ត្រឹមត្រូវ តែងឈ្នះលើ ភាពលម្អៀងដែលវៀរចាកភាពត្រឹមត្រូវ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការត្រឹមត្រូវណាស់នៅក្នុងជីវភាពរស់នៅរបស់ប្រជាជនទាំងអស់មានការគ្រប់គ្រងពីសំណាក់រដ្ឋអំណាច ដើម្បីផ្តល់នូវសន្តិសុខ សុវត្ថិភាពដល់ប្រជាជនគ្រប់រូប។ ដូចនេះហើយទើបមានពំនោលមួយចែងថា យុត្តិធម៌តែឈ្នះលើភាពអយុត្តិធម៌ វាជាការត្រឹមត្រូវណាស់។
  - ❖ រូបភាពនៃសេចក្តីយុត្តិធម៌៖ ការប្រកាន់លើភាពត្រឹមត្រូវភាពគ្មានលម្អៀង ប្រកាន់ពាក្យសច្ចៈក្នុងភាពត្រឹមត្រូវ មិនកេងបន្លំ ជិះជាន់សង្កត់កគេ...។
  - ❖ ភាពអយុត្តិធម៌ធ្វើឱ្យមនុស្សចងគំនុំ បង្កើតភាពពុករលួយ...
  - ❖ សេចក្តីពិតតែងឈ្នះភាពក្លែងក្លាយ ភាពមិនច្បាស់...។
  - ❖ មនុស្សទូទៅប្រាថ្នាចង់បាននូវយុត្តិធម៌ដើម្បីបម្រើដល់ផលប្រយោជន៍មនុស្សជាតិទាំងពួង។ តាមច្បាប់រដ្ឋ របស់ប្រទេសនីមួយៗ លើពិភពលោកបានចែងនូវបញ្ញត្តិសម្រាប់ឱ្យប្រជាពលរដ្ឋគោរព និងអនុវត្តតាមគោលបំណងសំខាន់

គឺរក្សាសណ្ដាប់ធ្នាប់ សន្តិសុខសង្គម ដោយបំបាត់អំពើទុច្ចរិត ពុករលួយ ការយល់ញ្ញាតិឃ្លាតច្បាប់។

- ករណីមានបទល្មើស ឬរំលោភបំពានច្បាប់ យើងមានសិទ្ធិស្វែងរកយុត្តិធម៌ជូន ដល់ជនរងគ្រោះដោយអង្គតុលាការ អង្គការសិទ្ធិមនុស្សជាអ្នកដោះស្រាយ។
- ជនដែលល្មើសត្រូវបញ្ជូនទៅតុលាការដើម្បីកាត់ទោសតាមកំហុស។

**ឧទាហរណ៍ក្នុងជីវិតថ**

- យោងតាមភាពជាក់ស្ដែងដែលមាននៅក្នុងជីវិតថបាន បង្ហាញដល់ប្រជាពលរដ្ឋក្នុងប្រទេសថា បានបង្កើតច្បាប់សម្រាប់ជាបញ្ញត្តិ ក្នុងតុលាការ ដើម្បីវិនិច្ឆ័យរកភាពត្រឹមត្រូវ ជូនប្រជារាស្ត្រ។ ពលរដ្ឋនឹងរស់នៅប្រកបដោយភាពសុខសាន្ត ពឹងផ្អែកចំបងលើយុត្តិធម៌ដែលជាស្ពានសម្រាប់ចម្លងប្រជាពលរដ្ឋឆ្ពោះទៅត្រើយសុភមង្គល។ម្យ៉ាងទៀតយុត្តិធម៌រក្សា នូវភាពស្ងប់សុខគ្មានការបះបោរឡើយ។
- ក្រុមបនប្រល័យពូជសាសន៍ ត្រូវបានកាត់ទោសជាបន្តបន្ទាប់ ដោយតុលាការកូនកាត់ ដែលមានឈ្មោះថាតុលាការ អង្គជំនុំជម្រះវិសាមញ្ញ។

**ឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍**

- រឿងចចក និងកំពឹស(ចចកត្រូវទទួលបរាជ័យពីសំណាក់ពួកមច្ឆា)។

- ⇨ រឿងទុំទាវ(ម្តាយទាវ គ្រួសារអរ ជូន មានបំណងអាក្រក់ យកទុំទៅសម្លាប់ត្រូវទទួលទោស...)។
- ⇨ រឿងព្រះវេស្សន្តរ(ព្រះអង្គដាក់ទានដំរី មិនពិគ្រោះនឹង រាស្ត្រៗមានសិទ្ធិប្តឹងរកយុត្តធម៌...)។
- ⇨ រឿងភូមិតិរច្ឆាន(ភាពអយុត្តិធម៌របស់ប្រជាជនដែល បារាំងបានបង្កទីបំផុតបារដេសជាមេគំនិតត្រូវទទួល ផលរបស់ខ្លួន...)។
- ⇨ រឿងសព្វសិទ្ធិ(តួរអង្គភីលៀង របស់សព្វសិទ្ធិត្រូវស្លាប់ បន្ទាប់ពីនាងសុវណ្ណកេសរ ប្រើល្បិចឱ្យដកវិញ្ញាណចូល ក្នុងសត្វប្រើសស្លាប់មួយ បន្ទាប់ពីគេបានក្បត់នឹងសព្វ សិទ្ធិ ក្នុងបំណងយកនាងសុវណ្ណកេសរធ្វើជាភរិយា។

- សរុបសេចក្តី៖ សរុបសេចក្តីជារួមមក ក្រោយពីបានធ្វើការបក ស្រាយយ៉ាងលម្អិតឃើញថាយុត្តិធម៌ ដែលជាតម្រូវការរបស់ប្រជា ជនពិតជាបានឈ្នះលើភាពអយុត្តិធម៌ដែរ ក្នុងករណីច្បាប់រដ្ឋមិន មានប្រសិទ្ធភាពនោះ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ឆ្លងតាមរយៈការបកស្រាយ យ៉ាងក្បោះក្បាយរួចរាល់ខាងលើមកនេះ យើងអាចវាយតម្លៃបាន ថា ប្រធានខាងលើពិតជាបង្កប់នូវអត្ថន័យ ខ្លឹមសារល្អយ៉ាងជ្រាល ជ្រៅ ព្រោះបានលើកពីច្បាប់ នៃភាពត្រឹមត្រូវសម្រាប់កសាង សង្គមឱ្យរីកចម្រើនរុងរឿង ដោយឈរលើយុត្តិធម៌អព្យាក្រឹត្យ។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាកូនខ្មែរ ជាយុវសិស្សជំនាន់ក្រោយ គប្បីខិតខំប្រឹងប្រែសិក្សារៀនសូត្រយកចំណេះដឹង ដើម្បីពង្រឹងផ្សព្វផ្សាយលទ្ធិប្រជាធិបតេយ្យស្រឡាញ់ភាពយុត្តិធម៌មិនលម្អៀង គោរពច្បាប់របស់ប្រទេស ស្របតាមច្បាប់របស់រដ្ឋធម្មនុញ្ញនៃកម្ពុជា។ ខ្ញុំសូមឆ្លើយថាទេចំពោះ«អំពើអយុត្តិធម៌»។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២០៖** មានមតិខ្លះយល់ថា៖“បើតាមផ្លូវលោក ការធ្វើទានរបស់ព្រះវេស្សន្តរ មិនអាចជួយរាស្ត្រឱ្យរួចផុត ពីសេចក្តីទុក្ខបានទេ ឯតាមផ្លូវធម៌ក៏មិនអាចជួយខ្លួនឯងឱ្យរួចផុតពីយមរាជបានដែរ”។ ចូរពិភាក្សាដោយលើកយកសំអាងមកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យោងតាមការសិក្សាអក្សរសិល្ប៍ប្រភេទបុរាណ នៃចលនាអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ ដែលស្ថិតនៅក្នុងគម្ពីរទសជាតកបានធ្វើឱ្យយើងឃើញថា ក្នុងរឿងមហាវេស្សន្តរជាតក គឺជារឿងមួយដែលបង្ហាញពីព្រះរាជសកម្មភាព របស់ព្រះពោធិសត្វនៃជាតិទីដប់។ ក្នុងជាតិទីដប់នេះព្រះអង្គបានបំពេញទានបារមី ដែលគេហៅថាមហាបញ្ចបរិច្ចាគទាន រួមមានធនបរិច្ចាគ ជីវិតបរិច្ចាគ អវយវៈបរិច្ចាគ បុត្តបរិច្ចាគ និងទានបរិច្ចាគជាដើម។
- ចំណូលបញ្ហា៖ អាស្រ័យដោយមានលំនាំបែបនេះហើយ ទើបមានមតិខ្លះយល់ថា៖“បើតាមផ្លូវលោក ការធ្វើទានរបស់ព្រះវេស្សន្តរ មិនអាចជួយរាស្ត្រឱ្យរួចផុត ពីសេចក្តីទុក្ខបានទេ ឯតាមផ្លូវធម៌ក៏មិនអាចជួយខ្លួនឯងឱ្យរួចផុតពីយមរាជបានដែរ”។
- ចំណោទបញ្ហា៖ តើទស្សនៈមតិដែលបានពោលខាងលើនេះត្រឹមត្រូវឬទេ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ

យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ពាក្យផ្លូវលោក មានន័យថាដំណើរនៃការរស់នៅរបស់មនុស្សប្រចាំថ្ងៃ។ ពាក្យផ្លូវធម៌ មានន័យថាការកសាងបុណ្យកុសលសម្រាប់ទៅអនាគតជាតិ។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថា បើតាមដំណើរនៃការរស់នៅរបស់មនុស្សប្រចាំថ្ងៃ ការធ្វើទានរបស់ព្រះវេស្សន្តរមិនអាចជួយរាស្ត្រឱ្យរួចផុត ពីសេចក្តីទុក្ខបានទេ ឯបើតាមការកសាងបុណ្យកុសលសម្រាប់ទៅអនាគតជាតិ របស់ព្រះអង្គ ក៏មិនអាចជួយខ្លួនព្រះអង្គឱ្យរួចផុតពីទីយមរាជដែរ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តាររួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
    - ❖ ជាការពិតណាស់នៅក្នុងជាតិទីដប់ នៃអតីតជាតិរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង គឺជាជាតិដែលព្រះអង្គបានលះបង់នូវទានដ៏កម្រ ដែលមិនមានបុគ្គលផ្សេងក្រៅពី ព្រះអង្គធ្វើបានឡើយ។ ទាក់ទងទៅនឹងបញ្ហារបស់ប្រធានខាងលើនេះធ្វើឱ្យមតិរបស់ប្រធានបានលើកឡើងថា៖«បើតាមផ្លូវលោក ការធ្វើទានរបស់ព្រះវេស្សន្តរ មិនអាចជួយរាស្ត្រឱ្យរួចផុត ពីសេចក្តីទុក្ខបានទេ ឯតាមផ្លូវធម៌ក៏មិនអាចជួយខ្លួនឯងឱ្យរួចផុតពីយមរាជបានដែរ»។ មតិនេះពិតជាសមហេតុផលសមផលព្រោះ៖

**តាមផ្លូវលោក**

⇨ ការធ្វើទាននេះមិនបានធ្វើឱ្យរាស្ត្ររបស់ទ្រង់រួចផុត ពីភាពក្រីក្រទេ ព្រោះការឱ្យទាននេះទ្រង់មិនបានយល់ពីបញ្ហារបស់សង្គមឡើយ គឺចេះតែឱ្យនៅពេលដែលគេមកសុំ។

⇨ ទានមិនបានធ្វើឱ្យប្រជារាស្ត្រមានភាពធូរធារឡើយ ប៉ុន្តែផ្ទុយទៅវិញបែរជានាំឱ្យរាស្ត្រកាន់តែមានជីវភាពដុនដាបទៅៗព្រោះមធ្យោបាយនេះ គឺបានត្រឹមតែធ្វើឱ្យរាស្ត្រកាន់តែក្រ និងខ្ជិល។

**តាមផ្លូវធម៌**

⇨ ទានមិនអាចឱ្យព្រះអង្គរួចផុតពីទីយមរាជទេ ព្រោះបានប៉ះពាល់ដល់ជីវិតរបស់ប្រពន្ធកូន...។

⇨ ការធ្វើទានរបស់ព្រះវេស្សន្តរ ជាប្រយោជន៍សួនតួ...។

**ឧទាហរណ៍**

⇨ ពេលដាក់ទានកូន ដល់ជូជកព្រាហ្មណ៍...។

⇨ ដាក់ទានប្រពន្ធដល់ឥន្ទព្រាហ្មណ៍...។

+ សរុបមតិស្រប៖ សរុបសេចក្តីមក ឃើញថាការបកស្រាយខាងលើពិតជាបង្ហាញថា ការធ្វើទានរបស់ព្រះវេស្សន្តរពិតជាបង្ហាញថា ការធ្វើទានរបស់ព្រះវេស្សន្តរពិតជាមិនអាចជួយរាស្ត្រឱ្យរួចផុតសេចក្តីទុក្ខ និងក៏មិនអាចជួយខ្លួនព្រះអង្គឱ្យរួចផុត ពីទីយមរាជបានដែរ។ ការយល់ឃើញ បែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

+ មតិផ្ទុយ៖ ផ្ទុយទៅវិញបើយើងពិនិត្យឱ្យបានម៉ត់ចត់ទៅការធ្វើទានរបស់ព្រះអង្គ គឺ៖

- ✓ បានជួយឱ្យសង្គមគ្មាននូវសង្គ្រាម
- ✓ រស់នៅដោយសុខសន្តិភាព
- ✓ ចេះចែករំលែកនូវអ្វីដែលមានឱ្យទៅដល់អ្នកដែលទន់ខ្សោយ...។

**ឧទាហរណ៍**

⇨ ចុងបញ្ចប់នៃរឿង រាស្ត្រយល់ពីតម្លៃនៃការធ្វើទានរបស់ព្រះអង្គ ក៏នាំគ្នាទៅយាងព្រះអង្គចូលនគរវិញ និងបានបង្ហាញពីការសោយសម្បត្តិទិព្វ ក្នុងឋានតុសិតទេវលោក របស់ក្រុមរាជវង្សនៃព្រះវេស្សន្តរ...។

+ សរុបមតិផ្ទុយ៖ សរុបសេចក្ដីមកឃើញថា ការធ្វើទានរបស់ព្រះវេស្សន្តរ ពិតជាអាចជួយរាស្ត្រឱ្យរួចផុតពីទឹយមរាជពិតប្រាកដមែន។ ការយល់បែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- ពិភាក្សាមតិ៖ ជារួមមកយើងឃើញថា ការបកស្រាយបង្ហាញខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និដ្ឋានបានថា មតិទីមួយដែលបានលើកឡើង ពុំបានឃើញពីគុណតម្លៃរបស់ទានក្នុងការជួយសង្គ្រោះទុគ៌តជន ដែលកំពុងត្រូវការជំនួយជួយសង្គ្រោះ និងការផ្ដល់ឱកាសឱ្យជីវិតមានសង្ឃឹមទេ។ ឯមតិទីពីរវិញមានន័យយល់បានទូលំទូលាយ ហើយបានធ្វើការស្រាវជ្រាវឱ្យឃើញថាការធ្វើទានពិតជាអាចធ្វើឱ្យរាស្ត្ររួចចាកពីភាពក្រីក្រលំបាកនឹងធ្វើឱ្យខ្លួនទទួលបាននូវបុណ្យកុសល សម្រាប់អនាគតជាតិ។

### គ. សេចក្តីបញ្ចប់

- *វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយបង្ហាញខាងលើ អាចសបញ្ជាក់ឱ្យឃើញថា ទស្សនៈរបស់ប្រធានខាងលើ ដែលបានលើកឡើងជាមតិដែលពុំត្រឹមត្រូវនោះទេ ព្រោះជាមតិដែលមើលឃើញតែភាពអវិជ្ជមាន នៃការធ្វើទានតែប៉ុណ្ណោះ ហើយក៏ពុំបានឆ្លុះបញ្ចាំងឱ្យឃើញ ពីសារប្រយោជន៍ដ៏ធំធេងនៃទានក្នុងការអភិវឌ្ឍសង្គមឡើយ។ ឯមតិទីពីរវិញជាមតិដែលត្រឹមត្រូវ ព្រោះបានបកស្រាយយ៉ាងច្បាស់គ្មានស្រពិចស្រពិលសោះឡើយ ដែលទាក់ទងទៅនឹងតម្លៃ នៃសេចក្តីល្អ ដែលកើតចេញមកពីការលះបង់ នូវអ្វីៗដើម្បីដោះស្រាយបញ្ហាទុក្ខលំបាកនៃអ្នកដទៃ ក៏ដូចជាដើម្បីផលអានិសង្សសម្រាប់ខ្លួន ឆ្ពោះទៅបរលោកនាយ។*
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវចេះលះបង់នូវកម្លាំងចិត្ត ចំណេះបញ្ញា ធនធានដែលខ្លួនមានខ្លះៗដើម្បីជួយដល់ជនក្រីក្រតោកយ៉ាក ដោយចិត្តសោមនស្សរីករាយក្រៃលែងបំផុត។
- *ពាក្យស្លោក ឬសុភាសិត*

**ប្រធានទី២១៖** ព្រះតេមិយមានបន្ទូលថា៖“នែនាយសារថី! បើអ្នកកប់ខ្ញុំក្នុងព្រៃនេះអ្នកមានឈ្មោះថាធ្វើខុសច្បាប់”។ ផ្អែកហេតុការណ៍សង្គម និងអក្សរសិល្ប៍ដែលបានសិក្សា រួចចូរបង្ហាញពីផលអាក្រក់ នៃការប៉ះពាល់ ដល់សិទ្ធិមានជីវិតនៃអ្នកដទៃ។

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ ព្រះពោធិសត្វជាតំណាងឱ្យអ្នក ដែលមានចិត្តមានសេចក្ដីប្រាថ្នាជាប់ជានិច្ចនៅក្នុងពោធិ ឬសំដៅលើអ្នកដែលកំពុងខំប្រឹងបំពេញបារមីបម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ហើយមកប្រោសសត្វលោកឱ្យចាកផុត ពីទុក្ខទោស គ្រប់សារពើ និងដើម្បីឱ្យនរជនទូទៅយល់ច្បាស់ពីច្បាប់នៃផ្លូវលោក និងផ្លូវធម៌។
- ចំណូលបញ្ហា៖ ហេតុដូចនេះហើយបានជាតួអង្គពោធិសត្វ ក្នុងជាតិជាព្រះតេមិយកុមារ បានមានព្រះបន្ទូលទៅកាន់នាយសុនន្ទថា៖“នែនាយសារថី! បើអ្នកកប់ខ្ញុំក្នុងព្រៃនេះអ្នកមានឈ្មោះថាធ្វើខុសច្បាប់”។
- ចំណោទបញ្ហា៖ តើពំនោលបែបនេះបានសេចក្ដីយ៉ាងដូចម្ដេច? ហើយយោងទៅតាមទង្វើ របស់នាយសារថីបានផ្ដល់ជាផលអាក្រក់នៃការប៉ះពាល់ ដល់សិទ្ធិមានជីវិត នៃអ្នកដទៃយ៉ាងណាខ្លះ?

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ...

- ពន្យល់ពាក្យគន្លឹះ៖ សារថី មានន័យថាអ្នកបរទេះ។ សិទ្ធិមានជីវិត មាននន័យថាសិទ្ធិការពារជីវិតឱ្យបានគង់វង្ស។ ច្បាប់ មានន័យថាវិន័យសម្រាប់ ឱ្យមនុស្សប្រព្រឹត្តិល្អ។
- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះដែលបានពន្យល់រួចទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផលនិងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការពិតណាស់ជីវិតមនុស្សយើងម្នាក់ៗ កើតមកលើលោកសន្និវាសយើងនេះ សុទ្ធតែត្រូវមានសិទ្ធិជាមូលដ្ឋានជាចាំបាច់ ព្រោះការធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតរបស់អ្នកដទៃនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ ចំណែកបន្ទូលរបស់ព្រះពោធិសត្វ ខាងលើមានន័យដូចតទៅ៖
    - ⇨ បើអ្នកកប់ខ្ញុំ ក្នុងរណ្តៅនេះអ្នកនឹងមានទោសជាដាច់ខាត ព្រោះខ្ញុំមិនមែនជាមនុស្សគ ថ្លង់ ខ្វិនខ្វង់។
    - ⇨ តេមិយធ្វើការតវ៉ា នឹងទង្វើនាយសារថី ក៏ដូចជាតវ៉ានឹងរាជបញ្ជាព្រះបាទកាសិករាជដើម្បីការពារសិទ្ធិរស់រានមានជីវិត។
    - ⇨ ព្រះអង្គមានបន្ទូលនេះចង់ឱ្យយើងយល់ ពីផ្លូវពុទ្ធចក្រ និងផ្លូវអាណាចក្រ(ពុទ្ធសាសនាជាសាសនារបស់រដ្ឋ)។
    - ⇨ ផ្លូវពុទ្ធចក្រ ឬផ្លូវធម៌(សីលប្រាំ ឬនិច្ចសីល ជាពិសេសសីល“បាណាតិបាត”)

⇨ ផ្លូវអាណាចក្រ កាន់តែច្បាស់ជាងពុទ្ធចក្រព្រោះបាននាំគ្នាបង្កើតច្បាប់សម្រាប់ពិន័យ ឬដាក់ទោសដល់ជនទាំងឡាយណាដែលល្មើសនឹងច្បាប់។

⇨ បើផ្អែកលើសេចក្តីថ្លែងការជាសកលស្តីពីបញ្ហាសិទ្ធិមនុស្សត្រង់មាត្រាទីបី បានចែងយ៉ាងច្បាស់ពីកិច្ចការពារដល់សិទ្ធិមានជីវិតដែរ។

⇨ មាត្រាទីសាមសិបពីរនៃច្បាប់រដ្ឋធម្មនុញ្ញចែងថា៖ «ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ដោយទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ»។

⇨ មាត្រាទីសាមសិបប្រាំបីចែងដែរថា៖ «ច្បាប់ធានារ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលមួយណាឡើយ ថែមទាំងការពារកិត្តិយសសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ»។

⇨ ទាំងផ្លូវពុទ្ធចក្រ និងអាណាចក្រមិនអនុញ្ញាតឱ្យសម្លាប់មនុស្សឡើយព្រោះ(ពុទ្ធចក្រនឹងមានកម្មតបស្នង...ឯអាណាចក្រនឹងទទួលទោសទណ្ឌតាមកម្រិតស្រាល ឬធ្ងន់)។

**ឧទាហរណ៍ (អាណាចក្រ)**

⇨ រឿងទុំទាវ(អរ ជូន សម្លាប់ទុំ ចុងក្រោយត្រូវស្តេចរាមាផ្តន្ទាទោសទាំងពោសន្តាន...ម្តាយទាវ និងអ្នកត្បូងឃ្មុំដែលបានលាក់បាំងទង្វើពួក អរ ជូន ត្រូវទទួលទោស)

⇨ រឿងថៅកែចិត្តចោរ(ពូហំបានប្រព្រឹត្ត បទឧក្រិដ្ឋ ដោយចង់បានប្រាក់មួយម៉ឺនរៀល តាមការបញ្ជារបស់ថៅកែ លុះទីបំផុតត្រូវជាប់គុក)។

⇨ រឿងកូលាបប៉ៃលិន(ប្រាល័ដ្ឋ និងមេចោរផាន់បានរួមគំនិតគ្នាទៅប្លន់ និងបៀតបៀនជីវិតរបស់ក្រុមគ្រួសាររបស់លោកហ្លួង លុះចុងក្រោយត្រូវបាត់បង់ជីវិត...)។

**ឧទាហរណ៍ (ធម្មចក្រ)**

⇨ រឿងពុទ្ធិសែន នាងកង្រី(នាងទាំង១២ កាលពីអតីតជាតិបានដោយភ្នែកត្រីទាំងសងខាង តែនាងពៅបានដោតភ្នែកត្រីតែម្ខាង ទើបក្នុងរឿងនេះនាងទាំង១២ត្រូវយក្សខ្វេះភ្នែកវិញ លើកលែងតែនាងពៅត្រូវយក្សខ្វេះតែម្ខាង)។

⇨ រឿងទុំទាវ(ដោយសារតែកម្មរបស់ទុំតាំងពីជាតិមុន ទើបតម្រូវឱ្យទុំត្រូវស្លាប់ ព្រោះតាមរយៈសាច់រឿងបានបញ្ជាក់ថា អរ ជូន គឺជាស្តេចត្រាញ់ ដែលល្អប្រចាំនៅខេត្តត្បូងឃ្មុំមានរាស្ត្រគោរពស្រឡាញ់ច្រើន ចំណែកឯម្តាយទាវ ក៏ជាមនុស្សចេះធ្វើបុណ្យទាន បើនាងទាវវិញក៏ជាកុលស្ត្រី ដែលគោរពប្រពៃណីស្តាប់ដំបូន្មានម្តាយ លុះទុំមកដល់ ធ្វើឱ្យអ្នកទាំង៣ខាងលើប្រែប្រួល ក៏ព្រោះកម្មរបស់ទុំ)។

- សរុបសេចក្តី៖ សរុបសេចក្តីមកយោងតាម ការបកស្រាយបង្ហាញខាងលើ សបញ្ជាក់ឱ្យឃើញថាការលើកឡើងនូវបណ្តាអំណះ

អំណោងទាំងក្នុងសង្គម ក៏ដូចជាក្នុងអក្សរសិល្ប៍ ជាហេតុនាំឱ្យគេនិយាយបានថាអ្នកដែលប៉ះពាល់ដល់ជីវិតអ្នកដទៃ រមែងទទួលកម្មតបស្នងវិញ ដោយលើកលែងពុំបាន បើមិនជាតិនេះ ក៏ជាតិក្រោយដោយផ្អែកលើទស្សនៈកម្មផល រួមផ្សំនឹងផ្លូវច្បាប់ជាធរមាន ។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ឃើញថាការអះអាងរបស់ព្រះពោធិសត្វ ពិតជាបានបង្កប់នូវអត្ថន័យ ដ៏ជ្រាលជ្រៅសមស្របតាម សេចក្តីថ្លែងការណ៍ ជាសកលស្តីពីសិទ្ធិមនុស្ស។ ហើយក៏ចង់អប់រំមនុស្សគ្រប់រូបឱ្យយល់ ពីសិទ្ធិរស់រានមានជីវិត សន្តិសុខផ្ទាល់ខ្លួន និងអប់រំឱ្យមនុស្សវៀរចាក ការសម្លាប់គ្នា ដោយប្រកាន់នូវធម៌ ខន្តី និងអហិង្សា។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាសិក្ខាកាមត្រូវខិតខំបន្តនូវការសិក្សារៀនសូត្រឱ្យបានខ្ពង់ខ្ពស់ និងបន្តថែរក្សាប្រពៃណីដ៏ល្អរបស់ដូនតាយើង ពិសេសក្នុងក្របខណ្ឌប្រជាធិបតេយ្យ គឺត្រូវប្រគល់សិទ្ធស្វ័យសម្រេចឱ្យបុគ្គលម្នាក់ៗ មិនត្រូវបង្ខំឱ្យគេ ធ្វើតាមបញ្ជាទាំងងងឹតងងល់នោះឡើយ ហើយត្រូវយល់ពីច្បាប់ពុទ្ធចក្រ និងអាណាចក្រឱ្យបានច្បាស់លាស់ ចេះឱ្យតម្លៃជីវិតអ្នកដទៃ។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២២៖** មតិខ្លះយល់ថា៖«ទុំស្លាប់ព្រោះស្រី»។ ចំពោះអ្នកវិញយល់យ៉ាងណា? ចូរពិភាក្សា។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ ជាតិ ជរា ព្យាធិ មរណៈ កើត ចាស់ ឈឺ ស្លាប់ ជារឿងមួយដែលតែងតែកើតមាន ចំពោះមនុស្សរាល់រូប ដែលគ្មាននរណាម្នាក់អាចគេចផុតបាននោះទេ គឺគ្រាន់តែយូរ និងឆាប់ ក៏គង់នឹងមកដល់ដូចតែគ្នា។ បើនិយាយពីការស្លាប់របស់មនុស្សម្នាក់ៗសុទ្ធតែមានប្រភពរបស់វា គឺមានអ្នកខ្លះស្លាប់ដោយសារមានជំងឺ ខ្លះស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ ឬខ្លះស្លាប់ដោយសារគេសម្លាប់ ក៏សឹងតែមាន។
- ចំណូលបញ្ហា៖ យ៉ាងណាមិញនៅក្នុងរឿងទុំទាវ របស់ព្រះភិក្ខុសោម បើវិភាគទាក់ទងនឹងបញ្ហាខាងលើ បានធ្វើឱ្យទស្សនៈមតិមួយបានលើកឡើងថា៖«ទុំស្លាប់ព្រោះស្រី»។
- ចំណោទបញ្ហា៖ តើទស្សនៈមតិដែលបានពោលថា៖«ទុំស្លាប់ព្រោះស្រី» ត្រឹមត្រូវឬទេ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ស្លាប់ គឺការរលាយរូបផុតវិញ្ញាណពីលោកយើងនេះ។ ព្រោះ គឺមូលហេតុមកពី...
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថា ទុំរលាយរូបផុតវិញ្ញាណ ពីលោកយើងនេះទៅ មូលហេតុមកពីស្រី គឺនាងទាវនេះឯង។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម
    - ❖ ជាការពិតណាស់ គេថាមានជីវិតត្រូវមានទុក្ខ។
    - ❖ ទុក្ខនោះ គឺការព្រាត់ប្រាស់និរាសពីគ្នា ឬដោយសារស្លាប់បាត់បង់ជីវិតជាដើម។
    - ❖ គ្មានអ្នកណាម្នាក់អាចកែប្រែរឿងនេះបានទេពីព្រោះពិភពនៃធម្មជាតិ បានតាក់តែងរចនាឡើង តម្រូវឱ្យមានការសប្បាយ ត្រូវតែមានទុក្ខ មានការកើតត្រូវតែទទួលយកមកវិញនូវការស្លាប់។
    - ❖ ឯក្នុងរឿងទុំទាវ ក៏បានលើកយកបញ្ហានេះមកបង្ហាញដែរ គឺអ្នកនិពន្ធបានតម្រូវឱ្យទុំស្លាប់នៅទីបញ្ចប់នៃរឿង។ ការស្លាប់នេះគេយល់ថាមកពីទាវជាដើមហេតុ ព្រោះ៖

    + មតិស្រប៖ (ទុំស្លាប់ព្រោះស្រី)

        ⇨ ពេលនាងទាវ ឬនាងនោ សរសើរពីរូបសម្បត្តិ និងសំឡេងរបស់នេនទុំ នាងទាវក៏រំអុកម្តាយឱ្យម្តាយទៅនិមន្តទុំមកស្មូត្រនៅលើផ្ទះភ្លាម...។

- ⇨ ពេលទាវឃើញរូបសម្បត្តិទុំភ្លាម នាងចាប់ផ្តើមក្តួចចិត្តលើទុំដែលស្ថិតក្នុងភេទជាអ្នកបួស ដោយនាងដើរឆ្លេឆ្លានៅមាត់បន្ទប់ក្នុងបំណងឱ្យទុំឃើញខ្លួន...។
- ⇨ ទាវជាស្រីចិត្តស្រើបស្រាល ដោយប្រគេនព្រៃ កម្មី ផាហ៊ុម ក្រមួន ដន្លាប់អប់ក្លិនផ្កាម្លិះ ចម្ប៉ា ហើយបានផ្សងចង់ជួបទុំក្នុងជាតិនេះ ធ្វើឱ្យទុំយល់ន័យ និងបំណងរបស់នាង...។
- ⇨ ទាវជាស្រីចិត្តងាយព្រោះព្រមប្រគល់ខ្លួនប្រាណដ៏ក្រពុំព្រហ្មចារី ឱ្យទៅមានមន្ទិលជាមួយទុំ មុនពេលរៀបការ ដែលខុសខូចច្បាប់ប្រពៃណីខ្មែរ...។
- ⇨ ពេលទុំមកនាំនាងចេញពីរោងការរបស់ម៉ឺនងួន នាងមិនបានឃាត់ប្តីកុំឱ្យផឹកស្រាទេ តែបែរជាបង្អកប្តីឱ្យស្រវឹង បាត់ភាពម្ចាស់ការ...។
- ⇨ នាងសង្ស័យថាក្នុងឈ្នួតខ្មៅនោះមានរាជសាររបស់ព្រះរាជា តែនាងមិនព្រមប្រាប់ អរ ជូន ទើបធ្វើឱ្យទុំត្រូវក្រុម អរ ជូន ចាប់ចងស្លាបសេកយកទៅសម្លាប់...។

+ សរុបមតិស្រប៖ សរុបសេចក្តីមកឃើញថាការបកស្រាយខាងលើពិតជាបង្ហាញថា ទុំពិតជាស្លាប់ព្រោះតែស្រីពិតប្រាកដមែន ព្រោះបើមិនមកពីនាងទាវទេ ទុំក៏មិនស្លាប់នោះដែរ។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សំណួរភ្ជាប់សេចក្តី៖ តើនាងទាវពិតជាដើមហេតុតែម្យ៉ាងបណ្តាល់ឱ្យទុំស្លាប់ឬ?

+ មតិផ្ទុយ៖ ទោះបីមជ្ឈដ្ឋានខាងលើខំធ្វើការអះអាង ជាមួយនឹងភស្តុតាងយ៉ាងជាក់ស្តែងគួរឱ្យស្តាប់បានយ៉ាងណា ក៏ដោយ ក៏គេនៅតែឃើញមានមតិមួយចំនួនទៀត ដែលមិនយល់ស្របតាមគំនិតខាងលើនេះ ទាំងស្រុងនោះដែរ ព្រោះទុំស្លាប់បណ្តាលមកពីមូលហេតុជាច្រើនដូចជា៖

⇨ មិនជឿទំនាយគ្រូ ដោយគ្រូបានឃាត់ទុំឱ្យពន្យាពេលសឹក ថាចាំដាច់ឆ្នាំទើបសឹកបាន ព្រោះគ្រូវាយលេខអត្តទៅចំលើលេខគ្រោះ...។

⇨ ដាក់ស្នេហ៍ដល់ទាវ នូវមន្តសារិកាលិនថោង ចំនួនប្រាំមេក្នុងចំណោមមន្តស្នេហ៍ទាំងប្រាំពីរមេ រហូតធ្វើឱ្យទាវបាត់សេចក្តីថ្លៃថ្នូរ...។

⇨ ម្តាយទាវលោភលន់បុណ្យសក្តិ ទ្រព្យសម្បត្តិ ចង់ឱ្យទាវការនឹងម៉ឺន ងួន ទុំស្លាប់ព្រោះម្តាយកម្ចាយកូន ឱ្យសូន្យបាត់ ឈ្មោះមិនរស់នៅ...។

⇨ អរ ជូន ត្រចៀកស្រាលជឿតាមម្តាយទាវទាំងដឹងថាទាវត្រូវរាជាបានផ្សំផ្គុំជាមួយទុំរួចហើយ តែគេនៅតែបំពាន រហូតសម្លាប់ទុំ...។

⇨ ការជិះជាន់គាបសង្កត់ ពីប្រពៃណី ពីសំពាធរបស់សង្គមដោយផ្តល់សិទ្ធិឱ្យស្តេចត្រាញ់ អាចសម្លាប់មនុស្សមុនកាត់ទោសជាក្រោយ...។

⇨ មិនបង្ហាញរាជសារ ព្រោះគិតថាខ្លួនជាប្តីទាវស្រប ច្បាប់អាងបារមីព្រះរាជារហូតភ្លេចខ្លួន ដោយយកស្រាជាត្រីមុខ...។

⇨ ទុំស្លាប់ព្រោះកម្មពីជាតិមុន ពុទ្ធសាសនបណ្ឌិតបាន អះអាងថា ម្តាយទាវ អរ ជួន គេធ្វើនេះក៏ព្រោះការ បង្ខិតបង្ខំពីព្រេងវាសនារបស់ទុំតែម្យ៉ាងគត់...។

+ សរុបមតិផ្ទុយ៖ សរុបសេចក្តីមកឃើញថា ការស្លាប់របស់ទុំ គឺបណ្តាលមកពីមូលហេតុជាច្រើនដូចជាបានធ្វើការ រៀបរាប់ ខាងលើពិតប្រាកដមែន។ ការយល់ឃើញបែបនេះ ក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សរុបសេចក្តី៖ ជារួមមកយើងឃើញថា ការបកស្រាយបង្ហាញខាង លើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និត បានថាមតិទីមួយ ដែលបានលើកឡើង ហាក់ដូចជាមានន័យមិន ទាន់គ្រប់គ្រាន់ ពេញលេញនោះទេ ព្រោះហាក់ដូចជាទម្លាក់ កំហុស អំពីការស្លាប់របស់ទុំទៅលើទាវតែម្នាក់ឯង។ ឯមតិទីពីរវិញ មានន័យថាយល់បានទូលំទូលាយ ហើយបានធ្វើការស្រាវជ្រាវឱ្យ ឃើញថាការស្លាប់របស់ទុំ គឺបណ្តាលមកពីមូលហេតុច្រើនយ៉ាង មិនមែនមកពីទាវតែម្នាក់នោះទេ។

**គ. សេចក្តីបញ្ចប់**

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបក ស្រាយបង្ហាញខាងលើ អាចសបញ្ជាក់ឱ្យឃើញថា ប្រធានខាងលើ ដែលបានលើកឡើង ជាមតិដែលមិនទាន់មានន័យគ្រប់ជ្រុង

ជ្រោយនៅឡើយទេ។ ឯមតិផ្ទុយវិញជាមតិដែលត្រឹមត្រូវជាង ព្រោះបានបកស្រាយយ៉ាងច្បាស់គ្មានស្រពិចស្រពិលសោះឡើយ ដែលទាក់ទងទៅនឹងការស្លាប់របស់ទុំ។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយយើងមិនត្រូវប្រទូក នឹងរឿងស្នេហាទាំងនៅវ័យក្មេងខ្ចីពេកនោះទេ ព្រោះជាលទ្ធផលមានទុំ និងទាវជាគម្រូរួចស្រេចទៅហើយ។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២៣៖** លោករដ្ឋមន្ត្រីមានប្រសាសន៍ថា៖"មនុស្សយើងត្រូវមានសិទ្ធិសេរីភាពស្មើគ្នា តែសិទ្ធិសេរីភាពនោះត្រូវមានព្រំដែន"។ តើព្រំដែននោះជាអ្វី? ចូរពន្យល់ ដោយឧទាហរណ៍ក្នុងសង្គម និងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ យើងបានដឹងហើយថា មនុស្សយើងដែលកើតមកនៅលើលោកសន្និវាសយើងនេះ សុទ្ធសឹងតែត្រូវការនូវសិទ្ធិសេរីភាពជាភាពចាំបាច់បំផុត ព្រោះសិទ្ធិសេរីភាពនេះ ជួយជំរុញឱ្យសង្គមជាតិ ឈានទៅរកសេចក្តីថ្លៃថ្នូរ ជាពិសេសនាំឱ្យមានការអភិវឌ្ឍថែមទៀតផង។ តែទោះជាយ៉ាងនោះក្តីក៏សិទ្ធិសេរីភាពនៃបុគ្គលនីមួយៗចាំបាច់ត្រូវតែស្ថិតនៅ ក្រោមអំណាចនៃច្បាប់ជាកំណាត់ដែរ។
- ចំណូលបញ្ហា៖ ដោយមើលឃើញពីភាពចាំបាច់ នៃសិទ្ធិសេរីភាពបែបនេះហើយទើបលោករដ្ឋមន្ត្រីមានប្រសាសន៍ថា៖"មនុស្សយើងត្រូវមានសិទ្ធិសេរីភាពស្មើគ្នា តែសិទ្ធិសេរីភាពនោះត្រូវមានព្រំដែន"។
- ចំណោទបញ្ហា៖ តើប្រសាសន៍លោករដ្ឋមន្ត្រីមានន័យដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ សិទ្ធិសេរីភាព អំណាចមនុស្សម្នាក់ៗដែលត្រូវមាន...។ ព្រំដែន ការកំណត់ជាគោល ឬជាព្រំដែនមួយដែលគេកំណត់។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមាននន័យថាមនុស្សយើងម្នាក់ៗត្រូវមានអំណាចរៀងៗខ្លួន ដោយស្មើភាពគ្នាហើយ អំណាចនោះត្រូវនៅក្រោមច្បាប់ និងមានការកំណត់។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និង ឧទាហរណ៍បញ្ជាក់ដូចខាងក្រោម
    - ❖ ជាភាពជាក់ស្តែងយើងដឹងហើយថា ភាពជាមនុស្សរស់នៅក្នុងលោក ត្រូវមានជាចំបាច់តាំងពីកំណើតមកម៉្លេះ នូវសិទ្ធិសេរីភាព ដើម្បីការពារខ្លួន ឱ្យមានភាពថ្លៃថ្នូរសមជាមនុស្ស។ ប្រសិនបើមនុស្សយើង បាត់បង់នូវសិទ្ធិសេរីភាព ហើយនោះ នោះសេចក្តីថ្លៃថ្នូររបស់ខ្លួន នឹងមិនមានទៀតឡើយ។ ប្រការនេះយើងត្រូវមានស្មារតីភ្ញាក់រឭក ក្នុងការប្រើសិទ្ធិ និងសេរីភាពរបស់ខ្លួន ដើម្បីទាមទារវាឱ្យបានមកវិញព្រោះ៖

**ក. បង្ហាញពីសិទ្ធិសេរីភាពជាមូលដ្ឋាន**

- ⇨ មនុស្សយើងម្នាក់ៗតាំងពីកើតមកត្រូវមានសិទ្ធិសេរីភាពស្មើៗគ្នា។
- ⇨ សិទ្ធិរស់រានមានជីវិត។
- ⇨ សិទ្ធិនិយាយស្តី ឬបញ្ចេញមតិ។
- ⇨ សិទ្ធិចូលរួមសកម្មភាពនយោបាយ។

- ⇨ សិទ្ធិធ្វើវិនិយោគទុន សេដ្ឋកិច្ច។
- ⇨ សិទ្ធិទទួលការអប់រំ។
- ⇨ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់។
- ⇨ សិទ្ធិមានការងារធ្វើ។
- ⇨ សិទ្ធិជ្រើសរើសគូស្រករ។
- ⇨ សិទ្ធិជ្រើសរើសអ្នកតំណាង។

**ខ. បង្ហាញពីព្រំដែននៃសិទ្ធិ**

- ⇨ សិទ្ធិសេរីភាពខាងលើវាជាភាពថ្លៃថ្នូររបស់មនុស្សទូទៅ ដែលមិនត្រូវរំលោភដោយជនណាម្នាក់។
- ⇨ សិទ្ធិសេរីភាពត្រូវមានព្រំដែនហើយត្រូវនៅក្រោម ច្បាប់រដ្ឋ។
- ⇨ បើប្រើសិទ្ធិហួសព្រំដែន នឹងធ្វើឱ្យសិទ្ធិលែងមានតម្លៃ សង្គមវឹកវរ អយុត្តិធម៌ ពុករលួយ...។

**គ. បង្ហាញតាមរយៈសង្គម**

- ⇨ ក្នុងសង្គមជាក់ស្តែង អជីវករមានសិទ្ធិធ្វើអាជីវកម្ម តែ គោរពច្បាប់អាជីវកម្ម ត្រូវបង់ពន្ធ ធ្វើកិច្ចសន្យាលើការ ធ្វើអាជីវកម្ម។
- ⇨ មន្ត្រីរាជការមានសិទ្ធិពេញលេញ ក្នុងការបំពេញ ការងារតាមជំនាញ ត្រូវគោរពពេលវេលាច្បាប់ការងារ
- ⇨ ប្រជារាស្ត្រមានសិទ្ធិស្មើៗគ្នា ក្នុងការរើសអ្នកដឹកនាំ របស់ខ្លួនស្របតាមឆន្ទៈដោយមិនមានបង្ខិតបង្ខំ។

**ឃ. បង្ហាញតាមរយៈអក្សរសិល្ប៍**

⇨ រឿងព្រះអាទិត្យថ្មី(លោករដ្ឋមន្ត្រីវ័យក្មេងបានគោរព សិទ្ធិរបស់សម គោរពតួនាទីរបស់ខ្លួនជារដ្ឋមន្ត្រី)។

⇨ រឿងថៅកែចិត្តចោរ(ពួកកម្មករប្រើសិទ្ធិរបស់ខ្លួនក្នុង ការស្វែងរកយុត្តិធម៌ ប្រឆាំងនឹងថៅកែ)។

⇨ រឿងគូលីកំនែន(ពូស្វាយមីងពតបានផ្តល់សិទ្ធិឱ្យនាង ហេងក្នុងការជ្រើសរើសគូស្រករ)។

- សរុបសេចក្តី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ ខាងលើ យ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថាមនុស្សយើងត្រូវ មានសិទ្ធិសេរីភាពស្មើៗគ្នា ហើយសេរីភាពនោះត្រូវផ្សារភ្ជាប់ទៅ នឹងព្រំដែនមួយហើយព្រំដែន គឺជាអំណាចនៃច្បាប់។ បើមិន ដូច្នោះទេ បុគ្គលនោះមានឈ្មោះថាជាអ្នកបំពានសិទ្ធិសេរីភាពគេ ឬជិះជាន់គេឯងជាមិនខាន។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបក ស្រាយយ៉ាងលម្អិត ចំពោះទស្សនៈរបស់ប្រធានខាងលើនេះ យើង ឃើញថាទស្សនៈរបស់ប្រធានខាងលើពិតជាផ្តល់តម្លៃអប់រំយ៉ាង ជ្រាលជ្រៅ ព្រោះបានធ្វើឱ្យមនុស្សទូទៅបានយល់ច្បាស់ នូវសិទ្ធិ សេរីភាពរបស់ខ្លួន ដើម្បីយកសិទ្ធិទាំងនេះ ទៅប្រើប្រាស់ឱ្យបាន សមស្របតាមច្បាប់រដ្ឋធម្មនុញ្ញ របស់ប្រទេស។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សាត្រូវខិតខំ ប្រឹងប្រែង រៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដ សម្រាប់ប្រទេសជាតិ ហើយពួកយើងគប្បីចេះគោរព អត់ឱនឱ្យគ្នា

ទៅវិញទៅមក ចៀសវាងរាល់អំពើសាហាវយង់ឃ្នងចំពោះអ្នកដែលរស់នៅជុំវិញខ្លួន នោះទើបយើងមានឈ្មោះថាជាមនុស្សល្អពោរពេញទៅដោយឧត្តមគតិក្នុងការគោរពសិទ្ធិមនុស្ស ដែលសក្តិសមជាពលរដ្ឋគំរូ។

- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២៤៖** ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ប្រកបដោយសុខសុវត្ថិភាព មិនអាចផ្ដាច់ចេញពីការបណ្ដុះបណ្ដាល ធនធានមនុស្សបានឡើយ។ ក្នុងស្ថានភាពបច្ចុប្បន្ន តើត្រូវបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិដូចម្ដេចខ្លះ?

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ យើងដឹងច្បាស់ហើយថានៅក្នុងសង្គមគ្រួសារក្ដី ក្នុងសង្គមជាតិទាំងមូលក្ដី គឺត្រូវចាំបាច់បំផុតនូវធនធានមនុស្ស ដែលពួកគេ គឺជាកោសិកា ដ៏សំខាន់ដែលពុំអាចខ្វះបាន ក្នុងការកសាងសង្គមគ្រួសារ និងសង្គមជាតិ។ តាមរយៈនេះលុះត្រាតែយើងនាំគ្នាចូលរួមយ៉ាងសស្រាក់សស្រាំ ក្នុងការបណ្ដុះបណ្ដាលនូវធនធានមនុស្ស ឱ្យបានគ្រប់គ្រាន់ ព្រោះថាធនធានមនុស្ស គឺជាកត្តាសំខាន់ ក្នុងការអភិវឌ្ឍ។
- ចំណូលបញ្ហា៖ ទាក់ទងទៅនឹងការវិនិច្ឆ័យបែបនេះហើយ ទើបមានមតិមួយពោលថា៖ «ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ប្រកបដោយសុខសុវត្ថិភាព មិនអាចផ្ដាច់ចេញពីការបណ្ដុះបណ្ដាល ធនធានមនុស្សបានឡើយ។»
- ចំណោទបញ្ហា៖ តើពំនោលខាងលើមានន័យដូចម្ដេច? តើត្រូវបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិដូចម្ដេចខ្លះ ដើម្បីចូលរួមក្នុងការអភិវឌ្ឍជាតិ?

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ការអភិវឌ្ឍ មានន័យថាការរីកចម្រើនខ្លាំង។ សុវត្ថិភាព មានន័យថាភាពប្រកបដោយសេចក្តីសុខ។ ធនធានមនុស្ស មានន័យថាមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថាការធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនខ្លាំង ប្រកបដោយសេចក្តីសុខ គឺមិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ បានឡើយ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផលនិងឧទាហរណ៍បញ្ជាក់ដូចខាងក្រោម៖
    - ❖ ជាភាពជាក់ស្តែងបើយើងក្រឡេកមើល ពីបណ្តាប្រទេសមួយចំនួន ដែលមានធនធានធម្មជាតិយ៉ាងច្រើនលើសលប់ក៏មិនប្រាកដថាជាប្រទេស រីកចម្រើននោះដែរ។ បើសម្បូរពោរពាសដោយសម្បត្តិធម្មជាតិតែខ្វះខាតនូវធនធានមនុស្សនោះ ក៏វាមិនមានការរីកចម្រើនទៅយ៉ាងរលូនដែរ។ ចំណែកឯប្រទេសមួយចំនួន ដែលគ្មានធនធានធម្មជាតិ ក៏មិនប្រាកដថាជាប្រទេសអន់ថយដែរ មានជាអាទិ៍ ដូចជាប្រទេសជប៉ុន ប្រទេសសិង្ហបូរី ជាប្រទេសដែលមិនសូវមាន

ធនធានធម្មជាតិនោះទេ តែប្រទេសរបស់គេសម្បូរដោយធនធានមនុស្ស ទើបប្រទេសទាំងនេះមាន ការរីកចម្រើនលើគ្រប់វិស័យទាំងអស់។ យ៉ាងណាមិញ ប្រទេសកម្ពុជាយើង ដើម្បីធ្វើការអភិវឌ្ឍ គឺត្រូវចូលរួមបណ្តុះបណ្តាលធនធានមនុស្សឱ្យមានលក្ខណៈសម្បត្តិដូចជា៖

**បណ្តុះបណ្តាលតាមរយៈសង្គមបច្ចុប្បន្ន៖**

- ⇨ កាយសម្បទារឹងមាំ(ឱ្យតម្លៃ លើកីឡា)
- ⇨ ប្រាជ្ញាសម្បទា(រៀន និងបង្រៀន)
- ⇨ សីលសម្បទា(មានសីលធម៌រស់នៅល្អ)
- ⇨ វិជ្ជាសម្បទា(មានបំណិនជីវិត មានបទពិសោធ)
- ⇨ ចរិយាសម្បទាន(មានការប្រព្រឹត្តល្អ ប្រកបដោយគុណ)
- ⇨ សិទ្ធិ និងប្រជាធិបតេយ្យ
- ⇨ចេះរួមរស់ក្នុងសន្តិភាព និងចុះសំរុងគ្នា។

**បណ្តុះបណ្តាលតាមរយៈអក្សរសិល្ប៍៖**

- ⇨ រឿងព្រះអាទិត្យថ្មី (សមទទួលការបណ្តុះបណ្តាលពីអ្នកជំនាញខាងវិស័យកសិកម្ម...ធ្វើឱ្យសង្គមជាតិរីកចម្រើន)
- ⇨ រឿងថៅកែចិត្តចោរ(ផានីត បានចំណេះពីការរៀនសូត្រយកមកអនុវត្ត...បានចូលរួមរក្សាយុត្តិធម៌ជូនសង្គម)
- ⇨ រឿងទុំទាវ(ទុំ ទៅបួសរៀនក្នុងអារាមដើម្បីទទួលបានចំណេះ និងជំនាញ...យកទៅអភិវឌ្ឍ សង្គមគ្រួសារ និងជាតិ)។

- សរុបសេចក្ដី៖ សរុបសេចក្ដីជារួមមក ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថា ក្នុងស្ថានភាពបច្ចុប្បន្ន យើងត្រូវបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានគ្រប់សមត្ថភាព ទាំងផ្លូវកាយ ប្រាជ្ញា សីលធម៌ វិជ្ជាចរិយា បំណិន ឬជំនាញ ដោយចេះរួមរស់ជាមួយគ្នាក្នុងសន្តិភាព ហើយចេះឱ្យតម្លៃលើសិទ្ធិ និងប្រជាធិបតេយ្យ។

## គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិត ចំពោះទស្សនៈរបស់ប្រធានខាងលើនេះ យើងឃើញថាទស្សនៈរបស់ប្រធានខាងលើ ពិតជាផ្ដល់តម្លៃអប់រំយ៉ាងជ្រាលជ្រៅ ព្រោះចង់ឱ្យយើងដឹងពីតម្លៃនៃធនធានមនុស្ស ដែលជាកត្តាកំណត់នៃការអភិវឌ្ឍ របស់សង្គម។ លើសពីនេះចង់ឱ្យយើងមានលទ្ធភាពចូលរួមក្នុងការកសាងជាតិ ព្រោះយើងជាកុលបុត្រកុលធីតាខ្មែរដែលពោរពេញទៅដោយចំណេះដឹង បទពិសោធ និងបំណិនច្បាស់លាស់ ហើយត្រូវយល់ថា អនក្ខរភាព គឺជាសត្រូវនៃការអភិវឌ្ឍប្រទេសជាតិ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវធ្វើយ៉ាងណាឱ្យមានភាពស៊ីចង្វាក់គ្នា រវាងការរីកចម្រើន ផ្លូវកាយ និងប្រាជ្ញា រវាងវិទ្យាសាស្ត្រ និងសីលធម៌ រវាងបុគ្គល និងសង្គម រវាងជាតិ និងអន្តរជាតិ។

- *ពាក្យស្លោក ឬសុភាសិត៖ សមទស្សនៈមួយពោលថា៖ ‹‹ប្រទេសជាតិរីកចម្រើនទៅបាន គឺអាស្រ័យលើធនធានមនុស្ស››។*

**ប្រធានទី២៥៖** ទស្សនៈមួយលើកឡើងថា៖«ឧត្តមភាពរបស់មនុស្ស កើតចេញពីភក្តីភាព»។ ចូរពន្យល់ ដោយលើកឧទាហរណ៍មក បញ្ជាក់ឱ្យបានពិស្តារ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ មនុស្សយើងម្នាក់ៗ ដែលកើតមកនៅលើលោកសន្និវាសយើងនេះ សុទ្ធតែមានបំណងប្រាថ្នាចង់ឱ្យអ្នកដទៃ គោរព និងឱ្យតម្លៃ។ សេចក្តីនេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវមានចិត្តស្មោះត្រង់ មានភក្តីភាពរវាងគ្នា និងគ្នាដើម្បីបង្កើននូវទំនុកចិត្តដល់ភាគីទាំងសងខាងដោយឥតមានកិច្ចកលខ្វល់ខ្វាយអ្វីឡើយ។ ដូចនេះភក្តីភាពវាមូលហេតុមួយដែលធ្វើឱ្យមនុស្សយើងម្នាក់ៗ កើតមាននូវឧត្តមភាព។
- ចំណូលបញ្ហា៖ ដោយយោងទៅតាមចំណុចនៃការរៀបរាប់ខាងលើនេះហើយទើបមានទស្សនៈមួយលើកឡើងថា៖«ឧត្តមភាពរបស់មនុស្ស កើតចេញពីភក្តីភាព»។
- ចំណោទបញ្ហា៖ តើទស្សនៈដែលលើកឡើងថា៖«ឧត្តមភាពរបស់មនុស្ស កើតចេញពីភក្តីភាព» មានន័យដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពស៊ីជម្រៅ និងកាន់តែល្អនោះ យើងគប្បីស្វែងយល់ឱ្យបានច្បាស់ នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ឧត្តមភាព មានន័យថាភាពខ្ពង់ខ្ពស់ ភាពថ្កុំថ្កើងល្បីល្បាញ ភាពថ្លៃថ្នូរ។ ភក្តីភាព មានន័យថាភាពស្មោះត្រង់ឥតងាករេ។
- ពន្យល់ន័យប្រធាន៖ ដូចនេះទស្សនៈប្រធានមានន័យថាភាពខ្ពង់ខ្ពស់ ភាពថ្កុំថ្កើងល្បីល្បាញ ភាពថ្លៃថ្នូរ របស់មនុស្សកើតចេញពីភាពស្មោះត្រង់ឥតងាករេ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការពិតណាស់មនុស្សដែលរស់នៅលើលោកយើងនេះក្លាយជាឥស្សរជនជាន់ខ្ពស់ ជាទីស្នេហានៃអ្នកដទៃ ក្លាយជាអ្នកមានកិត្តិយសមានកិត្តិនាមល្អខ្ចរខ្ចារ ដោយមនុស្សនោះជាអ្នកស្មោះត្រង់ចំពោះខ្លួនឯង ស្មោះត្រង់ចំពោះក្រុមគ្រួសារ ស្មោះត្រង់ចំពោះអ្នកដទៃ ជាតិ សាសនា និងព្រះមហាក្សត្រ។ ផ្ទុយទៅវិញបើមនុស្សយើងមិនមានភក្តីភាពដល់អ្នកដទៃដែលនៅជុំវិញខ្លួនទេនោះ នោះក៏មិនអាចត្រូវបានគេឱ្យតម្លៃ ជាបុគ្គលប្រកបដោយឧត្តមភាពនោះដែរ។
  - ❖ រូបភាពឧត្តមភាព៖ ការគិតល្អ គំនិតសុទិដ្ឋិនិយម ការមិនក្បត់គ្នាការការពារប្រទេសជាតិមិនចូលរួមអំពើពុករលួយ។
  - ❖ ការមនុស្សមានគំនិតល្អ ការយល់ឃើញល្អនោះនឹងមានភាពស្មោះត្រង់កើតឡើងក្នុងសង្គមជាក់ជាមិនខាន។

**ក. បង្ហាញតាមរយៈសង្គម**

- ⇨ បុរស ស្រ្តីមានគោលជំហរគោរពសម្ដីខ្លួន ស្មោះការងារ មិនក្រឡិចក្រឡុច... គេទទួលបានគោរពរាប់អាន។
- ⇨ ប្ដី ប្រពន្ធស្មោះត្រង់មិនក្បត់លួចមានសាហាយស្មន់មិនមានពុតត្បុត... គ្រួសាររីកចម្រើនគ្មានទំនាស់។
- ⇨ កសិករស្មោះត្រង់ក្នុងការផលិតផលដំណាំ ដោយមិនប្រើជីគីមីនាំឱ្យខូចសុខភាព...អតិថិជនគាំទ្រសាទរ។
- ⇨ ពលរដ្ឋគ្រប់ជាន់ថ្នាក់ មន្ត្រីរាជការទូទៅ មានទឹកចិត្តស្រឡាញ់ ជាតិ សាសនា ព្រះមហាក្សត្រ ស្មោះត្រង់បម្រើការពាររាជាយ៉ាងមុតមាំ ដោយមិនធ្វើអំពើល្មើសច្បាប់មិនពុករលួយនិងមានអនាគតភ្លឺស្វាង មានបុណ្យស័ក្តិ កិត្តិស័ព្ទល្អ ទោះបីស្លាប់ ឬរស់មានគេគោរព។

**ខ. បង្ហាញតាមរយៈអក្សរសិល្ប៍**

- ⇨ រឿងរាមកេរ្តិ៍ ព្រះរាមទៅបួសរក្សាពាក្យសច្ចៈ... ប្អូនៗគាំទ្រសាទរគោរព។ នាងសីតា ភក្ដីនឹងព្រះរាមជានិច្ច... ភ្លើងពុំឆេះនាងឡើយ ពេលព្រះរាមសាកល្បងពិសោធភាពបរិសុទ្ធ។
- ⇨ រឿងកូលាបប៉ៃលិន ចៅចិត្រខ្ពស់មុខខ្ពស់មាត់ មានកិត្តិយស ព្រោះមានក្ដីស្មោះនឹងលោកហ្លួងរតនសម្បត្តិពេលមានអាសន្ន។
- ⇨ រឿងតេជោយ៉ត ត្រង់តេជោយ៉តមិនព្រមចូលគាល់រាជាតាមការកោះហៅ ដោយរវល់កំពុងកំចាត់សត្រូវពីក្រោយខ្នង ដែលធ្វើឱ្យគ្រោះថ្នាក់ដល់ជាតិ សន្យាថានឹង

ចូលគាល់បន្ទាប់ពីច្បាំងចប់... ព្រះរាជាភ្ញាក់រឭក សរសើរ។

⇨ រឿងទុំទាវ ទុំ ទាវមានចិត្តស្មោះនឹងគ្នា... ទីបញ្ចប់ក្លាយជាប្តីប្រពន្ធស្របច្បាប់ ទោះស្លាប់ក៏ក្នុងកិត្តិយស។

- សរុបសេចក្តី៖ ក្រោយពីបានធ្វើការបកស្រាយបញ្ជាក់ ខាងលើយ៉ាងក្បោះក្បាយរួចមក សបញ្ជាក់ឱ្យឃើញថាមនុស្សដែលមានស្មារតីប្រកាន់នូវគោលជំហរស្មោះត្រង់ ភក្តីភាព នឹងអ្នកដែលនៅជុំវិញខ្លួន នោះនឹងធ្វើឱ្យជនទាំងអម្បាលនោះនឹងទទួលបាននូវការសាទរគោរពកោតសរសើរ ពីមនុស្សទូទៅនៅក្នុងសង្គមទាំងមូលយ៉ាងពិតប្រាកដ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការ បកស្រាយយ៉ាងលម្អិតចំពោះទស្សនៈនេះបានចូលរួមអប់រំមនុស្សឱ្យប្រកាន់យកនូវពាក្យពិត ចិត្តបរិសុទ្ធ កាយសុចរិត លះបង់នូវពាក្យសម្តីភូតភរកុហកបោកប្រាស់(មុសា) ដែលជាគុណវិបត្តិមួយដ៏ធ្ងន់ធ្ងរ ដល់ការអភិវឌ្ឍសង្គមខ្មែរនាពេលបច្ចុប្បន្ន និងទៅពេលអនាគត។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សាត្រូវខិតខំ ប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយត្រូវប្រកាន់ឱ្យបានយ៉ាងខ្ជាប់ខ្ជួន នូវភក្តីភាព ចំពោះខ្លួនឯង ចំពោះអ្នកដទៃ ចំពោះគ្រួសារ ជាពិសេស

នោះចំពោះប្រទេសជាតិខ្លួន ដើម្បីធ្វើឱ្យខ្មែរទាំងមូលមានឧត្តមភាពថ្លៃថ្លា។

- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២៦៖** តាមរយៈរឿងរាមកេរ្តិ៍ មានទស្សនៈមួយបានលើកឡើងថា៖"ការរៀបចំគូស្រករឱ្យកូនតាមបែបព្រះបាទជនក ក៏ជាមធ្យោបាយល្អម្យ៉ាងដែរ"។ ចូរពិភាក្សាដោយលើកឧទាហរណ៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ នៅក្នុងវណ្ណកម្មអក្សរសិល្ប៍បុរាណ នៃចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម យើងឃើញថារឿងរាមកេរ្តិ៍ត្រង់វគ្គព្រះរាមលើកធ្នូបានបំផុស និងឆ្លុះបញ្ចាំងឱ្យពីព្រះរាជសកម្មភាពរបស់ព្រះបាទជនកដែលជាព្រះចៅក្រុងមិថិលា ក្នុងរាជពិធីច្រត់ព្រះនង្គ័លនៅ ក្បែរឆ្នេរស្ទឹងយមុនា ដែលនៅពេលព្រះអង្គរើសបានទារិកាពីដីអាចម៍បំណះ។ លុះបានចិញ្ចឹមបីបាច់រហូតមានវ័យវឌ្ឍនាការគ្រប់ការក៏បង្កើតឱ្យមានការប្រឡងប្រជែង លើកធ្នូសរដើម្បីរកបុរសដែល មានអំណាចខ្លាំង មកធ្វើជាគូអនាគតរបស់នាងសីតា។
- ចំណូលបញ្ហា៖ វិភាគទាក់ទងទៅនឹងបញ្ហាខាងលើ បានធ្វើឱ្យទស្សនៈមតិមួយបានលើកឡើងថា៖"ការរៀបចំគូស្រករឱ្យកូនតាមបែបព្រះបាទជនក ក៏ជាមធ្យោបាយល្អម្យ៉ាងដែរ"។
- ចំណោទបញ្ហា៖ តើទស្សនៈមតិដែលបានពោលខាងលើនេះត្រឹមត្រូវដែរឬទេ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីជាមូលដ្ឋាននៃការបកស្រាយ យើងគប្បីស្វែងយល់នូវពាក្យគន្លឹះរបស់ប្រធានឱ្យបានច្បាស់ជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ពាក្យមធ្យោបាយ មានន័យថាឧបាយជាកណ្ដាលដំណើរទំនងដ៏សមគួរ សម្រាប់ធ្វើកិច្ចការ ឱ្យបានសម្រេចតាមបំណង។
- ពន្យល់ន័យប្រធាន៖ យកន័យរបស់ពាក្យគន្លឹះដែលបានពន្យល់រួចទៅជួសក្នុងប្រធាន...។
- បកស្រាយប្រធាន៖ បកស្រាយពិស្ដារ រួមផ្សំហេតុផល និងអំណះអំណាងបញ្ជាក់ដូចខាងក្រោម៖

❖ ជាការពិតណាស់រាល់ស្នាដៃអក្សរសិល្ប៍ ដែលអ្នកនិពន្ធបានតាក់តែងមក សុទ្ធតែបានបង្ហាញ ពីបញ្ហាជាច្រើនដែលមាននៅក្នុងសង្គមជាក់ស្ដែង។ យ៉ាងណាមិញ នៅក្នុងរឿងរាមកេរ្ដិ៍ក៏បានលើកយកបញ្ហាមួយចំនួន ដែលទាក់ទងទៅនឹង ការជ្រើសរើសគូស្រករឱ្យកូនរបស់ព្រះបាទជនកមកឆ្លុះបញ្ចាំងផងដែរ...

\+ មតិស្រប៖ ពិតមែនហើយការរៀបចំគូស្រករឱ្យកូនតាមបែបព្រះបាទជនក ក៏ជាមធ្យោបាយល្អម្យ៉ាងដែរព្រោះ៖

⇨ អាចជ្រើសរើសព្រះរាជសុណិសា ប្រកបដោយឫទ្ធីចេស្ដា សមត្ថភាព យុទ្ធសិល្ប៍អស្ចារ្យ (ឈ្នះត្រៃភព)។

⇨ ជ្រើសរើសបានរាជសុណិសាដែលជាអវតាទី៧ នៃព្រះវិស្ណុ ឬនរាយណ៍។

⇨ អាចជាសំណាងល្អសម្រាប់រាជនគរមិថិលា ជាទីពឹងសម្រាប់ប្រជានុរាស្ត្រ។

⇨ អាចធ្វើឱ្យនគរបានសុខ នគរដទៃមិនហ៊ានឈ្លានពានព្រោះខ្លាចអំណាចចេស្តាព្រះរាម...។

\+ សរុបមតិស្រប៖ សរុបសេចក្តីមកឃើញថា ជម្រើសតាមបែបព្រះបាទជនកពិតជាមធ្យោបាយមួយល្អមែនដែរ។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវមែនដែរ។

✵ សំណួរភ្ជាប់សេចក្តី៖ តើការលើកធ្នូរ ពិតជាមធ្យោបាយមួយដ៏ល្អ ក្នុងការជ្រើសរើសគូស្រករសម្រាប់នាងសីតាឬ?

\+ មតិផ្ទុយ៖ ទោះបីមជ្ឈដ្ឋានខាងលើខំធ្វើការអះអាង ជាមួយនឹងភ័ស្តុតាងយ៉ាងជាក់ស្តែងគួរឱ្យស្តាប់បានយ៉ាងណាក៏ដោយ ក៏គេនៅតែឃើញមានទស្សនៈមួយទៀតបានប្រឆាំងយ៉ាងដាច់អហង្ការដែរព្រោះ

⇨ ការជ្រើសរើសបែបនេះ ធ្វើឱ្យអ្នកទាំងពីរមិនបានសិក្សាចិត្តគំនិតគ្នា ឱ្យបានច្បាស់លាស់។

⇨ ប្តីប្រពន្ធមុននឹងអាចរស់នៅ ជាមួយគ្នាបានលុះត្រាស្គាល់ចិត្តសាស្ត្រទៅវិញទៅមកដើម្បីបំពេញឱ្យគ្នានូវការខ្វះខាត។

⇨ ព្រះរាម និងសីតាបានគ្នាជាគូជីវិតដោយឥតព្រាងទុកព្រោះការព្រាងទុកគឺជាគម្រោងដ៏ល្អមួយសម្រាប់ភាពជោគជ័យនៃជីវិតគ្រួសារ។

⇨ ការមិនយល់ចិត្តគ្នានេះបណ្តាលឱ្យមានការសង្ស័យប្រចណ្ឌ(ដើរកាត់ភ្លើង បញ្ហារូបយក្ស ក្រុងរាពណ៍ រហូតឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅសម្លាប់ទាំងកំពុងមានគភ៌)។

⇨ ជីវិតស្នេហា របស់ព្រះរាម និងសីតាមិនមានសុភមង្គលយូរអង្វែងទេ គឺមានតែការនិរាសព្រាត់ប្រាសគ្នារៀងរហូត។

\+ សរុបមតិផ្ទុយ៖ សរុបសេចក្តីមកឃើញថាការរៀបចំទុកដាក់កូនតាមបែបព្រះបាទជនក គឺជាមធ្យោបាយមួយមិនទាន់មានលក្ខណៈប្រសើរឡើយ ព្រោះមិនបានធ្វើឱ្យកូនមានសុភមង្គលនោះទេ គឺបានត្រឹមតែការបែកបាក់ប៉ុណ្ណោះ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សំយោគមតិ៖ ជារួមមកយើងឃើញថាការបកស្រាយខាងលើសុទ្ធតែបង្ហាញ នូវគោលជំហររៀងៗខ្លួន តែយើងសន្មតបានថាជុំវិញបញ្ហា ការជ្រើសរើសបុត្រ សុណិសាតាមបែប ព្រះបាទជនក ដោយឆ្លងកាត់វិញ្ញាសាលើកធ្នូសរក៏ជាមធ្យោបាយល្អម្យ៉ាងដែរ ព្រោះដើម្បីទទួលបាននូវបុរសដែលមានសមត្ថភាព។ ប៉ុន្តែជាមួយនឹងការឱ្យតម្លៃទៅលើសមត្ថភាព ព្រះអង្គគួរតែផ្តល់ឱកាសឱ្យបានគ្រប់គ្រាន់ សម្រាប់សមីជនទាំងសងខាងឱ្យមានឱកាសបានស្គាល់ចិត្តគ្នាជាមុនទើបល្អ...។

**គ. សេចក្តីបញ្ចប់**

- *វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ឆ្លងតាមរយៈនៃការបកស្រាយយ៉ាងក្បោះក្បាយរួចរាល់ខាងលើមកនេះ យើងអាចវាយតម្លៃបានថា ទស្សនៈរបស់ប្រធាន ខាងលើមានន័យត្រឹមត្រូវមួយចំណែកដែរ តែមិនទាន់មានន័យត្រឹមត្រូវគ្រប់ជ្រុងជ្រោយទេ ព្រោះការយល់ឃើញ របស់ប្រធានបែបនេះ វាគ្រាន់តែជាការយល់ឃើញមួយជ្រុងតូចនៃជីវិតគូស្រករតែប៉ុណ្ណោះ។ និយាយរួមទៅលុះត្រាតែ គំនិតទាំងពីរខាងលើបូកបញ្ចូលគ្នាទើបល្អ ដូចទូកត្រូវពឹងច្រវាដូច្នោះដែរ។*
- *ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមខ្ញុំជាកុលបុត្រខ្មែរមួយរូបយល់ឃើញថា ចំណុចខាងលើនេះអាចធ្វើឱ្យយើងជាបច្ឆាជន ជំនាន់ក្រោយប្រមូលយក នូវគំនិតបទពិសោធក្នុងការជ្រើសរើសគូស្រករ ទៅថ្ងៃអនាគត ដែលប្រកបដោយសុភមង្គល ដោយអាស្រ័យលើសមត្ថភាព បរិបូណ៌ទៅដោយធនធានមនុស្ស រួមផ្សំជាមួយ និងការសិក្សាចិត្តគ្នាទៅវិញទៅមក ដើម្បីបង្កឱ្យមានភាព ចុះសម្រុងគ្នារវាងជីវិតគូស្នេហ៍ ដ៏ផ្អែមល្ហែមមួយ នៃសង្គមគ្រួសារដែលចៀសផុត ពីការឈ្លោះទាស់ទែងគ្នា។*
- *ពាក្យស្លោក ឬសុភាសិត សមនឹងទស្សនៈមួយបានពោលថា៖«ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់បង្ហាញចោរ»។*

**ប្រធានទី២៧៖** ពំនោលមួយពោលថា៖«ឧត្តមភាពនៃជីវិតស្ថិតនៅលើ ការលះបង់»។ ចូរបកស្រាយ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ នរជនទូទៅក្នុងលោកយើងនេះ តែងតែប្រាថ្នាចង់ឱ្យជីវិតថ្កើងថ្កាន មានកេរ្តិ៍ឈ្មោះល្បីល្បាញ ទទួលបាននៅភាពថ្លៃថ្នូរ មានគេគោរពកោតសរសើរ។ បើនិយាយដល់ចំនុចនេះ គឺត្រូវផ្តើមចេញពីមនុស្ស ខ្លួនឯងផ្ទាល់ ដោយហ៊ានបូជា នូវអ្វីៗគ្រប់យ៉ាងដែលជាប្រយោជន៍ខ្លួន ដើម្បីប្រយោជន៍សម្រាប់ជាតិមាតុភូមិទាំងមូល ឥតស្តាយស្រណោះ អ្វីបន្តិចសោះឡើយ។ លក្ខខណ្ឌបែបនេះទើបអាចធ្វើឱ្យតម្លៃជីវិតនៃមនុស្សប្រកបដោយឧត្តមភាព។
- ចំណូលបញ្ហា៖ ទាក់ទងទៅនឹងករណីបែបនេះហើយ ទើបមានពំនោលមួយពោលថា៖«ឧត្តមភាពនៃជីវិតស្ថិតនៅលើ ការលះបង់»។
- ចំណោទបញ្ហា៖ តើពំនោលខាងលើមានន័យដូចម្តេចខ្លះ? តើឧត្តមភាពនៃជីវិតស្ថិតនៅលើ ការលះបង់អ្វីខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋានក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។

- ពន្យល់ពាក្យគន្លឹះ៖ ឧត្ដមភាពនៃជីវិត មានន័យថាជីវិតខ្ពង់ខ្ពស់ ជីវិតមានតម្លៃ ភាពប្រសើរនៃជីវិត។ ការលះបង់ មានន័យថាការចំណាយ ការបូជាជូន ចែងចែកឥតរារែក។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថាជីវិតខ្ពង់ខ្ពស់ ជីវិតមានតម្លៃ ភាពប្រសើរនៃជីវិត គឺស្ថិតនៅលើ ការចំណាយ ការបូជាជូនជាតិមាតុភូមិ នូវអ្វីៗគ្រប់យ៉ាងដោយមិនមានសេចក្ដីស្ដាយស្រណោះ។
- បកស្រាយប្រធាន៖ បកស្រាយពិស្ដារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
    - ❖ ជាតថភាពជាក់ស្ដែងមនុស្សយើងម្នាក់ៗ កើតមកហើយតែងតែស្លាប់ទៅវិញជារឿងធម្មតានោះទេ ព្រោះសេចក្ដីស្លាប់ វាគឺជាមរណធម៌ ជាមរតកនៃជីវិត ដែលមិនមានបុគ្គលណាម្នាក់អាចសូកប៉ាន់ ដើម្បីគេចវេះពីមច្ចុមារបានឡើយ។
    - ❖ មនុស្សក៏ប្រាថ្នា ចង់ឱ្យជីវិតនេះ ពេលរស់នៅក្ដី ពេលស្លាប់ទៅក្ដី មានគេគោរព សរសើរ នឹកគិតអាល័យ សោកស្ដាយ ជាពិសេសកេរ្ដិ៍ឈ្មោះបានជិតដាមក្នុងដួងចិត្តនៃមនុស្សគ្រប់ជំនាន់។
    - ❖ ប្រការនេះកើតមកពីជននោះ ពេលខ្លួនមានជីវិតតែងបានលះបង់គំនិតប្រាជ្ញា ស្មារតី កម្លាំងកាយចិត្ត ទ្រព្យធន សេចក្ដីសុខផ្ទាល់ខ្លួន អាយុជីវិត ដើម្បីការពារជាតិ កសាងស្នាដៃជូនសង្គម។

## បកស្រាយផ្អែកលើសង្គមប្រវត្តិសាស្ត្រ

- សម្ដេចនរោត្តម សីហនុ ជាអ្នកដឹកនាំដែលបានលះបង់សេចក្ដីសុខដើម្បីជាតិ ទាមទារឯករាជ្យពីបារាំង នៅឆ្នាំ ១៩៥៣ ពលរដ្ឋខ្មែរថ្វាយគោរមងារថា៖ «ព្រះបិតាឯករាជ្យជាតិ» ...សទ្ទិសញ្ញាទីក្រុងប៉ារីស ...ពេលសុគតរាស្ត្រខ្មែរសោកស្ដាយ។
- សម្ដេចសង្ឃរាជ ជួន ណាត ក្នុងនាមជាអ្នកប្រាជ្ញបានចំណាយពេលមួយជីវិតបង្កើតអក្សរសាស្ត្រខ្មែរដើម្បីឱ្យកូនខ្មែរទូទៅបានសិក្សាស្វែងយល់ ទោះបីពេលនេះព្រះអង្គអស់ព្រះជន្មមែន តែកូនខ្មែរនៅចងចាំឧត្ដមភាពព្រះអង្គជានិច្ច។
- មេទ័ពឃ្លាំងមឿង បានលះបង់ជីវិតទាំងគ្រួសារក្នុងរណ្ដៅដើម្បីបុព្វហេតុជាតិ ទឹកដី មិនឱ្យសៀមឈ្លានពានបាន ...រហូតពេលនេះគាត់បានទទួលងារជាវីរបុរសស្នេហាជាតិ គេសាងរូបសំណាកគាត់ទុកគោរពបូជា...។
- ឧកញ៉ា ក្រឡាហោមគង់ តស៊ូជាមួយបារាំងមិនខ្លាចបាត់បង់ជីវិត រហូតបារាំងប្រើល្បិចចាប់បានធ្វើទារុណកម្មចងផ្អោបនឹងបំពង់ផ្សែងកប៉ាល់ សំដៅទៅកោះត្រឡាចរហូតស្លាប់ ...វីរភាពប្រកបដោយឧត្ដមភាពនេះធ្វើឱ្យកូនខ្មែរចងចាំមិនភ្លេច។

## បកស្រាយផ្អែកលើអក្សរសិល្ប៍

⇨ រឿងព្រះវេស្សន្តរ (ដើម្បីឧត្តមភាពសាសនា ស៊ូលះបង់អ្វីគ្រប់យ៉ាង គឺអជ្ឈត្តិកទាន ពាហិរទាន)។

⇨ រឿងទុំទាវ (ទុំទាវ បានលះបង់ជីវិត ធ្វើជាគម្រូដល់យុវជនជំនាន់ក្រោយក្នុងការទាមទារសិទ្ធិ ... ប្រកបដោយឧត្តមភាព)។

⇨ រឿងភូមិតិរច្ឆាន (អ្នកភូមិក្រាំងលាវតស៊ូរើបម្រះលះបង់អាយុជីវិត ...ប្តូរឈ្មោះថាភូមិតិរច្ឆាន នេះជាឧត្តមភាពមួយ)។

⇨ រឿងរាមកេរ្តិ៍ (ហនុមាន លះបង់កម្លាំងកាយចិត្ត ជីវិត បម្រើព្រះវិស្ណុអវតារ ដើម្បីកំចាត់ភាវៈអាក្រក់ ទាំងនេះជាឧត្តមភាពមួយ)។

- សរុបសេចក្តី៖ សរុបសេចក្តីមកយោងតាមការបកស្រាយបង្ហាញខាងលើ សបញ្ជាក់ឱ្យឃើញថា តាមរយៈភស្តុតាងដែលបានលើកឡើងពីក្នុងសង្គមជាតិខ្មែរ និងអក្សរសិល្ប៍នានា បានបង្ហាញពីបុគ្គល តួអង្គសំខាន់ៗ ក្នុងការលះបង់អ្វីៗគ្រប់យ៉ាងបម្រើឱ្យបុព្វហេតុជាតិមាតុភូមិ ដែលជាឧត្តមភាពមួយប្រកបដោយវីរភាពយ៉ាងធំធេងបំផុត។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការ បកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើពិតជាផ្តល់តម្លៃអប់រំយ៉ាងល្អជ្រាលជ្រៅ ព្រោះពំនោលនេះ បានរួមចំណែកអប់រំមនុស្សទូទៅឱ្យចេះកសាង នូវគុណសម្បត្តិជូន សង្គមគ្រួសារ

សង្គមជាតិ ដោយហ៊ានបូជា កម្លាំងចិត្តកាយ អាយុជីវិត ពេលវេលាឥតស្តាយស្រណោះអ្វីឡើយ។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើង ជាអ្នកសិក្សាត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយបន្តនូវស្មារតីលះបង់អ្វីៗ ដើលខ្លួនមានទៅតាមលទ្ធភាពសម្រាប់សង្គមមនុស្ស។ លើសពីនេះចេះកសាងឧត្តមភាព ដោយធ្វើឱ្យកេរ្តិ៍ឈ្មោះល្បីខ្ចរខ្ចារ មានការដឹងគុណពីមនុស្សគ្រប់ជំនាន់តរៀងទៅ។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២៨៖** *គេថា៖«ម៉ឺង និងពូហំ មានភាវៈជាកូនប្រុស»។ ចូរបង្ហាញដោយលើកឧទាហរណ៍មកបញ្ជាក់ឱ្យបានពិស្តារ។*

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- *លំនាំបញ្ហា៖ យោងតាមការសិក្សាអក្សរសិល្ប៍ឃើញថា ម៉ឺងជាតួអង្គឯកដ៏សំខាន់នៃរឿងគូលីកំនែន ដែលជាស្នាដៃរបស់លោកអ៊ឹមថុក ឆ្នាំ១៩៥៦។ ចំណែកឯពូហំជាតួអង្គសំខាន់ នៃរឿងចៅកែចិត្តចោរ ដែលជាស្នាដៃរបស់លោកអ៊ុំ ឈឺន និងលោកពៅ យូឡេង ឆ្នាំ១៩៥៦។ អ្នកទាំងពីរសុទ្ធតែជាមនុស្សមានគំនិតដ៏ខ្ពង់ខ្ពស់ក្នុងចលនាលុបបំបាត់ចោល នូវកាកសំណល់អាក្រក់ក្នុងសង្គម ជាអ្នកដែលមានគំនិតអភិវឌ្ឍខាងផ្នែកតស៊ូទៅនឹងជីវិត។*
- *ចំណុចបញ្ហា៖ ទាក់ទងទៅនឹងករណីបែបនេះហើយ ទើបបានជាមានពំនោលមួយពោលថា៖ «ម៉ឺង និងពូហំ មានភាវៈជាកូនប្រុស»។*
- *ចំណោទបញ្ហា៖ តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថាអ្នកទាំងពីរជាមនុស្សដែលមានលក្ខណៈជាកូនប្រុស?*

### ខ. តួសេចក្តី

- *ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះយើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។*

- ពន្យល់ពាក្យគន្លឹះ៖ ភាវៈជាកូនប្រុស មានន័យថាអ្នកដែលមានជំហរ រឹងប៉ឹងមិនទ្រេតទ្រោត រេវារអល់រែអកចំពោះឧបសគ្គកើតមានចំពោះមុខ។
- ពន្យល់ន័យប្រធាន៖ ប្រធានមានន័យថាពូហំ និងម៉ឺង ជាមនុស្សដែលមានជំហររឹងប៉ឹងមិនទ្រេតទ្រោត រេវារអល់រែអកចំពោះមុខ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាតថភាពជាក់ស្តែងយើងឃើញថាច្បាប់ប្រុសបានចែងថា ក្នុងនាមជាកូនប្រុស គឺជាអ្នកឈ្នះ អ្នកដែលអាចធ្វើអ្វីៗបានដោយឥតទាស់អ្វីឡើយ។
  - ❖ រាល់ទង្វើរបស់កូនប្រុស បានស្តែងឡើងតាមរយៈគំនិតច្នៃប្រឌិត ចេះឃិតយោងជីវិតឱ្យឆ្ពោះទៅរកភាពរុងរឿង។
  - ❖ ក្នុងនាមជាកូនប្រុសគេ មិនកំសាក មិនមើលបំណាំរាល់ការងារធំៗ ដែលខ្លួនត្រូវបំពេញនោះឡើយ។ ពិសេសជានេះទៅទៀតរាល់កូនប្រុស ត្រូវធ្វើខ្លួនជាសសរទ្រូងនៃប្រទេសជាតិ។
  - ❖ ពេលជាតិមានវិបត្តិសង្គ្រាមកើតឡើងកូនប្រុសចេញមុខបម្រើក្នុងជួរកងទ័ព ដើម្បីការពារបូរណភាពទឹកដីឱ្យបានគង់វង្ស ស៊ូស្រក់ឈាមដល់ដី តែមិនលាក់មុខដូចអណ្តើកក្នុងស្នូក។
  - ❖ ជាកូនប្រុសត្រូវមានសមត្ថភាពពិតប្រាកដ ធ្វើអ្វីឱ្យជាក់លាក់ មានទំនួលខុសត្រូវខ្ពស់។

- ជាកូនប្រុសត្រូវមានចំណេះដឹង ជំនាញវិជ្ជាជីវខ្ពស់ មានសីលធម៌ក្នុងការរស់នៅ...។

**ម៉ឹងមានភារៈជាកូនប្រុស**

- ⇨ មានចំណេះវិជ្ជាខ្ពង់ខ្ពស់(ប្រឡងជាប់ចេញពីវិទ្យាល័យ)
- ⇨ មានសីលធម៌រស់នៅល្អ(រស់នៅផ្ទះជួលរបស់បងជីដូនមួយអ្នកគ្រូ គូ រស់ ឈ្មោះអ្នកគ្រូ ពេជ្រ ណារី ម៉ឹងស្រឡាញ់ គូ រស់ តែមិនដែលធ្វើអ្វីឱ្យខុសប្រពៃណីឡើយ)
- ⇨ មានជំហរទទួលខុសត្រូវនឹងការងារ(មានភាពម៉ឺងម៉ាត់ក្នុងការងារ)
- ⇨ មិនកំសាកនឹងពាក្យបំភិតបំភ័យ(មិនតក់ស្លុតក្នុងការគំរាមកំហែង ម៉ឹងហ៊ានតវ៉ាត្រង់ៗ នឹងបារាំងពេលគេគំរាមចាប់ដាក់គុក ម៉ឹងថា៖«បើខ្ញុំគ្មានសមត្ថភាពដកខ្ញុំចោលទៅ ខ្ញុំមិនអង្វរទេ ខ្ញុំមានកំហុសអ្វីបានជាលោកចង់ចាប់ខ្ញុំ»)
- ⇨ មានគំនិតស្រឡាញ់សិទ្ធិសេរីភាព និងឯករាជ្យ(ពេលដែលពួកបារាំងស៊ើបដឹងថាខ្លួនជាប្អូនប្រុសនូ ដួង ដែលជាក្រុមខ្មែរឥស្សរៈ ម៉ឹងក៏គេចខ្លួនចូលក្រុមចលនាតស៊ូខ្មែរឥស្សរៈ)
- ⇨ មិនមានវិប្បដិសារី ចំពោះពិការភាព គឺពិការដៃឆ្វេងម្ខាង ក្នុងបុព្វហេតុជាតិ( ការតស៊ូរបស់ប្រជាជនខ្មែរវៀតណាម ឡាវ ប្រជាជនស្នេហាជាតិលើសកលលោក

និងកិច្ចព្រមព្រៀម ហ្សឺណែវ បារាំងបានប្រគល់ឯករាជ្យឱ្យខ្មែរវិញ)

**ពូហំមានភាវៈជាកូនប្រុស**

- ⇨ មានសមត្ថភាពលើផ្នែកវិជ្ជាជីវៈ(មានវិជ្ជាជីវៈខាងបើកបររថយន្ត)
- ⇨ ហ្មត់ចត់ចំពោះកិច្ចការដែលខ្លួនត្រូវបំពេញ(ការងារបើកបរឡានរបស់ពូហំ ធ្វើឱ្យថៅកែពេញចិត្ត)
- ⇨ មានគំនិតលះបង់ខ្ពស់ចំពោះអនាគតគ្រួសារ(ជាសសរទ្រូងគ្រួសារ ដើម្បីទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ ហ៊ានធ្វើអំពើទុច្ចរិត)
- ⇨ ហ៊ានទទួលខុសត្រូវចំពោះអំពើ ដែលខ្លួនបានធ្វើ(សុខចិត្តជាប់គុកដើម្បី សេចក្តីយុត្តិធម៌ផុះឡើង)
- ⇨ មិនទន់ជ្រាយចំពោះការគំរាមកំហែងរបស់នាយទុន (ថៅកែគំរាមប្តឹងហំ ថាបើកឡានទៅបុកឡានអុងប៉ាងហុងលី)
- ⇨ មិនក្បត់ឧត្តមគតិខ្លួន(ប្រកែកឈប់យកប្រាក់ថៅកែ ទោះបីឱ្យប៉ុន្មានក៏ឈប់យក គឺចង់ឱ្យថៅកែជាប់គុកជាមួយខ្លួនដែរ)។

- សរុបសេចក្តី៖ សរុបសេចក្តីមក យោងតាមការបកស្រាយបង្ហាញខាងលើ សបញ្ជាក់ឱ្យឃើញថា តាមរយៈភស្តុតាងដែលបានលើកឡើងខាងលើនេះបានបង្ហាញពីសកម្មភាពរបស់តួអង្គ ម៉ឺង និងពូហំ ប្រកបដោយភាវៈជាកូនប្រុសក្នុងការប្រកាន់ នូវជំហរយ៉ាង

រឹងប៉ឹងមិនតក់ស្លុត ចំពោះហេតុការណ៍ ដែលកើតឡើងចំពោះមុខរបស់ពួកគេ។

### គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធានខាងលើពិតជាផ្ដល់តម្លៃអប់រំយ៉ាងល្អជ្រាលជ្រៅ ព្រោះពំនោលនេះបានរួមចំណែកអប់រំមនុស្សប្រុសទូទៅ ឱ្យចេះមានភាពក្លាហានប្រកាន់ជំហររឹងប៉ឹង ចេះសម្រេចចិត្តត្រូវលើកិច្ចការទាំងឡាយ។ ជាពិសេសជាងនេះ ទៅទៀតចង់ឱ្យបុរសៗគ្រប់រូបត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះគ្រួសារក៏ដូចជាសង្គមទាំងមូល ឱ្យសមជាបុរសដើមទ្រូងប្រាំហត្ថ។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាអ្នកសិក្សាត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយបើទោះបីយើងជាបុរសក្ដី ឬជាស្ត្រីក្ដី គឺត្រូវមានភាពជាមនុស្សប្រកបដោយគតិបណ្ឌិតហ៊ានពុះពារគ្រប់ឧបសគ្គ មិនរាថយ ក្នុងការស្ថាបនាប្រទេសជាតិឱ្យរុងរឿងដូចអារ្យប្រទេស។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី២៩៖** មតិខ្លះយល់ថា៖«រឿងភូមិតិរច្ឆាន និងរឿងចៅកែចិត្តចោរពុំបានអប់រំបណ្តុះស្មារតីមនុស្ស ឱ្យស្រឡាញ់លទ្ធិប្រជាធិបតេយ្យទេ»។ តើអ្នកយល់យ៉ាងណា? ចូរពិភាក្សា។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ នៅក្នុងវណ្ណកម្មអក្សរសិល្ប៍ គឺសុទ្ធតែបានលើកយកបញ្ហារបស់មនុស្សនៅក្នុងសង្គម មកចោទនិងដោះស្រាយជានិច្ច។ ក្នុងស្នាដៃនីមួយៗអ្នកនិពន្ធបានខិតខំបង្កើតឡើង ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីតថភាព ដែលកើតមានឡើង ពិតនៅក្នុងសង្គមខ្មែរ នាសម័យណាមួយយ៉ាងប្រត្យក្ស។ បើយើងក្រឡេកមកមើលរឿងភូមិតិរច្ឆាន និងរឿងចៅកែចិត្តចោរវិញ ឃើញថាជារឿងដែលបានបង្ហាញអំពីការរំលោភបំពាន លើសិទ្ធិសេរីភាព របស់ប្រជារាស្ត្រ ពីសំណាក់អ្នកដឹកនាំ អ្នកមានអំណាច ដោយពុំបានគោរពនូវគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យនោះទេ។
- ចំណូលបញ្ហា៖ ហេតុនេះហើយទើបធ្វើឱ្យមានទស្សនៈមតិខ្លះយល់ថា៖«រឿងភូមិតិរច្ឆាន និងរឿងចៅកែចិត្តចោរពុំបានអប់រំបណ្តុះស្មារតីមនុស្សឱ្យស្រឡាញ់លទ្ធិប្រជាធិបតេយ្យទេ»។
- ចំណោទបញ្ហា៖ តើទស្សនៈមតិដែលបានពោលថា៖«រឿងភូមិតិរច្ឆាន និងរឿងចៅកែចិត្តចោរពុំបានអប់រំបណ្តុះស្មារតីមនុស្សឱ្យស្រឡាញ់លទ្ធិប្រជាធិបតេយ្យទេ» ត្រឹមត្រូវឬទេ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាមូលដ្ឋាន ក្នុងការបកស្រាយនូវទស្សនៈរបស់ប្រធាន ខាងលើឱ្យមានភាពច្បាស់លាស់ និងកាន់តែល្អនោះ យើងត្រូវស្វែងយល់ឱ្យបានច្បាស់នូវពាក្យគន្លឹះរបស់ប្រធានជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ អប់រំ មានន័យថាការទូន្មានឱ្យដើរផ្លូវត្រូវ ផ្លូវល្អ។ បណ្តុះស្មារតី មានន័យថាបង្កើតឱ្យមាននូវគំនិតថ្មីៗ។ លទ្ធិប្រជាធិបតេយ្យ មានន័យថារបបគ្រប់គ្រងដែលគតិប្រយោជន៍រាស្ត្រគិតមតិភាគច្រើនជាធំ។
- ពន្យល់ន័យប្រធាន៖ ទស្សនៈប្រធានមានន័យថា រឿងភូមិតិរច្ឆាន និងរឿងថៅកែចិត្តចោរ ពុំបានទូន្មានឱ្យដើរផ្លូវត្រូវ ផ្លូវល្អដើម្បីបង្កើតឱ្យ មាននូវគំនិតថ្មីៗ តាមបែបរបបគ្រប់គ្រងដែលគិតប្រយោជន៍រាស្ត្រ គិតមតិភាគច្រើនជាធំនោះទេ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
    - ❖ ជាការពិតណាស់បើយើងធ្វើការសិក្សា ឱ្យបានច្បាស់លាស់ទៅឃើញថា រឿងភូមិតិរច្ឆាន និងរឿងថៅកែចិត្តចោរ ពិតជាពុំបានឆ្លុះបញ្ចាំងឱ្យឃើញពីស្មារតី ក្នុងការបណ្តុះស្មារតីមនុស្ស ឱ្យមានចិត្តស្រឡាញ់ នូវលិទ្ធិប្រជាធិបតេយ្យឡើយ ព្រោះបើតាមរយៈខ្លឹមសារនៃរឿងទាំងពីរ គឺសុទ្ធតែលើកយក ពីបញ្ហានៃការជិះជាន់របស់ អ្នកមានអំណាច អ្នកមានបុណ្យសក្តិ អ្នកមានទ្រព្យសម្បត្តិ មកលើរាស្ត្រទន់ខ្សោយដោយគ្មានត្រាប្រណី។

+ មតិស្របៈ រឿងភូមិតិរច្ឆាន និងរឿងថៅកែចិត្តចោរ ពុំបាន អប់រំបណ្តុះស្មារតីមនុស្សឱ្យស្រឡាញ់លទ្ធិប្រជាធិបតេយ្យ នោះទេព្រោះ៖

**រឿងភូមិតិរច្ឆាន** (គ្មានអ្នកគិតគូរវាស្រ្តជាធំនោះទេ)

- ⇨ ទុក្ខវេទនារបស់រាស្ត្រមិនមានអ្នកគិតគូរ (គ្មានលុយបង់ពន្ធ"ដូចជាសុវណ្ណ" ជួបគ្រោះទុរភិក្ស រាំងស្ងួត ជីវិតអនាថា"ដូចជានាងតន់ជាដើម")
- ⇨ ជាប់កំនែន (បារាំងមានចម្បាំង ជាមួយអាល្លឺម៉ង់កាន់តែខ្លាំង បារាំងបានបញ្ជាឱ្យកេណ្ឌទ័ពពីប្រទេស ដែលខ្លួនត្រួតត្រា ដើម្បីយកទៅច្បាំងឱ្យស្លាប់ជំនួសវា ដូចជា នាយសាត និងនាយឡុញ ដែលមិនឃើញត្រឡប់មកវិញ ហើយអ្នកទាំងពីរជាប្អូនរបស់សុវណ្ណ និងប៊ុត)
- ⇨ ការជិះជាន់កេងប្រវ័ញ្ច(ការកាន់អំណាចរបស់បូង្វាំង មានការជិះជាន់រាស្ត្រដោយចេះតែដំឡើងពន្ធ រហូតរាស្ត្របះបោរប្រឆាំងតប ដូចជាកម្មករនៅខេត្តសៀមរាប លួចធ្វើឃាតលោក កូម៉យ អ្នកអភិរក្សអង្គរ ព្រោះកេងប្រវ័ញ្ចប្រាក់កម្មករតែបារាំងនិយាយបំភ្លៃថាវាជាអំពើចោរកម្មទៅវិញ)
- ⇨ អំពើឃោរឃៅផ្តាច់ការ (បារដេស ដើរទារពន្ធដោយខ្លួនឯង ដើម្បីផ្គាប់ចិត្តចៅហ្វាយនាយ "

បូផ្ទាំង" បើគ្មានប្រាក់បង់ពន្ធទេ នឹងត្រូវជាប់ខ្នោះ ដូចជាប្ដីនាងនី នាងប៊ី...)

⇨ ការក្រោកឡើងតស៊ូ របស់រាស្ត្របរាជ័យយ៉ាងធ្ងន់ធ្ងរ (បក្សពួករួមអាវុធត្រូវស្លាប់គ្មានសល់ លើកលែងតែសុវណ្ណមួយគត់ ដែលរួចខ្លួន ព្រោះគេរអាណិតដល់សុវណ្ណ...)។

**រឿងថៅកែចិត្តចោរ** (គ្មានអ្នកគិតគូររាស្ត្រជាធំនោះទេ)

⇨ ការកេងប្រវ័ញ្ច ឆក់ប្លន់ ការជិះជាន់របស់នាយទុន (ថៅកែអាងទឹកលុយ មើលងាយទឹកចិត្តមនុស្ស)

⇨ រាស្ត្រវេទនាក្រីក្រ (កម្មករខ្វះខាត ជីវភាពលំបាក)

⇨ អំពើអយុត្តិធម៌ របស់អ្នកកាន់អំណាច ពុករលួយ (សែហ្វ ជាអ្នកកាន់ច្បាប់តែបែរជាបំពានច្បាប់)

⇨ អំពើផ្ដាច់ការ (គង់និយាយបញ្ចេញមតិ ធ្វើឱ្យគង់ត្រូវនគរបាលចាប់ខ្លួន)

⇨ ការតស៊ូរបស់កម្មករ បរាជ័យយ៉ាងធ្ងន់ធ្ងរ (គង់ មាន សុខ ទ្វី ផានីត ពូហំ ខ្លះត្រូវអស់ការងារធ្វើ ខ្លះត្រូវជាប់គុក ក៏ព្រោះតែចង់ឱ្យអំពើ របស់ថៅកែត្រូវបានលាតត្រដាង)

+ សរុបមតិស្របៈ សរុបមកឃើញថានៅក្នុងរឿងភូមិតិរច្ឆាន និងរឿងថៅកែចិត្តចោរ ពិតជាពុំបានអប់រំបណ្តុះស្មារតីមនុស្សឱ្យមានទឹកចិត្តស្រឡាញ់លទ្ធិប្រជាធិបតេយ្យនោះទេ ព្រោះបានត្រឹមតែបង្ហាញឱ្យឃើញពីការរងទុក្ខវេទនារបស់រាស្ត្រតែប៉ុណ្ណោះ។ ការយល់ឃើញបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

✵ សំណួរភ្ជាប់សេចក្តីៈ តើរឿងទាំងពីរខាងលើពិតជាដូចការអះអាងខាងលើឬយ៉ាងណា?

+ មតិផ្ទុយៈ ទោះបីមជ្ឈដ្ឋានខាងលើខំធ្វើការអះអាង ជាមួយនឹងភស្តុតាងយ៉ាងជាក់ស្តែងគួរឱ្យស្តាប់បានយ៉ាងណា ក៏ដោយក៏គេនៅតែឃើញមានមតិមួយចំនួន គេនៅតែមិនយល់ស្របគំនិតខាងលើនេះទាំងស្រុងនោះដែរ ព្រោះរឿងទាំងពីរបានអប់រំបណ្តុះស្មារតីមនុស្សឱ្យស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ពិតប្រាកដៈ

**រឿងភូមិតិរច្ឆាន** (ការតស៊ូរបស់រាស្ត្រ នៅក្នុងរឿងនេះប្រឆាំងនឹងការជិះជាន់ ដើម្បីទាមទារសិទ្ធិសេរីភាព ប្រជាធិបតេយ្យ)

⇨ រាស្ត្រធ្វើញត្តិតវ៉ា (នៅថ្ងៃ០៧ មករា ១៩១៦ បណ្តារាស្ត្រនៅមុខកំពូលខេត្តកណ្តាល ជាង ៣០០០នាក់ បានលើកគ្នាមកភ្នំពេញ ឱ្យព្រះបាទស៊ីសុវត្ថិ ជួយស្នើសុំឱ្យបន្ធូរបន្ថយពន្ធព្រះអង្គសន្យាថា ចាំនិយាយ និងគេឱ្យគេជួយ

បន្ធូរបន្ថយឱ្យ តែជាលទ្ធផល ត្រូវបាត់ស្រមោលសូន្យ ពន្ធនៅតែឡើងដដែល រហូតរាស្ត្រទ្រាំលែងបាន)

- ⇨ ជូន និងនៅ រៀបចំគម្រោងការសម្លាប់ប្ញារដេសបានសម្រេច (ជូន នៅ និងបក្សពួករួមអាវុធ ២០នាក់ ទៀតស្រុះស្រួលគ្នា ក្នុងការកំចាត់ប្ញារាំងប្ញារដេស ពីទឹកដី)
- ⇨ នាងនី នាងប៊ី ថ្កោលទោសប្ញារាំង (លោកធ្វើចៅហ្វាយលើខ្មែរ លោកមើលឃើញត្រឹមប្រាក់មួយមុខប៉ុណ្ណោះ ចង់ខ្មែរធ្វើស្រែមិនបាន ខ្មែរដាច់ពោះស្លាប់ លោកឥតឈឺក្បាលអ្វីទេ លោកគិតតែសង្វៀញទារពន្ធ ឱ្យខាងតែបាន។ នេះឬដែលហៅថាអ្នកអាណាព្យាបាល?)
- ⇨ ទឹកចិត្តនាងតន់ (នាងមិនរាំងស្ទះបំណងប្តី ក្នុងការចូលរួមសម្លាប់ប្ញារដេសទេ នាងបានវេចបាយឱ្យប្តីខ្លាចប្តីដាច់ខ្នោះ ពេលប្តីមិនដាច់ខ្នោះក៏វិលមកផ្ទះវិញ)។

**រឿងថៅកែចិត្តចោរ** (ការតស៊ូរបស់ពួកកម្មករដើម្បីទាមទារ យុត្តិធម៌ លទ្ធិប្រជាធិបតេយ្យ)

- ⇨ ពូហំសុខចិត្តជាប់គុក ដើម្បីយុត្តិធម៌ (បដិសេធឈប់ ទទួលប្រាក់ថៅកែ ទោះបីថៅកែឱ្យគាត់

ប៉ុន្មានក៏គាត់ឈប់យកដែរ គឺគាត់ចង់ឱ្យថៅកែជាប់គុកដែរ)

⇨ ផានិតសុខចិត្តឈប់ពីការងារ (ខ្ញុំបូកលេខលែងត្រូវខ្ទង់ទៀតហើយ ខ្ញុំសុំឈប់ធ្វើការហើយ ក្បួនគេបង្រៀនពីសាលាទាំងប៉ុន្មាន យកមកប្រើក្នុងជីវិតមិនត្រូវសោះ)។

+ សរុបមតិផ្ទុយ៖ សរុបសេចក្ដីមកឃើញថា នៅក្នុងរឿងភូមិតិរច្ឆាន និងរឿងថៅកែចិត្តចោរ ពិតជាធ្វើឱ្យរឿងទាំងពីរនេះ បានអប់រំបណ្ដុះស្មារតីមនុស្ស ឱ្យចេះតស៊ូ ចេះសាមគ្គី ចេះឈឺឆ្អាលរឿងអ្នកដទៃ ដើម្បីស្វែងរកភាពត្រឹមត្រូវ យុត្តិធម៌ គិតប្រយោជន៍រួមនៃមនុស្សទូទៅជាធំចំបង ដែលគេហៅថាលទ្ធិប្រជាធិបតេយ្យ។ ការគិតបែបនេះក៏មានន័យត្រឹមត្រូវម្យ៉ាងដែរ។

- សំយោគមតិ ៖ រួមមកយើងឃើញថា ការបកស្រាយបង្ហាញខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និដ្ឋានបានថាមតិទីមួយខាងលើមិនទាន់សមហេតុសមផលត្រឹមត្រូវទេ។ ចំណែកឯមតិទីពីរវិញសមហេតុផលជាងព្រោះរឿងទាំងពីរខាងលើពិតជាបានចូលរួមចំណែក ក្នុងការអប់រំបណ្ដុះស្មារតីមនុស្សឱ្យមានទឹកចិត្តស្រឡាញ់នូវសង្គមមួយដែលយុត្តិធម៌ មានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

### គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធាន ខាងលើរួចមក

ឃើញថា ទស្សនៈរបស់ប្រធានដែលបានពោលនេះ គឺមិនទាន់មានន័យត្រឹមត្រូវនោះទេ ព្រោះថារាល់ស្នាដៃអក្សរសិល្ប៍ដែលមានលក្ខណៈជឿនលឿន តែងតែអប់រំអ្នកសិក្សា ក៏ដូចជាមនុស្សទូទៅឱ្យមានទឹកចិត្តស្រឡាញ់នូវ សេរីភាព លទ្ធិប្រជាធិបតេយ្យ។ម្យ៉ាងទៀតប្រសិនបើ រាល់ស្នាដៃដែលអ្នកនិពន្ធបានចងក្រងឡើងសម្រាប់ឱ្យយើងសិក្សា មិនមានលក្ខណៈអប់រំឱ្យយើងមានឆន្ទៈប្រកបដោយលទ្ធិប្រជាធិបតេយ្យទេនោះ នោះក្រសួងអប់រំ ក៏គេមិនដាក់បញ្ចូលវា ក្នុងកម្មវិធីសិក្សាសម្រាប់ឱ្យយើងសិក្សាស្វែងយល់ដែរ។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ ហើយយើងត្រូវចេះឱ្យតម្លៃលើស្នាដៃអក្សរសិល្ប៍ដែលអ្នកនិពន្ធគ្រប់រូបខិតខំតែងនិពន្ធឡើងដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ព្រោះវាសុទ្ធតែមានតម្លៃអប់រំល្អៗ ក្នុងការយកទៅអនុវត្តក្នុងជីវភាពជាក់ស្ដែង។
- ពាក្យស្លោក ឬសុភាសិត

**ប្រធានទី៣០៖** មានមតិមួយយល់ឃើញថា៖"ការធ្វើសង្គ្រាមត្រូវពឹងលើកម្លាំងទ័ពទើបជោគជ័យ"។ រីឯមតិមួយទៀតយល់ឃើញថា៖"ការធ្វើសង្គ្រាមត្រូវពឹងលើកម្លាំងប្រាជ្ញាទើបជោគជ័យ"។ តើអ្នកយល់យ៉ាងណា?

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ ជីវិតមនុស្សម្នាក់ៗតែងតែជួបប្រសព្វជាមួយនឹងទំនាស់វិបត្តិផ្សេងៗ ដែលទំនាស់វិបត្តិអាចត្រឹមតែជាទំនាស់ពាក្យសម្តី ឬក៏ទំនាស់ទៅដោយប្រដាប់អាវុធ។ ហើយនៅពេលមានទំនាស់កើតឡើងដៃគូរភាគីតែងតែចង់ឈ្នះរៀងៗខ្លួន ដោយប្រើល្បិចឬក៏បច្ចេកទេសដោយឡែកៗពីគ្នា។
- ចំណូលបញ្ហា៖ អាស្រ័យដោយបញ្ហាបែបនេះហើយទើបមានមតិពីរយល់ឃើញផ្ទុយគ្នាដោយមតិទី១យល់ថា៖"ការធ្វើសង្គ្រាមត្រូវពឹងលើកម្លាំងទ័ពទើបជោគជ័យ"។ រីឯមតិមួយទៀតយល់ឃើញថា៖"ការធ្វើសង្គ្រាមត្រូវពឹងលើកម្លាំងប្រាជ្ញាទើបជោគជ័យ"។
- ចំណោទបញ្ហា៖ តើមតិទាំងពីរនេះមួយណាសមហេតុផលជាង?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ មុននឹងឈានទៅដល់ការពិភាក្សានូវមតិទាំងពីរដែលបានលើកឡើងឱ្យបានក្បោះក្បាយមុនដំបូងយើងគួរយល់ន័យរបស់ពាក្យសង្គ្រាម ពាក្យកម្លាំងទ័ព និងពាក្យកម្លាំងប្រាជ្ញាជាមុនសិន។ ពាក្យសង្គ្រាមមានន័យថាការតបតប្រឆាំងគ្នាដោយប្រើ

កម្លាំងអាវុធ ឬកម្លាំងប្រាជ្ញា។ រីឯពាក្យកម្លាំងទ័ពមានន័យថាការប្រើប្រាស់កម្លាំងមនុស្សជាច្រើនក្នុងការប្រយុទ្ធគ្នា។ ហើយចំណែកឯពាក្យកម្លាំងប្រាជ្ញាមានន័យថាការគិតពិចារណាដោយប្រើខួរក្បាល។

- ពន្យល់ពាក្យគន្លឹះ៖ ពាក្យសង្គ្រាម មានន័យថាការប្រយុទ្ធប្រឆាំងគ្នាដើម្បីផលប្រយោជន៍ណាមួយដោយមធ្យោបាយផ្សេងៗ។ ពាក្យកម្លាំងទ័ព មានន័យថាការប្រើប្រាស់កម្លាំងកាយក្នុងការច្បាំងដណ្តើមយកជ័យជំនះ។ ពាក្យកម្លាំងប្រាជ្ញា មានន័យថាការប្រើប្រាស់គំនិតប្រាជ្ញាក្នុងការច្បាំងដណ្តើមយកជ័យជម្នះ។
- ពន្យល់ន័យប្រធាន៖ យោងតាមន័យរបស់ពាក្យគន្លឹះទាំងបីខាងលើនេះប្រធានដែលបានលើកឡើងចង់មានន័យថាដើម្បីឱ្យការប្រយុទ្ធប្រឆាំងគ្នាទទួលបានជោគជ័យ គេត្រូវប្រើប្រាស់វិធីសាស្ត្រ ឬមធ្យោបាយផ្សេងៗ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការពិតណាស់នៅក្នុងសង្គមនីមួយៗ តែងតែដណ្តើមយកនូវផលប្រយោជន៍រៀងៗខ្លួន ហើយការប្រយុទ្ធប្រឆាំងគ្នាម្តងៗ សង្គមតែងតែប្រើប្រាស់កម្លាំងមនុស្សក្នុងការប្រកួតប្រជែង ដណ្តើមយកជ័យជំនះ។

  \+ មតិស្រប៖

  ⇨ យកកម្លាំងមនុស្ស ទៅបញ្ជាលើគ្រឿងយន្ត កាំភ្លើងធំ រថក្រោះ

⇨ មនុស្សអាចបោះជំរុំទ័ព

⇨ មនុស្សវាយមនុស្ស

⇨ មនុស្សអាចប្រើកម្លាំងទប់ស្កាត់ឧបសគ្គ

⇨ មនុស្សបញ្ជាអ្វីមួយឱ្យមានសកម្មភាព

**ឧទាហរណ៍** (ក្នុងសង្គម)

⇨ សម័យអង្គរ(សង្គ្រាមរវាងព្រះបាទជ័យវរ្ម័នទី៧ និងពួកចម្ប៉ា)

⇨ សម័យលង្វែក(ចម្បាំងរវាងព្រះបាទចន្ទរាជា និងស្តេចកន)

⇨ សម័យអាណានិគមបារាំង(សីហនុប្រើកម្លាំងស្ត្រីប្រយុទ្ធប្រឆាំងយកឯករាជ្យ)

**ឧទាហរណ៍** (ក្នុងអក្សរសិល្ប៍)

⇨ រឿងគូលីកំណែន(ការកែនទ័ពខ្មែររបស់ពួកបារាំងទៅច្បាំងជាមួយអាល្លឺម៉ង់)

⇨ រឿងភូមិតិរច្ឆាន(ការតស៊ូរបស់អ្នកក្លាហាន ជួន នៅ...)

⇨ រឿងវិលរកទ្រនំ(ការច្បាំងរវាងក្រុមចាកា និងក្រុមអាវខ្មៅ...)

+ សរុបមតិស្រប៖ សរុបសេចក្តីមកការប្រយុទ្ធប្រឆាំង ឬការធ្វើសង្គ្រាមដែលទទួលបានលទ្ធផលមួយគាប់ប្រសើរ គឺត្រូវពឹងពាក់កម្លាំងមនុស្សជាសំខាន់ក្នុងការកាន់កាប់ទៅលើគ្រឿងយន្ត...។

✵ សំណួរភ្ជាប់សេចក្តី៖ តើភាពជោគជ័យនៃការធ្វើសង្គ្រាមសុទ្ធតែពឹងពាក់លើកម្លាំងទ័ពទាំងអស់ឬ?

+ មតិផ្ទុយ៖ ទោះបីជាមតិខាងលើខិតខំលើអំណះអំណាង និងហេតុផលមកបញ្ជាក់ពីការធ្វើសង្គ្រាមមួយដោយជោគជ័យទៅលើកម្លាំងមនុស្សយ៉ាងណាក៏ដោយ ក៏នៅតែមានភាពខ្វះចន្លោះដដែល វាផ្ទុយពីនេះទាំងស្រុងបើយើងក្រឡេកទៅមើលការធ្វើសង្គ្រាមធំៗនៅក្នុងលោក យើងពិតជាឃើញមិនខាននូវការធ្វើសង្គ្រាមមួយដែលទទួលជ័យជំនះដោយកម្លាំងប្រាជ្ញា គឺការប្រើនូវចិត្តគំនិតក្នុងការរកវិធីសាស្ត្រ ល្បិចកល មធ្យោបាយប្រយុទ្ធទៅលើដៃគូបដិបក្ខ។

⇨ ការរៀបចំឧបាយកលរបស់មេទ័ពនីមួយ

⇨ ការរិះរកវិធីសាស្ត្រក្នុងការប្រយុទ្ធ

⇨ ការបំបាក់ទឹកចិត្តរវាងគូសត្រូវ

⇨ ការបំភាន់ភ្នែកសត្រូវ...

**ឧទាហរណ៍** (ក្នុងសង្គម)

⇨ សង្គ្រាមត្រជាក់(ការដោះស្រាយទំនាស់ដោយពាក្យសម្តី ការចរចារគ្នា" ជៀសវាងការប្រើប្រាស់កម្លាំងកាយដោះស្រាយ)

⇨ ការដាក់អាណានិគមរបស់បារាំងមកលើខ្មែរនៅឆ្នាំ ១៨៥៣

⇨ ការសុំទឹកដីកម្ពុជាក្រោមរបស់ពួកវៀតណាម...

**ឧទាហរណ៍** (ក្នុងអក្សរសិល្ប៍)

⇨ រឿងតេជោយ៉ត(ការប្រើប្រាជ្ញារកសត្រូវពីក្រោយខ្នង...)

⇨ រឿងកុមារកំព្រា(កុមារប្អូនប្រើគំនិតក្នុងការ ធ្វើដុចដាក់យក្ស)

⇨ រឿងសុភាទន្សាយ(ទន្សាយភូតពួកសត្វចតុប្បាទ ថាខ្លួនទទួលសារពីព្រះឥន្ទ...)

\+ សរុបមតិផ្ទុយ៖ សរុបសេចក្តីមកការធ្វើសង្គ្រាមមួយដែលទទួលលទ្ធផលជោគជ័យល្អ គឺអាស្រ័យទៅលើគំនិតវៃឆ្លាត របស់ក្រុមកម្លាំងទ័ព និងមេដឹកនាំ...។

- សំយោគមតិ៖ រួមមកយើងឃើញថា ការបកស្រាយបង្ហាញខាងលើសុទ្ធតែបង្ហាញនូវគោលជំហររៀងៗខ្លួន តែយើងអាចសន្និដ្ឋានបានថាមតិទីមួយខាងលើសមហេតុសមផលត្រឹមត្រូវមួយផ្នែក។ ចំណែកឯមតិទីពីរវិញសមហេតុផលមួយផ្នែក ព្រោះមតិទាំងពីរខាងលើពិតជាបានចូលរួមចំណែក ក្នុងការអប់រំបណ្តុះស្មារតីមនុស្សឱ្យចេះរកវិធីសាស្ត្រក្នុងការប្រកួតប្រជែងទៅលើរឿងរៀនសូត្រ និងការធ្វើការ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធាន ខាងលើរួចមកឃើញថា ទស្សនៈរបស់ប្រធានដែលបានពោលនេះ គឺបំពេញន័យឱ្យគ្នាទៅវិញទៅមក ព្រោះថាការធ្វើសង្គ្រាមមួយដែលប្រកបទៅដោយលក្ខណៈបរិបូណ៌នៅអាស្រ័យលើកត្តាទាំងពីរនេះ គឺកម្លាំងមនុស្ស និងកម្លាំងប្រាជ្ញា។

- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ និងអភិវឌ្ឍន៍ឱ្យរីកចម្រើនក៏ឱ្យប្រទេសដទៃមើលងាយបាន។

**ប្រធានទី៣១៖** មតិអ្នកសិក្សាមួយចំនួនបានចោទថា៖ «រឿងគូលីកំណៃនមានខ្លឹមសារណែនាំឱ្យបន្ថយជំនឿលើព្រះពុទ្ធសាសនា។ ដូចនេះមិនគួរគប្បីយករឿងនេះមកសិក្សាឡើយ»។ តើអ្នកយល់ដូចម្តេច? ចូរពិភាក្សា។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ ប្រជាជនខ្មែរភាគច្រើនសុទ្ធតែអ្នកកាន់ពុទ្ធសាសនា ហើយជឿជាក់យ៉ាងមុតមាំក្នុងវិស័យពុទ្ធសាសនា។ ចំណែកច្បាប់រដ្ឋធម្មនុញ្ញខ្មែរ ក៏បានចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ រីឯក្នុងស្នាដៃអក្សរសិល្ប៍រឿងគូលីកំនៃនរបស់លោកអ៊ុម ធុក ក៏បានលើកបញ្ហាជំនឿសាសនានេះដែរ។
- ចំណូលបញ្ហា៖ អាស្រ័យដោយការលើកយកមកនិយាយបែបនេះ ហើយទើបមានមតិរិះគន់ខ្លះដែរថា៖ «រឿងគូលីកំណៃនមានខ្លឹមសារណែនាំឱ្យបន្ថយជំនឿលើព្រះពុទ្ធសាសនា។ ដូចនេះមិនគួរគប្បីយករឿងនេះមកសិក្សាឡើយ»។
- ចំណោទបញ្ហា៖ តើការយល់ឃើញដូចខាងលើនេះត្រឹមត្រូវដែរឬទេ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ជាបឋមយើងគួរគប្បីយល់នូវខ្លឹមសាររបស់ពាក្យបន្ថយជំនឿ និងព្រះពុទ្ធសាសនាជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ខ្លឹមសារ សំដៅយកន័យថាអត្ថប្រយោជន៍ ឬសារៈសំខាន់។ រីឯពាក្យបន្ថយជំនឿ មានន័យថាធ្វើឱ្យចុះថយនូវ

ការជឿជាក់ទៅលើអ្វីមួយ។ ចំពោះព្រះពុទ្ធសាសនាសំដៅទៅលើឱវាទ ឬពាក្យទូន្មានរបស់ព្រះពុទ្ធសមណគោតម។

- ពន្យល់ន័យប្រធាន៖ យោងតាមន័យរបស់ពាក្យគន្លឹះខាងលើទស្សន:ដែលបានលើកឡើងចង់មានន័យថារឿងគូលីកំណែន ជាស្នាដៃអក្សរសិល្ប៍មួយប្រភេទដែលមាននិន្នាការទៅរកលទ្ធិសង្គមនិយម។ វណ្ណកម្មនេះត្រូវបានលើកអ៊ឹម ផុក តាក់តែងឡើងក្នុងគោលបំណងកែប្រែគំនិតមនុស្សខ្មែរ ឱ្យឆ្ពោះទៅរកអ្វីដែលមានលក្ខណជឿនលឿនទាន់សន្ទុះនៃការរីកចម្រើនរបស់មនុស្សជាតិ។
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំហេតុផល និងឧទាហរណ៍បញ្ជាក់ ដូចខាងក្រោម
  - ❖ ជាការពិតណាស់រឿងបានបង្ហាញឱ្យអ្នកសិក្សាមួយចំនួនយល់ថាខ្លឹមសារនៃរឿងគឺណែនាំ ឱ្យមនុស្សកាត់បន្ថយជំនឿលើព្រះពុទ្ធសាសនា គេយល់ឃើញបែបនេះដោយសំអាងទៅលើហេតុផលមួយចំនួនដូចតទៅ៖

  \+ មតិស្រប៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាង៖

    - ⇨ យកទស្សន:បដ្ឋឹមប្រទេសមកលាយឡំ...
    - ⇨ បង្ហាញពីភាពអវិជ្ជមាននៃសាសនាព្រះពុទ្ធ...
    - ⇨ ប្រៀបធៀបពីចំណុចអសកម្មនៃសាសនា...
    - ⇨ មិនឱ្យតម្លៃនៃព្រះពុទ្ធសាសនា...
    - ⇨ បួសរៀននៅវត្តតែបែរមិនធ្វើតាមការទូន្មានតាមឱវាទព្រះពុទ្ធសាសនា...

**ឧទាហរណ៍**

⇨ តួអង្គតាង៉ែត យាយម៉ុក មានជំនឿស៊ប់ទៅលើព្រះពុទ្ធ...

⇨ តួអង្គលឹម ថាឱ្យអាចារ្យឆេង "ដោយលាតត្រដាងពីទ្រឹស្តីសាសនា..."

\+ សរុបមតិស្រប៖ សរុបសេចក្តីមករឿងនេះពិតជាបានបង្ហាញពីការបន្ថយចុះនៃឥទ្ធិពលសាសនាព្រះពុទ្ធ....

✵ សំណួរភ្ជាប់សេចក្តី៖ តើរឿងនេះពិតជាបានកាត់បន្ថយជំនឿពុទ្ធសាសនាមែនឬ?

\+ មតិផ្ទុយ៖ វាមិនពិតទាំងអស់នោះទេ បើយើងក្រឡេកឱ្យបានច្បាស់លាស់វិញ...

⇨ វត្តអារាមសម្រាប់ទ្រង់ទ្រព្រះធម៌ ព្រះសង្ឃ

⇨ សម្រាប់បណ្តុះចំណេះដឹង(ចំណេះដឹងទូទៅ និងចំណេះជំនាញ)

⇨ ឱ្យជឿទៅលើទ្រឹស្តីព្រះពុទ្ធ...

⇨ សាសនាព្រះពុទ្ធឱ្យប្រកាន់ធម៌ខន្តី សន្តិភាព

⇨ ស្វែងរកសេក្តីសុខរបស់មនុស្ស

**ឧទាហរណ៍**

⇨ វត្តដែលលឹមបួសរៀន ជួយបង្រៀនលឹមឱ្យចេះពិចារណាដោយហេតុ និងផល

⇨ វត្តឧណ្ណាលោម ដែលតាង៉ែត យាយម៉ុក នាងក្រហេងទៅជ្រក...

+ សរុបមតិផ្ទុយ៖ សរុបសេចក្តីមកឃើញថា នៅក្នុងរឿងគូលីកំរែណែន ពិតជាធ្វើឱ្យអ្នកអាន អ្នកស្តាប់នូវការអប់រំបណ្តុះស្មារតីមនុស្ស ឱ្យចេះ...

- សំយោគមតិ៖ ជារួមមកយើងឃើញថាការបកស្រាយខាងលើសុទ្ធតែបង្ហាញ នូវគោលជំហររៀងៗខ្លួន តែយើងសន្មតបានថាជុំវិញបញ្ហា ដែលបានចោទឡើង...។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ជាយោបល់បញ្ចប់ដោយឆ្លងតាមការបកស្រាយយ៉ាងលម្អិតចំពោះទស្សនៈរបស់ប្រធាន ខាងលើរួចមកឃើញថា ទស្សនៈរបស់ប្រធានដែលបានពោលនេះ គឺថាមិនទាន់ត្រឹមត្រូវនោះទេ គឺជាទស្សនៈអាត្មានិយម ព្រោះថា...។
- ទស្សនផ្ទាល់ខ្លួន៖ ក្នុងនាមយើងជាក្នុងនាមយើងជាអ្នកសិក្សា ត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានជ្រៅជ្រះ ដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដសម្រាប់ប្រទេសជាតិ និងស្វែងយល់ពីគោលបំណងរបស់អក្សរសិល្ប៍ឱ្យបានច្បាស់ជៀសវាងការភ័ន្តច្រឡំ។

**ប្រធានទី៣២៖** ចូរអ្នកប្រៀបធៀប"ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យបច្ចុប្បន្ន ទៅនឹងសម័យអាណានិគមនិយមបារាំង-ជប៉ុន"។ តើជីវភាពរស់នៅរបស់ប្រជាជននាសម័យទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងដូចម្ដេចខ្លះ?

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ សង្គមផ្លាស់ប្ដូរ អ្វីៗក៏ផ្លាស់ប្ដូរទៅតាមនោះដែរ។
- ចំណូលបញ្ហា៖ ដោយសារបញ្ហាបែបនេះហើយទើបបានជាមានមតិមួយលើកឡើងថា៖ "ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យបច្ចុប្បន្ន ទៅនឹងសម័យអាណានិគមនិយមបារាំង-ជប៉ុន"។
- ចំណោទបញ្ហា៖ តើមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ ដើម្បីបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ គប្បីត្រូវយល់ន័យនៃពាក្យគន្លឹះជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ជីវភាព មានន័យថាភាពនៃការរស់នៅ ការចិញ្ចឹមជីវិត។ សម័យអាណានិគមនិយមបារាំង-ជប៉ុន នាអំឡុងដើមទសវត្សទីសែសិប។
- ពន្យល់ន័យប្រធាន៖ យោងតាមន័យរបស់ពាក្យគន្លឹះ ប្រធានខាងលើចង់ឱ្យធ្វើការប្រៀបធៀបពីការចិញ្ចឹមជីវិតរស់នៅរបស់ប្រជាជនខ្មែរនាសម័យបច្ចុប្បន្ន ទៅនឹងសម័យដែលប្រទេសខ្មែររស់នៅក្រោយការគ្រប់គ្រងឱ្យបអាណានិគមនិយមបារាំង-ជប៉ុន នាអំឡុងដើមទសវត្សទីសែសិបកន្លងមក។

- បកស្រាយប្រធានៈ
  - ❖ លក្ខណៈដូចគ្នា
    - ប្រកបការងារកសិកម្មដូចគ្នា(ធ្វើស្រែចំការ ចិញ្ចឹមសត្វ នេសាទ...)
    - ប្រកបការងារជួញដូរដូចគ្នា(លក់ទំនិញ ដើរលក់ ជួញដូរដី ...)
    - ប្រកបការងាររាជការដូចគ្នា(ឃុំ ប៉ូលីស លោកចៅហ្វាយ ...)
  - ❖ លក្ខណៈខុសគ្នា
    - ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យបច្ចុប្បន្ន
      - ▪ ប្រកបការងារកសិកម្ម ដោយបច្ចេកទេសទំនើប ទាន់សម័យ(ត្រាក់ទ័រ ជម្រើសពូជ ប្រើជី ប្រព័ន្ធធារាសាស្ត្រ ...)
      - ▪ ប្រជាជនមានសិទ្ធិសេរីភាពក្នុងការរកទទួលទាន មានជីវភាពធូរធារ(ចង់ប្រកបរបរអ្វីក៏បានឱ្យតែស្របច្បាប់ប្រទេសជាតិរីកចម្រើន...)
      - ▪ ប្រជាជនរស់នៅក្នុងភាពសន្តិភាព(ការដើរហើរមិនមានការភ័យខ្លាចទោះយប់ ឬថ្ងៃ)
    - ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យនិគមនិយមបារាំង-ជប៉ុន
      - ▪ ប្រកបការងារកសិកម្មតាមបែបបុរាណ(ធ្វើស្រែប្រវាស់មេឃ ដាំដំណាំយថាផល...)

- ▪ ប្រជាជនរស់នៅក្រោមភាពក្រីក្រ ប្រទេសជាតិទន់ខ្សោយ គ្មានសិទ្ធសេរីភាពក្នុងការរកទទួលទាន(ជាប់កំណែន សង្គ្រាម...)
- ▪ ប្រជាជនរស់នៅក្នុងភាពអសន្តិសុខ(រត់គេចពីការធ្វើបាបរបស់អ្នកកាន់អំណាច ការទម្លាក់គ្រាប់បែករបស់សត្រូវ...)

- សរុបសេចក្តី៖ សរុបមកឃើញថាទម្រង់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យនីមួយៗប្រហាក់ប្រហែលគ្នា តែមានសារជាតិមិនដូចគ្នាទេ ព្រោះសម័យបច្ចុប្បន្នប្រជាជនខ្មែររស់នៅមានជីវភាពធូរធារ មានសិទ្ធិសេរីភាព រស់ក្នុងសុខសន្តិភាព រីឯក្នុងសម័យអាណានិគមនិយមបារាំងជប៉ុន ប្រជាជនខ្មែររស់នៅមានជីវភាពក្រីក្រលំបាកវេទនា គ្មានសិទ្ធិសេរីភាព រស់នៅក្រោមការជិះជាន់គាបសង្កត់របស់អ្នកមានអំណាចក្នុងស្រុកបរទេស និងក្រោមការភ័យខ្លាចនៃសង្គ្រាមឈ្លានពាន។

## គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មតិប្រធានខាងលើលើកឡើងនេះ ចង់បង្ហាញឱ្យឃើញពីរស់នៅធ្វើការរកស៊ីចិញ្ចឹមជីវិតរបស់ប្រជាជនខ្មែរ ក្នុងសម័យឯករាជ្យបច្ចុប្បន្ន ខុសប្លែកពីសម័យអាណានិគមនិយមបារាំង-ជប៉ុន។ ការរស់នៅរបស់ប្រជាជនខ្មែរក្នុងសម័យឯករាជ្យបច្ចុប្បន្នមានជីវភាពធូរធារ និងប្រកបទៅដោយសន្តិភាព។
- ទស្សនផ្ទាល់ខ្លួន៖ ដូច្នេះយើងជាសិស្សត្រូវខិតខំប្រឹងប្រែង តស៊ូព្យាយាមរៀនសូត្រឱ្យបានចេះដឹងខ្ពង់ខ្ពស់ ដើម្បីថ្ងៃក្រោយក្លាយជា

*ពលរដ្ឋល្អ អ្នកដឹកនាំល្អ រួមចំណែកកសាងជាតិ រស់នៅដោយឯករាជ្យ គ្មានសត្រូវមើលងាយ និងជិះជាន់។*

**ប្រធានទី៣៣៖** ចូរអ្នកប្រៀបធៀប"សង្គមខ្មែរនាសម័យបច្ចុប្បន្ន ទៅនឹងសម័យអាណានិគមនិយមបារាំង-ជប៉ុន"។ តើមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងដូចម្តេចខ្លះ?

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សង្គមផ្លាស់ប្តូរអ្វីៗក៏ផ្លាស់ប្តូរទៅតាមនោះដែរ។
- ចំណូលបញ្ហា៖ អាស្រ័យដោយហេតុនេះហើយទើបបានជាមានប្រធានមួយលើកឡើងថា៖ "សង្គមខ្មែរនាសម័យបច្ចុប្បន្ន ទៅនឹងសម័យអាណានិគមនិយមបារាំង-ជប៉ុន"។
- ចំណោទបញ្ហា៖ តើសង្គមខ្មែរនាសម័យទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងដូចម្តេចខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ គប្បីត្រូវយល់ន័យនៃពាក្យគន្លឹះជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ សង្គមខ្មែរនាសម័យបច្ចុប្បន្ន មានន័យថាការរស់នៅចិញ្ចឹមជីវិត និងការគ្រប់គ្រងប្រទេសខ្មែរ សម័យបច្ចុប្បន្ន។ ឃ្លាសម័យអាណានិគមនិយមបារាំង-ជប៉ុន សំដៅយកន័យសម័យដែលប្រទេសខ្មែររស់នៅក្រោមការគ្រប់គ្រងឧបអាណានិគមនិយមបារាំង-ជប៉ុន នាអំឡុងដើមទសវត្សទីសែសិប។
- ពន្យល់ន័យប្រធាន៖ ប្រធានខាងលើចង់ឱ្យធ្វើការប្រៀបធៀបពីការចិញ្ចឹមជីវិត ការគ្រប់គ្រងប្រទេសខ្មែរ នាសម័យបច្ចុប្បន្ន ទៅនឹងសម័យដែលប្រទេសខ្មែររស់នៅ និងស្ថិតក្រោមការគ្រប់គ្រងឧ

បរអាណានិគមនិយមបារាំង-ជប៉ុន នាអំឡុងដើមទសវត្សទីសែសិបកន្លងមក។

- បកស្រាយប្រធានៈ
  - ❖ លក្ខណៈដូចគ្នា
    - ការរស់នៅប្រកបរបររកស៊ីចិញ្ចឹមជីវិតដូចគ្នា(ធ្វើស្រែចំការ ចិញ្ចឹមសត្វ នេសាទ លក់ដូរ)
    - មានអ្នកការជាការគ្រប់គ្រងដូចគ្នា(ឃុំ ប៉ូលិស លោកចៅហ្វាយ...)
    - មានការអភិវឌ្ឍសង្គមដូចគ្នា(កសាងព្រលានយន្តហោះ...)
  - ❖ លក្ខណៈខុសគ្នា
    - សង្គមខ្មែរនាសម័យបច្ចុប្បន្ន
      - ▪ ការគ្រប់គ្រងសង្គមដោយលទ្ធិប្រជាធិបតេយ្យ(មានការបោះឆ្នោតក្នុងការជ្រើសរើសថ្នាក់ដឹកនាំរដ្ឋបាលឃុំ សង្កាត់ ខេត្ត ក្រុង ប្រជារាស្ត្រមានសិទ្ធិបញ្ចេញមតិ...)
      - ▪ ការអភិវឌ្ឍសង្គមល្អប្រសើរ(បានកសាងហេដ្ឋារចនាសម្ព័ន្ធច្រើនផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ...)
      - ▪ ជីវភាពរបស់ប្រជាជនល្អប្រសើរ(មានសិទ្ធិសេរីភាពគ្រប់គ្រាន់ គ្មានការភ័យខ្លាចក្នុងការរស់នៅចិញ្ចឹមជីវិត)
    - សង្គមខ្មែរនាសម័យអាណានិគមនិយមបារាំង-ជប៉ុន

- ការគ្រប់គ្រងសង្គមដោយផ្តាច់ការ(អ្នកកាន់អំណាចក្នុងស្រុក និងបរទេសជិះជាន់គាប់សង្កត់ ធ្វើបាបប្រជាជន...)
- ការអភិវឌ្ឍសង្គមមានកម្រិតទាប(កសាងវិស័យនានាតិចតួច ផ្លូវថ្នល់ ពលានយន្តហោះ...)
- ជីវភាពរបស់ប្រជាជនក្រីក្រលំបាក វេទនា(ដីស្រែបង់ពន្ធ ជាប់កំណែន សង្គ្រាម...)

- សរុបសេចក្តី៖ សរុបមកឃើញថាទម្រង់សង្គមខ្មែរនាសម័យនីមួយៗមានលក្ខណៈប្រហាក់ប្រហែលគ្នា តែមានខ្លឹមសារមិនដូចគ្នាទេ...។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ មតិប្រធានខាងលើលើកឡើងនេះ ចង់បង្ហាញឱ្យឃើញពីសង្គមខ្មែរ ក្នុងសម័យឯករាជ្យបច្ចុប្បន្ន ខុសប្លែកពីសម័យអាណានិគមនិយមបារាំង-ជប៉ុន។ សង្គមខ្មែរសម័យឯករាជ្យបច្ចុប្បន្នប្រជាជនមានជីវភាពធូរធារ ប្រកបទៅដោយសន្តិភាព និងមានការអភិវឌ្ឍជាតិខ្ពស់។
- ទស្សនផ្ទាល់ខ្លួន៖ ដូច្នេះយើងជាសិស្សត្រូវខិតខំប្រឹងប្រែង តស៊ូព្យាយាមរៀនសូត្រឱ្យបានចេះដឹងខ្ពង់ខ្ពស់ ដើម្បីរួមចំណែកកសាងជាតិ ឱ្យបានរីកចម្រើនជឿនលឿនដូចអរិយប្រទេសលើសកលលោក ចៀសផុតពីការជិះជាន់នៃបរទេសឈ្លានពាន។
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៣៤៖** ចូរប្រៀបធៀប“ចរិតលក្ខណៈរបស់មីងពតម្តាយនាងហេង និងយាយចាន់ក្នុងការទុកដាក់កូនចៅ”។ តើការទុកដាក់កូនចៅរបស់អ្នកទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ បំផុសគំនិតទូទៅទាក់ទងនឹងប្រធានបទ។
- ចំណូលបញ្ហា៖ ដោយសារបញ្ហាបែបនេះហើយទើបមានទស្សនៈមួយលើកឡើងថា៖“ចរិតលក្ខណៈរបស់មីងពតម្តាយនាងហេង និងយាយចាន់ក្នុងការទុកដាក់កូនចៅ”។
- ចំណោទបញ្ហា៖ តើការទុកដាក់កូនចៅរបស់អ្នកទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ?

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីបកស្រាយប្រធានខាងលើឱ្យបានក្បោះក្បាយ យើងគប្បីត្រូវយល់ន័យនៃពាក្យគន្លឹះជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖ ចរិតលក្ខណៈ បែបបទនៃការប្រព្រឹត្ត កិរិយាមារយាទ គ្រឿងសម្គាល់ចរិយាមារយាទ។ ការទុកដាក់កូនចៅ គឺការរៀបចំទុកដាក់ឱ្យកូនចៅមានគូរស្រករ មានប្តី មានប្រពន្ធ មានគ្រួសារ។
- ពន្យល់ន័យប្រធាន៖ ប្រធានខាងលើនេះចង់បង្ហាញឱ្យឃើញថា បែបបទនៃការប្រព្រឹត្ត ឬកិរិយាមារយាទរបស់មីងពតម្តាយនាងហេង និងយាយចាន់ក្នុងការរៀបចំទុកដាក់ឱ្យកូនចៅមានគូស្រករ

មានប្តីប្រពន្ធ ឬមានគ្រួសារមានលក្ខណៈដូចគ្នា និងខុសគ្នាដូចម្តេច។

- បកស្រាយប្រធានៈ
  - ❖ លក្ខណៈដូចគ្នារបស់មីងពត និងយាយចាន់
    - ចង់ឱ្យកូនចៅមានទ្រព្យសម្បត្តិ
    - ចង់ឱ្យកូនចៅមានបុណ្យសក្តិ មានកិត្តិយស
    - ចង់ឱ្យកូនចៅរស់នៅមានសេចក្តីសុខ។
  - ❖ លក្ខណៈខុសគ្នារបស់មីងពត និងយាយចាន់

    \+ ចរិតលក្ខណៈរបស់មីងពត
    - ចេះពិចារណាទៅលើហេតុការណ៍ដែលកើតមានឡើង
    - ស្តាប់គំនិតយោបល់ដែលត្រឹមត្រូវរបស់អ្នកដទៃ
    - មិនលោភលន់បំពាន
    - មានទស្សនៈទូលាយ មិនអាត្មានិយម
    - ផ្តល់សិទ្ធិគ្រប់យ៉ាងដល់កូន ក្នុងការសម្រេចដោគវាសនាសម្រាប់ខ្លួន។

    \+ ចរិតលក្ខណៈរបស់យាយចាន់
    - អាត្មានិយមគិតតែប្រយោជន៍ផ្ទាល់ខ្លួន
    - មើលឃើញបុណ្យសក្តិមាសប្រាក់ជាធំ
    - មិនគិតពីសុខទុក្ខអ្នកដទៃ
    - ខ្វះការពិចារណារកហេតុផលខុសត្រូវ។

- សរុបសេចក្តី៖ សរុបសេចក្តីមកមតិខាងលើបង្ហាញថា ទាំងមីងពត ទាំងយាយចាន់សុទ្ធតែមានគំនិតចង់ឱ្យកូនចៅមានទ្រព្យសម្បត្តិ បុណ្យសក្តិ កិត្តិយស និងរស់នៅក្នុងសុភមង្គលដូចគ្នា។ ប៉ុន្តែយាយចាន់ជាមនុស្សអាត្មានិយម គិតតែប្រយោជន៍ផ្ទាល់ខ្លួន មើលឃើញតែបុណ្យសក្តិមាសប្រាក់ មិនខ្វល់សុខទុក្ខអ្នកដទៃ។ ចំណែកមីងពតមានទស្សនៈទូលាយ ផ្តល់សិទ្ធិគ្រប់យ៉ាងដល់កូនចៅក្នុងការជ្រើសរើសគូស្រករ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ ឆ្លងតាមការលើកឡើងនេះ ចង់បង្ហាញពីវិធីក្នុងការជ្រើសរើសគូស្រករឱ្យកូនចៅរបស់មីងពតខុសប្លែកពីយាយចាន់។ ការជ្រើសរើសគូស្រករឱ្យកូនចៅរបស់មីងពតមានទស្សនៈជឿនលឿនទាន់សម័យនិយម។
- ទស្សនផ្ទាល់ខ្លួន៖ ដូច្នេះក្នុងនាមយើងជាយុវជន យុវនារីសម័យថ្មី មុននឹងសម្រេចចិត្តធ្វើការថ្លឹងថ្លែងឱ្យហ្មត់ចត់ បើមិនប្រាកដកុំប្រថុយ គួរគិតសួរយោបល់ ឬពិភាក្សាជាមួយអ្នកចាស់ទុំជាមុនសិន ចៀសវាងការប៉ះពាល់ ឬរំខានដល់អ្នកដទៃ។
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៣៥៖** រឿងព្រះវេស្សន្តរបានអប់រំសង្គមអ្នកដឹកនាំខ្មែរឱ្យមានគំនិត និងអនុវត្តលទ្ធិប្រជាធិបតេយ្យក្នុងសង្គមរស់នៅ។ ចូរបកស្រាយមតិខាងលើនេះ។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៥ទៅ៣បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យអប់រំ និងពាក្យលទ្ធិប្រជាធិបតេយ្យមកពន្យល់
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនិងអំណះអំណាង
    - ⇨ គោរពមតិរាស្ត្រនៃនគរជេតុត្តរជាធំ
    - ⇨ ស្រឡាញ់ប្រយោជន៍រួមជាងប្រយោជន៍បុគ្គល
    - ⇨ អ្នកដឹកនាំត្រូវធ្វើតាមបទបញ្ជាថ្នាក់ក្រោម ពិសេសមតិភាគច្រើន...
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៣បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៣ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៤ទៅ៥បន្ទាត់...

- ពាក្យស្លោក ឬសុភាសិត៖ មានក៏ដាក់ គ្មានក៏មិនបាច់ដាក់...

**ប្រធានទី៣៥៖** មានទស្សនៈមួយបានពោលថាៈ“ភាសាបាលីសំស្រ្កឹតជាម្តាយនៃភាសាខ្មែរ”។ តើមតិនេះត្រឹមត្រូវដែរឬទេ? ចូរពិភាក្សាដោយលើកយកសេចក្តីអះអាងមកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពិភាក្សា...

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យភាសាបាលីសំស្រ្កឹត និងពាក្យម្តាយមកពន្យល់
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនិងអំណះអំណាង
  + មតិស្រប៖ និយាយឱ្យស្របនឹងប្រធានដែលបានលើកឡើង
    - ⇨ ពាក្យជាច្រើនដែលមានប្រភពកម្ចីមកពីបាលី មិត្ត ចិត្ត បុត្ត...
    - ⇨ ពាក្យជាច្រើនដែលមានប្រភពកម្ចីមកពីសំស្រ្កឹត បុត្រ សមុទ្រ ល័ក្ខ...

⇨ ពាក្យជាច្រើនដែលមានប្រភពកម្ចីមកពីបាលីសំស្ក្រឹត ប្រយោជន៍ សារសំខាន់ ប្រណិប័តន៍...

**ឧទាហរណ៍**

⇨ ការស្រាវជ្រាវរបស់អ្នកភាសាវិទ្យា ហ្ស៊ាន តូប៉ុង អះអាងថាភាសាបាលីសំស្ក្រឹតភាសាដើមកំណើតរបស់ជនជាតិឥណ្ឌា ហើយជាអ្នកបង្កើតអក្សរខ្មែរ...

⇨ ទស្សនៈរបស់លោកឈឹម ក្រសេម និយាយថាខ្មែរមានប្រភពពីឥណ្ឌា...

\+ សរុបមតិស្រប៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

⎈ សំណួរភ្ជាប់សេចក្តី៖ ចោទសំណួរផ្ទុយពីចំណោទបញ្ហា...

\+ មតិផ្ទុយ៖ និយាយឱ្យផ្ទុយពីប្រធានដែលបានលើកឡើង

⇨ ភាសាខ្មែរមិនប្រែប្រួលទៅតាមវចនៈ ភេទ

⇨ ភាសាខ្មែរគ្មានការបំបែកលិង្គ ឬភេទ

⇨ ភាសាខ្មែរមិនឡើងចុះ សូរស្មើរ

⇨ មានពាក្យសំគាល់ភេទស្រី ប្រុស មីង ពូ ម៉ែ ពុក...

⇨ មានពាក្យ**មេ**នៅខាងដើម....

**ឧទាហរណ៍**

⇨ សៀវភៅត្រឹង ងា បានបញ្ជាក់ថាខ្មែរជាជនជាតិពិសេសមួយ...

\+ សរុបមតិផ្ទុយ៖ សរសេរយ៉ាងតិច៤ទៅ៥បន្ទាត់...

- សំយោគមតិ៖ សរសេរយ៉ាងតិច៧ទៅ៩បន្ទាត់...

**គ. សេចក្តីបញ្ចប់**

- *វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិចពទៅ៨បន្ទាត់...*
- *ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិចពទៅ៨បន្ទាត់...*
- *ពាក្យស្លោក ឬសុភាសិត៖*

**ប្រធានទី៣៦៖** មានសុភាសិតមួយលើកឡើងថា៖"ចំណេះជាអាហារ ប្រាជ្ញាជាអាវុធ"។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យចំណេះ និងពាក្យប្រាជ្ញាមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...

**ប្រធានទី៣៧៖** មានសុភាសិតមួយលើកឡើងថា៖ «ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ»។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកឃ្លាឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ(ន័យចំ ន័យធៀប) រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៣៨៖** មានសុភាសិតមួយលើកឡើងថា៖«កុំពត់ស្រឡៅ កុំប្រដៅស្រីមានៈ»។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យស្រឡៅ និងស្រីមានៈមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្ដារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្ដី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៣៩៖** មានសុភាសិតមួយលើកឡើងថាៈ"ក្រពើវង្វេងបឹង"។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យក្រពើមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ(ន័យចំ ន័យធៀប) រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៤០៖** មានសុភាសិតមួយលើកឡើងថា៖ "ធ្វើស្រែខុសមួយឆ្នាំ ត្រូវមួយឆ្នាំ យកប្តីប្រពន្ធ តែខុស គឺខុសរហូត"។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យធ្វើស្រែ និងពាក្យយកប្តីប្រពន្ធមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៤១៖** មានសុភាសិតមួយលើកឡើងថា៖"ចេះដប់មិនស្មើនឹងប្រសប់មួយ"។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- *លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...*
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្ដី

- *ឃ្លាភ្ជាប់សេចក្ដី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...*
- *ពន្យល់ពាក្យគន្លឹះ៖ យកពាក្យមិនស្មើនឹងមកពន្យល់...*
- *ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...*
- *បកស្រាយប្រធាន៖ បកស្រាយពិស្ដារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣*
- *សរុបសេចក្ដី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...*

### គ. សេចក្ដីបញ្ចប់

- *វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...*
- *ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...*
- *ពាក្យស្លោក ឬសុភាសិត៖*

**ប្រធានទី៤២** មានសុភាសិតមួយលើកឡើងថា៖“ទន្លេដប់ មិនស្កប់សមុទ្រមួយ”។ ចូរបកស្រាយ ដោយលើកយកអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យទន្លេ និងពាក្យសមុទ្រមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្ដារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្ដី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៤៣៖** មានទស្សនៈមួយលើកឡើងថា៖ «អ្នកសិក្សាគប្បីស្រឡាញ់ការអាន ទើបទទួលបានជោគជ័យ»។ ចូរបកស្រាយ ដោយលើកយកក្នុងសង្គមមកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យស្រឡាញ់ និងពាក្យជោគជ័យមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៤៣៖** មានទស្សនៈមួយលើកឡើងថា៖«អ្នកសិក្សាគប្បីកំណត់នូវគោលបំណងអនាគតឱ្យបានច្បាស់ ទើបមិនមាននូវវិប្បដិសារី»។ ចូរបកស្រាយ ដោយលើកយកក្នុងសង្គមមកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៣ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យគោលបំណង និងពាក្យវិប្បដិសារីមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៣ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៣ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៤៥៖** មានទស្សនៈមួយលើកឡើងថា៖“មានតែអ្នកសិក្សាទេ ទើបដឹងថាខ្លួនកំពុងធ្វើអ្វី និងដឹងពីសមត្ថភាពរបស់ខ្លួនច្បាស់ជាង អ្នកឯទៀត”។ ចូរបកស្រាយ ដោយលើកយកក្នុងសង្គមមកបញ្ជាក់។

## គម្រោងតែងសេចក្តី

### ក. សេចក្តីផ្តើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យពិបាកមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាង យ៉ាងតិច៣
- សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

**ប្រធានទី៤៦៖** មានទស្សនៈមួយលើកឡើងថា៖"មានតែអ្នកសិក្សាទេ ទើបដឹងថាខ្លួនកំពុងធ្វើអ្វី និងដឹងពីសមត្ថភាពរបស់ខ្លួនច្បាស់ជាងអ្នកឯទៀត"។ ចូរបកស្រាយ ដោយលើកយកក្នុងសង្គមមកបញ្ជាក់។

## គម្រោងតែងសេចក្ដី

### ក. សេចក្ដីផ្ដើម

- លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ខ. តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...
- ពន្យល់ពាក្យគន្លឹះ៖ យកពាក្យពិបាកមកពន្យល់...
- ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...
- បកស្រាយប្រធាន៖ បកស្រាយពិស្ដារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣
- សរុបសេចក្ដី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...

### គ. សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...
- ពាក្យស្លោក ឬសុភាសិត៖

***ប្រធានទី៤៧៖*** *មានទស្សនៈមួយលើកឡើងថា៖"មនុស្ស និងអក្សរសិល្ប៍មិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ"។ ចូរបកស្រាយ។*

## ***គម្រោងតែងសេចក្តី***

### ***ក. សេចក្តីផ្តើម***

- *លំនាំបញ្ហា៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...*
- ចំណូលបញ្ហា៖ លើកយកបញ្ហារបស់ប្រធានមកដាក់ឡើងវិញ...
- ចំណោទបញ្ហា៖ ចោទបែបពន្យល់ (២សំណួរ)

### ***ខ. តួសេចក្តី***

- *ឃ្លាភ្ជាប់សេចក្តី៖ សរសេរយ៉ាងតិច២ទៅ៣បន្ទាត់...*
- *ពន្យល់ពាក្យគន្លឹះ៖ យកពាក្យពិបាកមកពន្យល់...*
- *ពន្យល់ន័យប្រធាន៖ សរសេរយ៉ាងតិច៥ទៅ៦បន្ទាត់...*
- *បកស្រាយប្រធាន៖ បកស្រាយពិស្តារ រួមផ្សំនឹងអំណះអំណាងយ៉ាងតិច៣*
- *សរុបសេចក្តី៖ សរសេរយ៉ាងតិច៥ទៅ៧បន្ទាត់...*

### ***គ. សេចក្តីបញ្ចប់***

- *វាយតម្លៃប្រធាន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...*
- *ទស្សនផ្ទាល់ខ្លួន៖ សរសេរយ៉ាងតិច៧ទៅ៨បន្ទាត់...*
- *ពាក្យស្លោក ឬសុភាសិត៖*

ឯកសារយោង

1. ក្រសួងអប់រំ ១៩៨៣ វេយ្យាករណ៍ខ្មែរ ថ្នាក់ទី៥
2. ក្រសួងអប់រំ យុវជន និងកីឡា ១៩៩៦ ភាសាខ្មែរ ថ្នាក់ទី៧
3. ព្រៃ សំបូរ ២០១៥ សរសេរតាមអាន និងតែងសេចក្តី ថ្នាក់ទី ៩
4. ឃិន ធី ២០១២ សរសេរតាមអាន និងតែងសេចក្តី ថ្នាក់ទី៧
5. សម្តេចព្រះសង្ឃរាជ ជួន ណាត ១៩៦៧ វចនានុក្រមខ្មែរ
6. យ៉ង់ កំស៊ាន ២០១៥ សរសេរតាមអាន និងតែងសេចក្តី ថ្នាក់ ទី៨
7. ក្រសួងអប់រំ យុវជន និងកីឡា ២០១៧ វិធីសាស្ត្រនៃការសរសេរតែងសេចក្តី
8. ក្បួនសំរាប់ធ្វើតែងសេចក្តី រៀបរៀងដោយសាស្ត្រាចារ្យខ្មែរ **លឹម សុខុម**
9. www.google/youtube-veang engksa.com



គោព្រៃ (Bos sauveli) ជាសត្វចតុប្បាទដែលត្រូវបានចាត់ទុកថាជានិមិត្តរូបនៃ ព្រះរាជាណាចក្រកម្ពុជាដែលមានការទទួលស្គាល់ដោយ ព្រះរាជក្រឹត្យ។ វាមាន ប្រវែងខ្លួនពី ២.១ ទៅ ២.៣ ម៉ែត្រ ,កម្ពស់ពី ១.៧ ទៅ ១.៩ ម៉ែត្រ និងទម្ងន់ចន្លោះ ពី ៧០០ ទៅ ៩០០ គីឡូក្រាម។

**និពន្ធនិងរៀបរៀងដោយ អ្នកគ្រូ វណ្ណា ឆារ៉ា**